# របាំប្រជាប្រិយខ្មែរ



BUDDHIST INSTITUTE LIBRARY

តាមឯកសារស្រាវជ្រាវប្រវត្តិសាស្ត្រ

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

# របាំប្រជាប្រិយខ្មែរ

តាមការស្រាវជ្រាវរបស់ក្រុមជំនុំទំនៀមទម្លាប់
ព្រមទាំង សមាជិកឆ្លើយឆ្លង គ្រប់ខេត្ត

រៀបរៀងដោយ :

លោក ចាប-ពិន អធិបតីក្រុមជំនុំ

អ្នកស្រី ពេជ្រ-សល់, លោក លី-ធាមតេង និង ស្ដើង-ជួរ

សមាជិកនៃក្រុមជំនុំ

គំនូររបស់ លោក ចាប-ធូ

បោះពុម្ពលើកដំបូង

INSTITUT BOUDDHIQUE
LIBRARY
BUDDHIST INSTITUTE

ភ្នំពេញ

www.budinst.gov.kh www.elibraryofcambodia.org

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

## ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង
**ពុទ្ធសាសនបណ្ឌិត្យ និង បណ្ណាល័យអេឡិចត្រូនិចខ្មែរ**
ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត
ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ
សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់
**អង្គការរីស្សូ កូសីុ-កៃ  វិទ្យាស្ថានបើកទូលាយ**
**ការុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**
ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh        www.elibraryofcambodia.org


www.budinst.gov.kh        www.elibraryofcambodia.org

# សេចក្ដីផ្ដើម

ប្រទេសខ្មែរយើង ដែលមានអាយុរាប់ពាន់ឆ្នាំមកហើយ, ប្រកបដោយគ្រឿងដំណែលអារ្យធម៌បូរមបុរាណជាច្រើនអនេក ហេតុដល់ទៅជនជាតិជិតខាងនាំគ្នាប្រឌិតយកបែបទៅធ្វើជាគោលគំនិតសំរាប់សាងអារ្យធម៌គេផងៗ អ្នកសិក្សាស្រាវជ្រាវអំពីអារ្យធម៌សាកល គេក៏បានកត់ទុកយ៉ាងច្បាស់ថា អារ្យធម៌ខ្មែរ ស្ថិតនៅក្នុងបណ្ដាអារ្យធម៌ " អាស៊ីខាងត្បូង " ហៅយ៉ាងទៀតថា អូស្ត្រូ-អាស៊ី ( Austro-Asiatiques ) ។ អារ្យធម៌ពួកនេះ កើតឡើងពីមនុស្សដើម ឬ ហៅថា វេដ្ឋាសី ( Les Autochtones ) ដែលមានកំណើតកើតជា រស់នៅយ៉ាងយូរលង់លើទឹកដីដំបន់នេះ ហើយដែលសព្វថ្ងៃបានក្លាយទៅជាសញ្ជាតិផ្សេង ៗ គ្នា មានការរៀបចំជីវភាព ការសាងអារ្យធម៌ថ្មីដោយឡែកៗពីគ្នាមានជនជាតិ ខ្មែរ, លាវ, ភូមា, សៀម, យួន, ម៉ាឡាយូ, ឥណ្ឌូណេស៊ី, ហ្វីលីពីន និង កោះនូវែលហ្សេឡង់ សព្វថ្ងៃនេះ ។ អាស្រ័យដោយប្រភពកើតឡើងពីជនជាតិដើម ឬ មនុស្សដើម ស្រករគ្នាហើយមានរបបរស់នៅដូចគ្នា របស់ពួកវេដ្ឋាសីទាំងនោះ ហើយ បានជាសព្វថ្ងៃនេះ អារ្យធម៌នៃជនជាតិទាំងប៉ុន្មានដែលរាប់មកខាងលើនេះមានចំណែកប្រហាក់ប្រហែលគ្នា ឬ ចំណុចខ្លះសឹងតែដូចបេះបិទក៏

www.bophan...gov.kh www.elibraryofcambodia.org

មាន, តួយ៉ាងដូចជាទំនៀមទម្លាប់, សិល្បៈផ្សេង ៗ ជាតាទិ ។ ហេតុនេះទើបគេចាត់ថាសាសន៍ណាចំឡងពីសាសន៍ណាឲ្យប្រាកដសឹងតែពុំបាន លើកលែងតែសាសន៍ជាតិណាដែលទើបតែកើតថ្មី ពុំមានពួកដ្ឋាសីដូចគេ ( ឧ. ស្រុកផឹតខាងខ្វះ . . . ) ។ ឧបមាដូចជារបាំស្នែងទន្សោង នឹងរបាំគោះអង្រែ គេប្រទះឃើញនៅស្រុកខ្មែរយើងផង នៅស្រុកយួន (ផ្នែកខាងជើង) ផង នឹងនៅស្រុកហ្វីលិពីនផង ។ ដូច្នេះនឹងសន្មតថា ក្បាច់រាំនេះកើតពីនរណាម្នាក់ឲ្យដាច់មុខមិនបាន ព្រោះថាតាមពិតគឺកើតមកពីពួកមនុស្សដើម ដែលនិយមយក របស់នៅមកធ្វើជាមូលដ្ឋាន; គឺថាបើពេលនោះខ្លួនរស់នៅដោយរបៀបណា ក៏ប្រឌិតយករបៀបនោះមកធ្វើជារបាំរាំរែកឲ្យកើតការសប្បាយរីករាយឡើង ។ ជាកស្តុតាងដូចជាកាលៈនោះគេប្រកបរបរប្រមាញ់ជាអម្រែសអម្រាល់ថ្ងៃ ម្ល៉ោះហើយ ការបង្កើតសិល្បៈរបាំក្រុមខ្លួន ក៏ប្រឌិតយកតាមនោះ មានសត្វ, មានស្នែងសត្វ, មានមនុស្សព្រៃ ។ល។ តួយ៉ាងក្នុងរបាំត្រុដិ, របាំស្នែងទន្សោង, របាំក្ងោកជាឧទាហរណ៍ស្រាប់ ។

ដោយសារគោលគំនិតចង់រក្សាទុកកេរ្តិ៍ដំណែលបុរាណ ឲ្យនៅជាប់លាប់តទៅទៀត ទើបក្រុមជំនុំទំនៀមទម្លាប់ខ្មែរ ចាប់ធ្វើការស្រាវជ្រាវរើរកតាមឯកសារ ដែលសមាជិកធ្វើយត្តផ្ញើមកពីខេត្តក្រៅខ្លះ និងតាម

ការសាកសួរផ្ទាល់ដល់អ្នកធ្លាប់លេងរបាំទាំងនេះខ្លះ ហើយខ្លះទៀតសរ-សេរតាមការឃើញផ្ទាល់ ; រួចហើយប្រមូលក្រងឲ្យកើតជាសៀវភៅនេះឡើងសំរាប់ជូនដល់កុលបុត្ត កុលធីតាខ្មែរយើង គ្រប់ថ្នាក់រស់ជាតិអារ្យ-ធម៌ដើមរបស់ខ្លួន ។ ព្រោះថា ដើម្បីពត់និស្ស័យមនុស្សឲ្យចេះស្រឡាញ់អារ្យធម៌ជាតិ គេនឹងតែណែនាំជាបឋមឲ្យស្គាល់អារ្យធម៌កំណើតរបស់ជាតិខ្លួនសិន ។ កាលណាជ្រួតជ្រាបស៊ប់ស្ងួនក្នុងអារ្យធម៌ជាតិខ្លួន បានជាមូល-ដ្ឋានហើយ ទើបយើងចាប់ហាត់ រៀនចេះ រៀនស្គាល់អារ្យធម៌នានាជាតិយកមកផ្សំធ្វើជាប្រដាប់ប្រដា ជួយស្ថាបនាអារ្យធម៌ទំនើបថ្មីសំរាប់ជាតិនៅបច្ចុប្បន្នកាលនេះឲ្យបានជាប់លាប់ល្អឡើង ។ បើពុំនោះទេ ច្បាស់ជាយល់បញ្ហាអារ្យធម៌ជាតិដោយគ្មានមូលដ្ឋានឡើយ, ប្រសិនជាគ្មានមូល-ដ្ឋានហើយ ជននោះអាចយល់ច្រឡំថា ជាតិខ្លួនគ្មានអារ្យធម៌ ឬក៏ថាអារ្យធម៌ខ្លួនចំលងពីគេ ជាមិនខាន ។

ប៉ុន្តែ ការរាវស្រាវជ្រាវប្រមូលចងក្រងតម្រាប់តម្រាទាំងនេះ ពុំមែនជាការងាយស្រួលឡើយ ព្រោះបើដូចជាមនុស្សស្ទើរតែផុតលេតសូន្យបាត់សង្ខារទៅហើយ ហើយយើងកេនសង់ទៅប្រកបឲ្យសះស្បើយមានជីវិតជីវ៉ាឡើងវិញដូចេះ ជាការពុំងាយទេ ។ ដោយយល់ច្បាស់ថាការនេះត្រូវធ្វើអស់ពេលយ៉ាងយូរហើយហត់ចត់ផង ទើបយើងប្រគល់ការៈនេះ

www.budinst.gov.kh www.elibraryofcambodia.org

ទៅលោក លី-ឆាមតេង ជាសមាជិកនៃក្រុមជំនុំ ឲ្យមើលឯកសារស្តីពីរបាំដែលមានតាំងពីបុរាណ ហើយសុំបសួរទៅសមាជិកឆ្លើយឆ្លងទៅតាមខេត្តក្រៅព្រមទាំងសាកសួរផ្ទាល់ដល់ទីកន្លែងលេងរបាំទាំងនេះផង ដើម្បីពិនិត្យផ្ទៀបផ្ទឹម ករកហេតុផលឲ្យសមរម្យ ហើយសរសេរឡើងឲ្យមានរបៀបផែនស្រួលយលតាមលំដាប់ ដូចជា អំពីគ្រឿងប្រដាប់, សំលៀកបំពាក់, ក្បាច់រាំ, ទំនុកច្រៀង និងប្រវត្តិនៃរបាំ, .. ដោយមានលោក ចាប-ពិន អគ្គិបតីក្រុមជំនុំ ជួយណែនាំ និងមានអ្នកស្រី ពេជ្រ សល់, លោក ស្តីង-ឆ្នួរ ជាសមាជិក ជួយផ្តល់ឯកសារជួយគាត់តែងផង ។

មិនតែប៉ុណ្ណោះ ដើម្បីឲ្យបានអស់ចិត្ត ក្រុមជំនុំក៏បានអញ្ជើញអស់លោកចាស់ទុំដែលធ្លាប់ស្គាល់ច្បាស់ក្នុងមុខការ ខាងសិល្បៈដែលទាក់ទងនឹងរបាំទាំងនេះ មកជួយពិនិត្យផ្ទៀងផ្ទាត់ទៀត គឺ ៖

១– លោកឧកញ៉ាកវីកនុគូល ទិម-យឹង ធ្វើការនៅព្រះបរមរាជវាំង ដែលធ្លាប់បាត់ចែងល្បែង-របាំផ្សេងៗ ក្នុងព្រះរាជពិធី តាំងពីលោកនៅក្មេងរហូតមកដល់សព្វថ្ងៃ លោកមានអាយុជាង ៨០ ឆ្នាំហើយ ។

២– លោក គេត-វៀន មេជាងរចនាខាងខ្ចុក ស្លាច ដែលជាអ្នកឯកទេសខាងធ្វើគ្រឿងអលង្ការ មានមកុដ-មុខ-កង-សង្វារ ។ ល ។ នៅប្រចាំវាំងរបាំព្រះរាជទ្រព្យ និងជាសាស្ត្រាចារ្យនៃសាលាវិចិត្រសិល្បៈ ។

www.budinst.gov.kh www.elibraryofcambodia.org

៣- លោក អ៊ឹម-ធុំ ជំណាន់ក្រោយ ជាអ្នកទទួលបន្ទុកគណៈកម្មការសិល្បៈនៅសមាគមអ្នកនិពន្ធខ្មែរ និងជាអ្នកចេះភ្លេងប្ដូណណាំង ពិណពាទ្យ ចាំមហោរី យ៉ាងពិតប្រាកដ ។

៤- លោក ញុង-សៀង អ្នកធ្វើការនៅពុទ្ធសាសនបណ្ឌិត្យយូរមកហើយ ជាអ្នកចេះចាំខាងកាព្យៈឃ្លាង ចំនុកចំនើដែលប្ដូណណាប់ច្រៀន ភ្ជាប់ស្មូត្រហូរហែមក ។

ទោះបីជាយើងប្រឹងខិតខំយ៉ាងណាក៏ដោយ ក៏យើងជឿថា ពុំទាន់បានត្រឹមត្រូវសព្វគ្រប់ទេ ហេតុនេះប្រសិនជាអស់លោក អ្នកណាបានជ្រាបពីពត៌មានខាងរបាំប្រជាប្រិយយើងយ៉ាងណា ៗ ទៅទៀត សូមមេត្តាផ្ញើពត៌មាននោះមកក្រុមជំនុំវិញ ដើម្បីបញ្ចូលថែម ឬកែប្រែសម្រួលក្នុងការបោះពុម្ពលើកក្រោយទៀត ព្រោះលើកនេះជាការស្រាវជ្រាវនៅឡើយ ។ ក្រុមជំនុំទំនៀមទំលាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ សូមថ្លែងអំណរគុណទុកជាមុន ។

ភ្នំពេញ ថ្ងៃទី ១៩ ឧសភា ព.ស ១៩៦៤

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

www.budinst.gov.kh www.elibraryofcambodia.org

# មាតិការឿង

| អត្ថបទ | ទំព័រ |
|---|---|
| សេចក្តីផ្តើម | ១ |
| ១– រឿងត្រុជិ | ៩ |
| ២– រឿងពាំស្នែងទន្សោង | ២២ |
| ៣– រឿងពាំគោះអង្រែ | ៥២ |
| ៤– រឿងពាំបុកអង្រែ | ៦៧ |
| ៥– រឿងពាំក្អោក | ៧៥ |
| ៦– រឿងយើគេ | ៨៩ |
| ៧– រឿងនៃយុំ | ១១២ |
| ៨– រឿងកន្តៃរ៉ៃ | ១២៥ |
| ៩– រឿងស្បូព្រ៉ែត្រ | ១៣៣ |
| ១០– រឿងពាំវ៉ង់ | ១៣៩ |

www.budinst.gov.kh www.elibraryofcambodia.org

# ១- របាំត្រុដិ

របាំត្រុដិ ជារបាំប្រជាប្រិយមួយបែប ដែលសព្វថ្ងៃនេះគេឃើញមាននៅតែក្នុងខេត្តសៀមរាប ហើយជួនកាលគេឃើញនៅខេត្តបាត់ដំបងខ្លះដែរ ត្រង់ភូមិភាគណាដែលនៅជាប់នឹងខេត្តសៀមរាបនោះឯង ។

របាំនេះ មានលេងតែនៅពេលបុណ្យចូលឆ្នាំខ្មែរប៉ុណ្ណោះដែលជាចាំបាច់ ព្រោះមានសេចក្ដីឲ្យការណ៍ជាច្រើន អំពីសមាជិកក្ដើយធ្ងន់នៃក្រុមជំនុំចំនៀមទម្លាប់យើងដែលនៅក្នុងខេត្តតាំងនោះថា របាំនេះគេលេងឡើងដើម្បីប្រសិទ្ធនូវសព្វសាធុការពរជូនដល់អ្នកស្រុកក្នុងឱកាសឆ្នាំថ្មី ។ អាស្រ័យហេតុនេះហើយ បានជាមានឈ្មោះថា “ត្រុដិ” ដែលជាពាក្យដើមមកពី ភាសាសំស្ក្រឹត ប្រែថា ផ្ដាច់ ឬ កាត់ផ្ដាច់ គឺសំដៅដល់ការផ្ដាច់ឆ្នាំ ឬការកាត់ផ្ដាច់ឆ្នាំចាស់ចូលទៅក្នុងឆ្នាំថ្មី ហើយដែលនៅមានជាប់នាមព្រះរាជពិធីមួយហៅថា “ត្រុស្តិសង្ក្រាន្ត”(១) ជាប់រហូតសព្វថ្ងៃ ។ ដូច្នេះឃើញថាឈ្មោះរបាំនេះបញ្ជាក់ថាសំរាប់ប្រគបឡើងនៅពេលដំណាច់ឆ្នាំនិមួយ ៗ មែន ៗ ប៉ុន្តែតាមទំលាប់របស់អ្នកស្រុក ជួនកាលគេមានលេងរបាំនេះនូវពេលប្រារព្ធពិធីសុំទឹកភ្លៀង នៅគ្រាដែលស្រុកទេសមានការរាំងរះជាច្រើនថ្ងៃខែម្ដងៗដែរ ។ មិនតែប៉ុណ្ណោះ មានពាក់មានខ្លះបាន

---

១. ពាក្យត្រុស្តិ ក្លាយមកពីពាក្យ ត្រុដិ ។

www.elibraryofcambodia.org

បញ្ជាក់ថា របាំនេះសេសសល់នៅជាមួយមនុស្សជាន់ដើមមួយពួកដែលរស់នៅលើទឹកដីសុវណ្ណភូមិចាស់ តាំងអំពីដែនដីនេះពុំទាន់ទទួលអារ្យធម៌ពីប្រទេសណានៅឡើយ គឺត្រកូលមនុស្សមួយពួកនៅក្នុងប្រទេសយើង ដែលអ្នកស្រុកហៅថា " សំរែ " សព្វថ្ងៃច្រើនរស់នៅក្នុងភូមិភាគខាងជើងបឹងទន្លេសាបនេះឯង ។ កាលពីជំនាន់បុរាណ វង់ត្រូវរបស់ជនជាតិសំរែនេះ បាននាំគ្នាទៅលេងថ្វាយព្រះកជានៅរៀងរាល់ពេលបុណ្យចូលឆ្នាំ ដើម្បីថ្វាយព្រះពរសួស្តីសិរីមង្គល ។ ហេតុនេះហើយ បានជាមានទំលាប់លេងតែនៅពេលចូលឆ្នាំរហូតដល់សព្វថ្ងៃ ហើយមាននៅតែក្នុងខេត្តសៀមរាបដែលនៅជិតរាជធានីចាស់តែប៉ុណ្ណោះ ។

រីឯប្រដាប់ប្រដា និងរបៀបលេងយ៉ាងណាៗ នោះយើងនឹងអធិប្បាយជូនដូចតទៅ ៖

## ១- អំពីប្រដាប់ប្រដា

តាមធម្មតារាំរបាំនេះ មានក្រុមតូចក្រុមធំ យោលទៅតាមការនិយមរបស់អ្នកស្រុក ទីងនិយមតាមចំនួនមនុស្សដែលស្ម័គ្រចិត្តចូលលេង ។ ឯប្រដាប់ប្រដាសោត គឺនិយមទៅតាមនោះដែរ ប៉ុន្តែយើងអាចរកមើលទាំងអស់ឲ្យឃើញថា តើវង់ត្រូវពេញលេញនោះ ប្រដាប់មានឈ្មោះអ្វីខ្លះ? គឺមាន ៖

www.budinst.gov.kh www.elibraryofcambodia.org

## ក– គ្រឿងភ្លេង .–

– កញ្ឆារ .– ផលធ្វើពីពនចង់ប្រវែង ២ ម. មានបន្ទះនាបតូចភ្ជាប់នៅចុង ហើយខ្វែងគ្នាពត់ជាទ្រនុំមានសណ្ឋានដូចស្នែង ៤ ។ នៅចុងបន្ទះនាបមានចងខ្សែខ្វែង ពីចុងមួយទៅចុងមួយ ហើយត្រង់កណ្ដាលខ្សែខ្វែងនេះ មានបន្ទោងផ្លែអង្គញ់ដែលបោះយកគ្រាប់ចេញអស់ ហើយដាក់គ្រាប់គ្រួស ឬគំរោចដែកទៅក្នុងនោះ ប្រយោជន៍ឲ្យឮសូរកាលណាគេបុកដងវាទីងដី តាមចង្វាក់ស្គរ ។



( សូមមើលរូបនេះ ) ។

កញ្ឆារ

– ចង្រ្កឹងដំបែ .– ចង្រ្កឹងចងបន្តោងទីងខ្សែតាមគោ ហើយចងភ្ជាប់ទីងដងឫស្សីដៃ ។ កាលណាគេបុកទីងដី ក៏មានសូរព្រាវ ៗ តាមចង្វាក់ ។

–ចង្រ្កឹងជើង.–ចង្រ្កឹងនេះចងព្យួរនឹងចង្កេះមនុស្សតែម្ដងដោយចងគួបគ្នាជាចង្កោម ១ផង ។

– ស្គរ.– ស្គរអារក្សគឺស្គរដែលធ្វើពីដីដុតពាសស្បែកថ្លាន់ ។

– ប៉ីពក(១).– (មានតែ ១ ប៉ុណ្ណោះ)

– ទ្រអ៊ូ-ទ្រសោ.– (ត្រូវមានទាំងពីរ)

–សន្ធូច.–ដងពីងពង់វែងមានសណ្ឋានដូចសន្ទូចចុងដូចបន្ទាល

រវេះដោយមានព្យួរចងមួយនៅចុងសំរាប់ទទួលវត្ថុជាតាន ។

១– គ្រឿងតែង.–

– មុខក្លាក – ធ្វើពីធ្លឹងឫស្សីពាសក្រដាស ឬ ស្លាប់ ឬ ខ្នុក ។

– មកុដ.–គេធ្វើពីក្រដាសលាបកាវទឹងបិទឲ្យក្រាស់តម្រួតគ្នា

ទៅជាវីងគឺស្លាប់ ឬ ខ្នុក ហើយផាត់ពណ៌ ។

–ស្នែងប្រើស.–គេយកផ្តៅមកព័ទ្ធធ្វើធ្លឹងហើយយកក្រដាសបិទ

ពីក្រៅឲ្យក្រាស់ ព័ទ្ធឲ្យមានរាងដូចស្នែងឬជួនកាលគេយក

ស្នែងប្រើសមែនទែន មកសិតភ្ជាប់ទងផ្តៅពាក់ឲ្យជាប់ នឹង

ក្បាលមនុស្សទៀតក៏មាន ។

– ស្នែងទន្សោង.– ស្នែងទន្សោងគេធ្វើប្រហែលគ្នានឹងស្នែង

ប្រើសដែរ គឺជួនគេយកស្នែងមែនទែនមកធ្វើ ជួនគេស្រោប

ក្រដាសឲ្យក្រាស់ ។

www.budinst.gov.kh www.elibraryofcambodia.org

- កន្ទុយក្ងោក.– យកកន្ទុយក្ងោកមែនទែនមកកាន់ ហើយ កាច់កែឲ្យមានសណ្ឋានដូចសត្វក្ងោកមែនទែន ។

- ក្រចក.– យកផ្តៅប្រវែង ០ម២០ ចិតចុងឲ្យស្រួច ពេលត្រូវពាក់ឲ្យជិត ហើយយកអម្បោះចងតល់ភ្ជាប់នឹងម្រាម ៤ ឯមេដៃ មិនពាក់ទេ ។



ស្នែងទន្សោង



ក្រចក

## ២–របៀបលេង

### ក– ក្រុមអ្នកពាក់មុខ ឬ ពាក់ស្នែង ·–

ពួកអ្នកពាក់មុខទាំងប៉ុន្មាន មានអ្នកពាក់មុខ ឬ លាបមុខខ្មៅ ធ្វើមនុស្សព្រៃ. អ្នកពាក់មុខខ្លះធ្វើជាព្រានព្រៃដែលដឹកកូលគេ.

មាត់ស៊ីរង្កាកស៊ីកឈើជុំវិញ ត្រចៀកស៊ីកបេកមកបង់ព័ទ្ធបង្កើះ លាបខ្លួនខ្មៅហើយស្លៀកប៉ុន ដោយមានស្លាយស្នាដង មាន កិរិយាមិនទីនជីនទេ ច្រើនរត់រេច្ចនរេស្តាំ ចេញក្រៅពីវង់ជានិច្ចគឺ ច្រើនតែរត់ទៅមុខគេ ។ ឯជនខ្លួនធ្វើដើកដោកយោលទៅតាម ចង្វាក់ស្គរ ដៃគ្រាន់តែពត់បន្តិចមិនពេញដាក់ទេ ។

ពួកអ្នកពាក់ស្នែងប្រើសទីងស្នែងទន្សោង គឺពាក់ក្បាលប្រហែល ព្រានទីងមនុស្សព្រៃដែរ គឺមានតែស្នែងនៅលើក្បាល មុខឥតមាន ពាក់អ្វីទេ ហើយដៃទាំងពីរជួនយកទៅកាន់ស្នែង ជួនចុះបង្អោន ខ្លួនហើយលូកដៃទាំងពីរទៅមុខមានទំនងដូចជាធ្វើដើងម្រឹគ ។ គេ រាំលោត ១ តាមចង្វាក់ស្គរ ផ្លៀងផ្លង់គមានសណ្ឋានដូចម្រឹគផ្អើល ម្ដង ១ ។ យូរ ១ ប្រើសទីងទន្សោងនេះ ធ្វើជារត់ចេញខាងក្រៅ វង់ម្ដង ១ ដែរ ។

កាលណាប្រើសទីងទន្សោងចេញពីវង់ហើយ, ព្រានព្រៃដែល កំពុងរត់រេច្ចាតាមមនុស្សទាំងអស់ ហើយយូរ ១ ម្ដងធ្វើជាទៅ ជន្ទួតនាងម្ដង ១ នោះ, គំរត់ដេញតាមបាញ់ម្រឹគទាំងនេះ ។ ទន្សោងដេញដល់ព្រានវិញ, ព្រានភ័យរត់ចេញគេដើមឈើឡើង គេចខ្លួន ។

w...inst.gov.kh www.elibraryofcambodia.org

## ១– ក្រុមតួរាំ.–

ក្រៅពីពួកអ្នកពាក់មុខ នៅមានតួរាំស្ត្រី ១ ជាតួឯកនិងជាតួនាងច្រើននាក់ទៀត ៖

– តួឯកពីរនាក់ ស្លៀកចងក្បិនពណ៌ ពាក់អាវពណ៌ ពាក់មកុដ ឬកញ្ចាំង ពាក់សង្វារ, មុខផាត់ម្សៅ ដៃកាន់កន្ទុយក្ងោក ។

– តួនាងពីរនាក់ទៀត មានសំលៀកបំពាក់ពណ៌ដូចតួឯកដែរ ប្លែកតែក្បាលពាក់ខែ ( ដូចខែគេពាក់ការពីបូរាណដែរតែតូចជាងនោះបន្តិច ), សំពត់សំឡូយ គ្មានសង្វារ ហើយបង់កន្សែងពណ៌សំយុង មុខផាត់ម្សៅ ។

តួអ្នករាំទាំងពីរគូនេះ មានក្បាច់ទន់ភ្លន់ជាងគេដោយមានឫកពាជាស្ត្រីក្រមុំអៀនអន់ក្រោយ ។

កាលណាចូលទៅដល់មុខផ្ទះណាមួយ ដែលរាំត្រុដិនេះត្រូវលេង, តួនាង និង តួឯក ត្រូវលុតជង្គង់ ឱនក្បាលលើកដៃប្រណម្យ យោលខ្លួនបន្តិច ៗ តាមសូរចង្វាក់ស្គរយ៉ាងទន់ខ្លួន ។ រួចហើយក្រោកឈរឡើងបន្ទន់ជើងស្តាំបក់ទៅមុខ ដៃឆ្វេងច្រត់ចង្កេះ ដៃស្តាំលាតហើយលូកទៅមុខ មានទំនងជាសុំនូវសប្បុរសទានអំពីម្ចាស់ផ្ទះ ។ រេឆ្វេង-ស្តាំបន្តិច ក៏ផ្លាស់ជើងឆ្វេងទៅមុខម្តង ប្តូរយកដៃ

ស្ដាំប្រត់បង្កើះវិញ ៗ ក្នុងពេលដែលគូទាំងនេះកំពុងរេកំយ៉ាន់ហ្នឹង អ្នកដទៃទៀតក្នុងវង់ត្រដិទាំងមូលត្រូវយោលខ្លួន ទៅតាមចង្វាក់ស្គររៀង ៗ ខ្លួន ប្លែកគ្នាតែអ្នកខ្លះខ្លាំងអ្នកខ្លះតិច តាមចរិតរបស់គូ ដែលមាននារីជាអ្នកកំប្លែង ឬជាអ្នកទឹងធឹងប៉ុណ្ណោះ ៗ ជួនកាលគូកំប្លែង ៗ មានដល់ទៅកៀកគ្នាក៏មាន ៗ

## គ- គូបន្ទាប់បន្សំដទៃទៀត .-

ក្រៅពីគូអ្នកពាក់មុខ និងគូអ្នករាំ , នៅមានគូបន្ទាប់បន្សំដទៃទៀតដូចជាគូអ្នកពាក់ក្រចក , អ្នកកាន់ដងសន្ទូច និងអ្នកកាន់គ្រឿងក្មេងជាដើម ៗ យើងលើកយកអ្នកមានមុខងារពិសេស ៗ ទាំងនេះមកអធិប្បាយដូចតទៅ ៖

ចំពោះអ្នកពាក់ក្រចកជាជំនួយក្នុងការច្រៀងផង និងការឲ្យចង្វាក់ជាមួយស្គរផង ព្រោះក្នុងពេលលេង អ្នកពាក់ក្រចកនេះជួយផ្ទាត់ក្រចករបស់ខ្លួនឲ្យឮស្នូរសៀងផង ៗ ហើយធេកធោកខ្លួនតាមចង្វាក់ជួយបង្កើនទស្សនិយភាពនៃវង់រាំនេះដែរ ៗ ចំណែកអ្នកកាន់ដងសន្ទូច ក៏ជាស្ត្រីអ្នករាំស្លៀកពាក់ស្អាតបាត (ជួនកាលគេឲ្យគូនាន់ប្រុសកាន់ក៏មាន) ៗ ដូច្នេះ នៅពេលដែលមានចង្វាក់ស្គរ

www.budinst.gov.kh www.elibraryofcambodia.org

LIBRARY BUDDHIST INSTITUTE

រន្ទឹន ៗ ព្រមជាមួយភ្លេងនិងចម្រៀងរាំ ៗ នោះ អ្នកកាន់ដងសន្ទូច ក៏រាំជាមួយគេដែរ ដៃម្ខាងកាន់ដងនេះ ដោយយកគល់មកចល់ទឹង ចង្កេះហើយលូកចុងដែលមានព្យួរថង់នោះ តម្រង់ទៅអ្នកម្ចាស់ផ្ទះ រៀបជារង់ចាំទទួលសប្បុរិសទាន ៗ

រីឯអ្នកភ្លេងទាំងប៉ុន្មាន បើសង្កេតចំពោះអ្នកផ្លុំប៉ី អ្នកគូសទ្រ អ្នកវាយស្គរ មិនឃើញមានភាពអ្វីប្លែកទេ យើងសង្កេតបានតែចំពោះ អ្នកបុកគញ្ជារ និងចង្រ្កង់ដំបែប៉ុណ្ណោះ ៗ អ្នកទាំងនេះពុំមានតាក់តែង ខ្លួនអ្វីឲ្យប្លែកធម្មតាឡើយ ៗ ដៃម្ខាងគេកាន់ដងគញ្ជារ ឬ ដងចង្រ្កង់ ដំបែបុកទៅនឹងដីប្រយោជន៍ឲ្យឮសូរធា ៗ រាំ ៗ ស្របជាមួយសំឡេង ស្គរនិងដៃម្ខាងទៀតយោលតាមចង្វាក់នោះ ជាមួយនឹងជង្គង់ខ្លួនផង ៗ ឯចំនួនអ្នកកាន់ដងគញ្ជារនិងចង្រ្កង់ដំបែនេះ ពុំមានកំណត់ទេតាម តែវង់ធំ ឬវង់តូច ប៉ុន្តែ បើយ៉ាងតិចណាស់គឺមួយមុខ ៗ ត្រូវមាន ពីរដែរ ៗ

ចំណែកចង្រ្កង់មួយយ៉ាងទៀត ដែលយើងហៅថា ចង្រ្កង់រ៉ូង នោះ ពុំមានអ្វីដោយឡែកទេ គឺពាក់ជាប់នឹងចង្កេះអ្នកលោតរាំមាន អ្នកពាក់ស្នែង ឬអ្នកពាក់ក្រចកដែលអធិប្បាយរួចស្រេចទៅហើយ ៗ

www.budinst.gov.kh www.elibraryofcambodia.org

ដូច្នេះ យើងអាចយល់បានថា វង់ត្រុដិ ត្រូវមានគ្នាជាមធ្យម ២៥ នាក់ ប៉ុន្តែគេអាចថែមថយបាន ស្រេចហើយតែលើមធ្យោបាយដែលគេអាចធ្វើទៅបាន ។

ក្រៅពីចំនួននេះ ក្នុងវង់ត្រុដិនិមួយៗ តែងតែមានអាចារ្យម្នាក់ ជាអ្នកនាំមុខ(១) ។ ចូលទៅផ្ទះនិមួយៗ តែងអាចារ្យចូលទៅជាមុន បើម្ចាស់ផ្ទះគេសុខចិត្តឲ្យលេង ទើបវង់ត្រុដិចូលទៅតាមក្រោយ តែបើអាចារ្យចូលទៅហើយ ម្ចាស់ផ្ទះបដិសេធវិញ អាចារ្យក៏នាំវង់ត្រុដិដើរហួសទៅទៀត ។ កាលបើបានប្រាក់ទានមកពីម្ចាស់ផ្ទះ ដោយគេដាក់ក្នុងថង់នៅចុងដងសន្ទូចក្តី ឬដោយគេបោច ហើយកូនត្រុដិនាំគ្នាប្រជែងរើសយកក្តី ក៏ត្រូវដាក់ទៅក្នុងថង់យាមដែលអាចារ្យនេះស្ពាយ ។ ព្រោះថា វិធីទទួលប្រាក់នេះ វង់ត្រុដិមានមធ្យោបាយច្រើនសុំ ដោយប្រើសំដីបញ្ចុតបញ្ចៀង



---

១ – កាលណាក្នុងពេលលេងត្រុដិសុំទឹកភ្លៀងវិញ អាចារ្យនេះគេហៅថា តាម្លោ ។ បើលេងតែប្រាក់ធ្វើបុណ្យ អាចារ្យមាន ៣ ឬ ៤ កាន់ផ្តិលដាក់ប្រាក់ទាន ។

www.budinst.gov.kh www.elibraryofcambodia.org

គោសរូសឲ្យគេយកជាប្រាក់ ឬ ជាសរសៃអំបោះដាក់ក្នុងថង់ ឬ មួយឲ្យម្ចាស់ពានបាចប្រាក់ពាននោះទៅនឹងដី រួចសឹមគេនាំគ្នារើស ដោយស្រែក "ជាត្រីច្រើនណាស់ៗ" នាំគ្នាកៀរឬជញ្ជាត់យក ៗ កាលណាកៀរឬជញ្ជាត់បានហើយ គេនាំគ្នាច្រៀនជូនពរដល់ម្ចាស់ផ្ទះវិញ ហើយប្រសិនជាម្ចាស់ផ្ទះមានចំណូលចូលចិត្តឲ្យត្រុដិលេងពាល់តែអស់ក្បាច់នោះ ដល់ចុងបំផុត តួព្រានព្រៃត្រូវធ្វើជាកៀងបាញ់ប្រើស ៗ ឯប្រើសត្រូវបែកចេញពីហ្វូងឲ្យពាល់តែព្រានព្រៃនោះបាញ់បាន គាត់ដកយកស្នែងទៅលក់ឲ្យម្ចាស់ផ្ទះ យកប្រាក់មកដាក់ថង់ម្ដងទៀត ៗ តាមទំនៀមខ្លះនិយាយថា កាលណាបើត្រុដិលេងនៅផ្ទះណាមួយហើយ ម្ចាស់ផ្ទះនោះពុំបានឲ្យពានជាប្រាក់ឬជាវត្ថុទេ ក្រុមត្រុដិត្រូវលើកយកជណ្ដើរផ្ទះនោះទៅ ត្រាតែម្ចាស់ផ្ទះយកប្រាក់ ឬ វត្ថុទៅលោះយកមកវិញ ៗ

## ៣- ទំនុកច្រៀង

តាមការពិនិត្យមើលហូរហែមក ទំនុកច្រៀនរបស់វង់ត្រុដិមិនមានសេចក្ដីដូចគ្នាទេ និយមទៅតាមក្រុមតាមពួក តាមភូមិស្រុក [illegible]

www.[illegible].gov.kh www.elibraryofcambodia.org

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ មានតែឯកសាររបស់សម្ដេចព្រះវន្ន័ត អ៊ុំ-ធួត មេគណខេត្តបាត់ដំបងមួយទេ ដែលមានពាក្យសេចក្ដីទំនុកច្រើនថែម ហើយទំនុកនិមួយៗ ចប់ចុងចប់ដើមផង ៗ រីឯឯក-សារដទៃទៀត ពោះបើជាមានប្រាប់ថាមានទំនុកដែលពាក្យសេចក្ដីខ្វែកពីគ្នាក៏ដោយ ក៏មានត្រឹមតែសេចក្ដីផ្ដើមទំនុក ឬ ពោះយកត្រង់កណ្ដាលទំនុកបន្តិចៗ ប៉ុណ្ណោះ ជាហេតុឲ្យយើងយកមកធ្វើការផ្ទៀងផ្ទឹមក្នុងទីនេះពុំបានសព្វគ្រប់ឡើយ ៗ ដូច្នេះ យើងយកតាមតែឯកសារសម្ដេចព្រះវន្ន័ត ដោយជ្រើសយកអត្ថខ្លះៗ និងយកពីឯកសារអស់លោកដទៃទៀតខ្លះមកធ្វើគំរូ ៗ មានហេតុមួយគួរសង្កេតថា ក្នុងបណ្ដាទំនុករបស់ឯកសារសម្ដេចព្រះវន្ន័តសុទ្ធតែមានជាកាព្យពាក្យ ៤ ព្យាង្គៗ ក្នុង មួយឃ្លា ឬមួយបាទ; ហើយមានបួនឃ្លាកាត់ចេញជាមួយល្បះឬ ១ គាថា ៗ ចំណែកឯកសាររបស់លោកដទៃខ្លះវិញ មានពាក្យ ៦ ព្យាង្គ មួយឃ្លា, ៤ ព្យាង្គៗ ពីរឃ្លា មានចំនួនប្រហែលកាព្យបទពំនោលខ្លះដែរ ៗ ចំពោះកាព្យជាទំនុកដែល

www.budinst.gov.kh www.elibraryofcambodia.org

មានបួន ៗ ព្យាង្គនោះ មានការចាប់ចុងចួនដូចតទៅ ៖

ព្យាង្គទី ៨ ផ្ទួនជាមួយព្យាង្គទី ១២; ឯព្យាង្គទី ១៤ នៅចុងនៃគាថានិមួយ ៗ ត្រូវយកទៅផ្ទួនជាមួយព្យាង្គទី ៨ នៃគាថាបន្ទាប់ ទៅទៀត មានចំនងដូចគំនូរនេះ ៖



ដើម្បីជាកស្តុតាង យើងសូមជូនសេចក្តីស្រង់ចំនុកតាំងនោះ ដូចតទៅ ៖

## ក- ច្រៀងនៅពេលទៅដល់ .-

– ខ្ញុំមកដល់ក្រៅ ស្រែកហៅសួរថ្កាន ព្រះបាទសូមបាន ចូលបាន ឬទេ ៗ (បន្ទរ) ឱណា៎ នាងណា៎ ចូលបានឬទេ ៗ

– តោះបានមិនបាន ចូរអ្នកបំណោរ ចូលបានឬទេ អ្នកឆាប់ប្រាយប្រាប់ (បន្ទរ) ឱណា៎ នាងណា៎ អ្នកឆាប់ប្រាយប្រាប់ ៗ

– អាដែងគ្នាយើង អាដែងគ្នាយើង ដែលគាត់ស៊ុដក្លីង ទទួលត្រុជិហើយ (បន្ទរ) ឱណា៎ នាងណា៎ ទទួលត្រុជិហើយ ៗ

– ខ្ញុំមកពីឆ្ងាយ ដល់ក្រៅរបង អង្គុះដំរឹង សេះអានចង្ក្រិន់ (បន្ទរ) ឱណា៎ នាងណា៎ សេះអានចង្ក្រិន់ ៗ

www.budinst.gov.kh www.elibraryofcambodia.org

– គនះយើងវាយរង់ គនះយើងវាយរង់ វាយឲ្យត្រូវខ្នង់ រង់ឲ្យរបេប

( បន្ទរ ) ទ ណាំ នាង ណាំ រង់ឲ្យរបេប ។

– សូមអើយសូមសព្វ សូមអើយសូមសព្វ សូមស្វាប្រអប់ ក្រមួន

មាត់ផង ( បន្ទរ ) ទ ណាំ នាង ណាំ ក្រមួនមាត់ផង ។

– សូមហើយសូមទៀត សូមហើយសូមទៀត សូមម្សៅរមៀត

ប្រេងក្រអូបផង ( បន្ទរ ) ទ ណាំ នាង ណាំ ប្រេងក្រអូបផង ។

– សូមចាំងម្ជូរបៀក សូមបារីបង ក្រមួនមាត់ផង ទឹកអប់ធ្វេងស្អាំ

( បន្ទរ ) ទ ណាំ នាង ណាំ ទឹកអប់ធ្វេងស្អាំ ។

– ធ្វើបុណ្យប្រាសាទព្រះ ជំរះវិហារ ធ្វើបុណ្យផងគ្នា លាបាបពីក្នុង

( បន្ទរ ) ទ ណាំ នាង ណាំ លាបាបពីក្នុង ។

– ទ្រើងត្រាក់ទ្រើងទ្រោល ទ្រើងត្រាក់ទ្រើងទ្រោល វាយរង់ប្រមូល

បណ្តូលរង់យើង ( បន្ទរ ) ទ ណាំ នាង ណាំ បណ្តូលរង់យើង ។

( បម្រៀងអ្នកស្រុកតាព្រាម តាមឯកសារ សម្តេចព្រះវនរ័ត អ៊ុំ-ធ្លូត )

– គ្រូជិះខ្ញុំដល់ហើយ ដល់ក្រៅបង រទេះគោផង សេះអមបង្ក្រិន ។

( បន្ទរ ) ទ ណាំ នាង ណាំ សេះអមបង្ក្រិន[១] ។

---

១- គ្រប់តែឃ្លា តែងបន្ទរថា « ទណាំនាងណាំ » និងបន្ថែមឃ្លាចុង ស្មូតឡើងវិញ ម្តងទៀត

www.budinst.gov.kh www.elibraryofcambodia.org

– ដើមចង់របង់ ដៃគង់សម្រាប់ បង្វិកកៅម្ចាស់ផ្ទះ លក់ហើយ ឬទៅ ៗ

– មើលោកសព្វព្រះច័យ អុជចន្លុះបង្ហាញផ្លូវ បែកតានខ្ញុំទៅ. យប់ជ្រៅណាស់ហើយ ៗ

– ឈរឈប់នៅក្រៅ ស្រែកហៅទៅថ្កាន ជំរាបសុំទាន ព្រះលានឈរលេង ៗ

– គ្នាខ្ញុំច្រើនណាស់ គ្រឹក ៗ គ្រេង ៗ ព្រះលានឈរលេង លេងបានទេណា ៗ

– ទោះបានមិនបាន ប្រាយប្រាប់ខ្ញុំពី លេងបានទេណា ខ្ញុំនឹងនាំគ្រុដើរទៅ ៗ

– លោកមិនអាណិត បែកតានឥឡូវ អគ្រាត្រយប់ជ្រៅ ខ្ញុំសោកណាស់ហើយ ៗ

( ទំនុកឆ្លកខេត្តសៀមរាប តាមឯកសារលោក មាស.យ៉ាំម
កាលធ្វើចៅហ្វាយស្រុក ៗ សូទ្រនិគម-សៀមរាប )

## ១– ច្រៀងនៅពេលសូមទាន .–

– គ្រុដនេះមិនគឺស្រុកអាយ គ្រុដនេះមិនគឺស្រុបអាយ គ្រុដលោកចៅហ្វាយ ច្រើនខ្ញុំមកលេង ៗ

www.budhist.gov.kh www.elibraryofcambodia.org

(បន្ទរ) ទណាំ នាងណាំ ប្រើខ្ញុំមកលេង(១) ។

– ផ្ទះធំចម្លាក់ៗ ជណ្ដើរកាំប្រាក់ សមគាត់មានបុណ្យ ។

(បន្ទរ) ទណាំនាងណាំ សារ៉ាមុំបង(២) ។

– នៃហើយកុំធោត នៃហើយកុំធោត ជញ្ជាំងស្លឹកត្នោត គង់មាន ថ្នាំខ្នាំង ។

– បានមួយបារី គង់មានកំឡាំង គាត់មានថ្នាំខ្នាំង មួរដាក់ជើង ពាន ។

– ក្របីស្នែងខប់ ស្នែងទប់ចង្ការ ក្របីនរណា ចូលហ្វូងយើង ហើយ ។

– ទន្សោងគោទប់ ទន្សោងគោទប់ ចេញស៊ីតែយប់ ថ្ងៃកពួនព្រៃ ។

– ទន្សោងទឡៃ ទន្សោងទឡៃ ទន្សោងចង្រៃ មិនបេះដល់គ្នា ។

– ទន្សោងគោបា ទន្សោងគោបា គេបានទឹកថ្លា ដល់គ្នាឲ្យមើល ។

– រមាំងតានអើយ ស៊ីកំពងទូង វាដេញដល់បង ដួលផ្កាប់ ដួលផ្ងារ ។

– រមាំងស្នែងកែក ស៊ីបែកពីហ្វូង រមាំងស្នែងស្រួច រត់ហ្វូង បែកខ្ចាយ ។

---

១-២- គ្រប់ពាក្យ តែងមានបន្ទរថា « ទណាំនាងណាំ » ដែលគ្មានពាក្យឃ្លាបន្ថែម ទៀតទៀត ឬក្នុងពេលមានថែមថា « សារ៉ាំមុំបង » ឬថា « គាក់ចិត្តណា សារ៉ាំមុំបង »

www.khmerlibrarycambodia.org

– កញ្ញារខ្ញុំដាច់ បានខ្សែត្បូង អំបោះមួយគំរង ចងដៃកញ្ញារ ។

– ខ្ញុំសុំទានប្រាក់ ខ្ញុំសុំទានប្រាក់ ផ្សឹតមានបុរៈ ធ្វើស្គរគេបែក ។

– បើអ្នកមិនជឿ ទៅមើលបំណែក ធ្វើស្គរគេបែក ឯលិច ស្វាយជ្រុំ ។

( ទំនុកភ្លេងសៀមរាប តាមឯកសារសម្ដេចព្រះវន្នរ័ត អ៊ុំ-ឆ្នូក )

## គ– ប្រៀងជញ្ជាត់ប្រាក់ដែលគេបាបទាន .–

– ខ្វះបិទខ្វះបាច ខ្វះសាចជញ្ជាត់ ការដងកុំមាត់ សម្ងំតាប់លុយ ។ (បន្ទរ) យ៉ាំងណោ ណោនាំងណា ណាណាតូនអើយ ។ (១)

– សញ៉ាំងញ៉ាំងអើយ សន្ទឹម(២)ដូចក្អុក ធៀងៗតែមុខ ដកកដូចគ្នា ។

– ពីដើមមិញអើយ ម៉េចអ្នកមិនថា ឥឡូវនេះណា ឆ្ងាយហើយណាអ្នក ។

– ជញ្ជាត់ជញ្ជូង ជញ្ជាត់ជញ្ជូង ជញ្ជាត់លេងៗ ក្រែងបានលុយកាក់ ។

– ជាន់ពើកជាន់ពាំង ជាន់ពើកជាន់ពាំង ជាន់ឲ្យខ្លាំងៗ ឲ្យត្រីចុលឈ្លាន ។

---

១– តាជា គេបត្តា ទៅ កុំត្រូវបក្អូនទួបៗ ផ្លាះនេះដែរ ។

www.budinst.gov.kh www.elibraryofcambodia.org

២– ពាក្យនេះហើយនៅថី [illegible]

- នើយត្រីអ៊ុយ(១) នេះត្រីអណ្ដែង អាណាញ់យកែង បញ្ចូល ដាក់ត្រក ។

- ញាតិអើយខ្ញុំលា ញាតិអើយខ្ញុំលា សព្វានមិនមា អស់ទាំងប្រុសស្រី ។

- លាទាំងក្មេងប្រុស លាទាំងក្មេងស្រី ខ្ញុំលាហើយនៃ ផ្ទះគេនៅច្រើន ។

( ចំនួនអ្នកសៀមរាប ឯកសារ[illegible] មាស-ហាំម )

## ឃ- ច្រៀងឲ្យពរដល់អ្នកដាក់ទាន .-

- គាវែងគ្នាយើង គាតស្បូត្រអំបោះ គាត់ឲ្យយើងអស់ យើងឲ្យពរគាត់ ។(២)

- ឲ្យយសឲ្យយ ឲ្យពរទៀនទាត់ ឲ្យបានសួលមាត់ កូនចៅផងក្ដី ។

- ឲ្យបានកូនប្រុស ជាមុខមន្ត្រី ឲ្យបានកូនស្រី ទំពកម្ចាក់ ។

- កាលកូនបេះផ្លែ បេះផ្សុលបេះប៉ាក់ ទេះខុកបេះដាក់ បំប៉ ម្ដាយស្រី ។

---

១- អុយ : អី ឬ អ៊ុំ ( សំឡេងអ្នកសៀមរាប ) ។

www.budinst.gov.kh www.elibraryofcambodia.org

– កាលកូនបេះផឹង បេះអំបេះស្លៃ បេះត្បាញរៀ

គោមគាត ៗ

– បានមាសដូចតាក់ បានប្រាក់ដូចគរ បានខ្ញុំកំដរ

ផ្ទួនស្ពាំ ៗ

– ផ្គរលាន់ឯត្បូង ក្រយូងបេកផ្កា អ្នកអើយខ្ញុំលា

ទៀត ៗ

( តាមឯកសារសម្តេចព្រះវនរ័ត

ចំពោះចម្រៀងដែលមានសេចក្តីទំនុកទាំងអស់នេ

បញ្ចេញសូរសំឡេងជាបំសណ្ឋានប្លែក ៗ គ្នា; នេះ ។

ទំលាប់អ្នកស្រុកតាគ្រាម ( ខេត្តបាត់ដំបង ) មកពន្យល់ៈ

បែបទី ១ ហៅថា " បទសណ្តឹង " ដែលមានសំ

វៃង ៗ តាមទម្លាប់ស្រុកគេចូលចិត្តអន្ទាយ ១ ៗ

បែបទី ២ ហៅថា " បទសន្ទូច " មានសាម្លេះ

រណោត់រលើនខ្ទះ ៗ

បែបទី ៣ ហៅថា " បទកញ្ចាញ់ចេក " ដែរ

www.budinst.gov.kh www.elibraryofcambodia.org

ពាបព្វ ១ សង់តែរតបទពាឃើញ ៗ

ក្នុងបណ្ដាទំទុកតាំងនេះ យើងដឹងថានៅមានប្លែកច្រើនទៅទៀត ព្រោះថាគំនិតអ្នកដែលនិយមរៀនតាមក្រុមតាមពួក មួយកន្លែង ១ តែងតែបន្ថែមបន្ថយខ្លះជាធម្មតា ៗ មួយយ៉ាងទៀត បើអ្នករៀននោះ ជាអ្នកកំប្លែងផង គេតែងក្រឡេកមើលឡេ ឃើញហេតុការណ៍អ្វីមួយនៅជិតខ្លួនគេ ហើយគេចាប់រៀនឡុក. ឡើយទៅរកគេឯងឬអ្វី ១ ដែលនៅជិតនោះ ឬមួយក៏ឡុកឡេម្ចាស់ផ្ទះតែម្ដងទៅក៏មាន ៗ ចំណែកអ្នកស្រុកសោតទៀត មានអ្នកខ្លះក៏ចូលចិត្តឲ្យក្រុមគ្រូដាំរៀនវែង ១ តាមបទដែលគេមានស្រាប់ អ្នកខ្លះទៀតចូលចិត្តឲ្យគ្រាន់តែគេផ្ដើមបន្តិចបន្តួចតែប៉ុណ្ណោះ ៗ

## ៤– អំពីទំនៀមថ្វាយគ្រូ

តាមទំនៀមដែលជាប់ជាដំនៀលហូរហែមកនៅស្រុកខ្លះថា មុននឹងចាប់ផ្ដើមសម័យលេងល្បែងគ្រូដាំនេះ គេមានទំនៀមមួយប្រកាន់ខ្ជាប់រៀងរាបមក គឺថាត្រូវរៀបណ្ដាប់ពលីការថ្វាយព្រះពិស្ណុការជាមុនសិន ទើបរាំគ្រូដាំនោះចេញលេងតាមស្រុកភូមិហូរហែទៅបាន ៗ បើលើកយកទំនៀមរបស់អ្នកស្រុកតាគ្រាមមកធ្វើជាមូលដ្ឋាន យើងឃើញពិធីរៀបថ្វាយព្រះពិស្ណុការមានដូចតទៅ ៖

cambodia.org

## ក- រណ្ដាប់ពលីការ .-

គេត្រូវធ្វើរានទេពតាជាបីថ្នាក់ នៅទីតាំងត្រង់ណាមួយ ដែលគេយល់ឃើញថាជាការគួរ គឺនៅចំទីធ្លាស្រឡះស្រឡំ មានគមនាគមន៍ងាយស្រួលសមាជិកក្រុមគ្រួសារ អាចមកជួបជុំគ្នាបានជួរ ៗ ឯប្រដាប់ដទៃទៀតមាន៖ បាយសីមួយគូ, ពែមួយ, ព្រមទាំងគ្រឿងសំអាងច្រើនទៀតមាន ៖ កញ្ចក់, ក្រាស, ម្សៅមៀត និង ស្លាបារី ។

ចំណែកការរៀបរៀបចំគ្រឿងពលីការទាំងនេះគឺ ៖ លើរានទេពតាថ្នាក់លើបំផុត គេដំកល់ស្លាធម៌, បាយសី, ក្រាស, កញ្ចក់ និងម្សៅមៀត ។ ថ្នាក់ទី ២ គឺថ្នាក់កណ្ដាល គេដំកល់តែ ដំមានករន្ទ្រាន់ដាក់បាយ ម្ហូប ចំណី និងទឹកមួយផ្តិលផង ។ នៅមាត់ផ្តិលនោះ មានអំបោះមួយកម្រងពាក់លើមាត់ផ្តិល ហើយចុងខ្វាន ភ្ជាប់ត្រាំទៅក្នុងទឹកផ្តិល ។ ថ្នាក់ក្រោមបង្អស់ ដម្កល់គ្រឿងប្រដាប់សំរាប់លេងភ្លេង គឺមានមុខស្លាប់, គ្រឿងភ្លេង និងអលង្ការដទៃទៀត ។

## ១- របៀបធ្វើ .-

ក្នុងពិធីអ្នកលេងភ្លេង គឺអ្នកលេងភ្លេងទាំងអស់មកជួបជុំគ្នា

www.budhist.gov.kh www.elibraryofcambodia.org

នៅចំពោះមុខគ្រឿងពលីការនេះ ៗ អ្នកកំភ្លូងកទីនតួនាងអង្គុយមួយជួរបែរមុខឆ្ពោះទៅកាន់ទេវតា ពួកភ្លេងអង្គុយមួយជួរខាងត្បូង, ពួកអ្នកកាន់ផងគញ្ជារ, ដងចង្ក្រង់ និងដងសន្ទូចអង្គុយមួយជួរខាងស្តាំ ឯលោកអាចារ្យអង្គុយនៅចំកណ្តាល ៗ ក្រោយពីអុជទៀនធុជធូប ដោតនៅស្លាធម៌បាយសី រួចស្រេចហើយ លោកអាចារ្យក៏នាំអ្នកទាំងអស់ថ្វាយបង្គំបីដងព្រមៗ គ្នាឆ្ពោះទៅកាន់ទេវតានោះៗ ថ្វាយបង្គំរួចស្រេចអ្នកទាំងអស់នាំគ្នាអង្គុយស្ងៀម លើកហត្ថប្រណម្យ ហើយលោកអាចារ្យ ប្រកាសបួងសួងឡើងថា ៖

« សូមអញ្ជើញលោកជាធំ មកជួបជុំសេពសោយក្រយា
ដែលពួកយើងខ្ញុំទាំងអស់គ្នា មកបូជាបន់បួងសួង ៗ
ទាំងលោកយាយលោកតាម៉ែឪ ពោះបីខុសត្រូវទោសទាំងពួង
ឲ្យបានរបួកផុតដោយបួងសួង សមដូចដួងចិត្តគិតប្រាថ្នា ៗ

ប្រកាសរួចអាចារ្យចាប់សែនតែ ហើយទើបយកអំបោះដែលត្រាំក្នុងផ្តិលទឹកមកចងដៃឲ្យពួកក្រុមគ្រួគ្រប់ ៗ គ្នា ៗ តមកអាចារ្យលើកមុខទីនស្នែងពាក់ឲ្យអ្នកលេងជាត្បូង ឬ តួប្រើស-ទន្សោង រួចដើរថយចេញពីវង់អង្គុយគោរពនោះ ៗ អ្នកទាំងអស់គ្នាក្រោកឈរស្មើគ្នា ហើយតួឯកចាប់ច្រៀងឡើងថា ៖

« ខ្ញុំសូមថ្វាយបង្គំ ហត្ថខ្ញុំប្រណម្យ ព្រះរតនត្រ័យ

www.budinst.gov.kh www.elibraryofcambodia.org

ឱព្រះគុណអើយ ព្រះរតនត្រ័យ សូមមានជោគជ័យ សេចក្ដីក្សេមក្សាន្ត ”

អ្នកទាំងអស់ទទួល បន្ទរព្រមគ្នាឡើងថា ៖

“ ឱ ណាំ យើណាំ សេចក្ដីក្សេមក្សាន្ត ”

បន្ទាប់ពីបញ្ចប់ពិធីពលីការថ្វាយគ្រូនេះរួចស្រេចហើយ ទើបវង់ត្រុដិចាប់ចេញទៅលេងនៅទីផ្សេង ៗ ។

មានទំនៀមមួយគួរកត់សំគាល់ថា នៅពេលជិតចូលឆ្នាំដែលត្រូវរៀបចំជាវង់ត្រុដិ នាងស្រី ៗ ណាដែលមានប្ដីហើយ ហើយបើចង់លេងត្រុដិដែរនោះ ត្រូវទៅសុំអនុញ្ញាតពីប្ដីសិន ។ ពេលទៅសុំត្រូវមានរៀបរណ្ដាប់ ស្លាម្លូ ៥ បារី ៥ ទៀន ៥ ធូប ៥ និងផ្កា ៥ ដាក់លើជើងពានកាន់ចូលទៅជូនប្ដី ហើយក្រាបសំពះស្វាមីថា ៖ “ ខ្ញុំសុំលាទៅលេងត្រុដិ ” ។ បើមានការគោរពប្រណិប័តន៍ត្រឹមត្រូវតាមក្បួនខ្នាតយ៉ាងនេះ ប្ដីត្រូវតែអនុញ្ញាតដោយខានមិនបាន ។

## ៥– អំពីដើមកំណើតត្រុដិ

ដូចយើងបានស្គាល់មកហើយនៅដើមបំផុតថា “ ត្រុដិ ” មកពីភាសាសំស្ក្រឹត ដែលមានន័យថា ៖ “ កាត់ផ្ដាច់ ឬថា ផ្ដាច់ឆ្នាំ ” ហេតុនេះហើយ បានជាគេទម្លាប់លេងរបាំនេះនៅតែពេលបុណ្យ

www.budinst.gov.kh www.elibraryofcambodia.org

ចូលតាំ ៗ ត្រង់នេះបង្ហាញបញ្ជាក់តែចំពោះពាក្យថា « គ្រុង » តែប៉ុណ្ណោះ មិននិយាយពីប្រវត្តិឬកំណើតរបាំប្រភេទនេះវិញ យើងរកឃើញប្រភពច្រើនបែបប្លែក ១ ទៀត ៖

## ក_ ប្រភពបែបរឿងនិទាន ._

ប្រភពនេះ មាននៅជាប់នឹងមាត់អ្នកស្រុកដែលនិទានតពីមាត់ទៅមាត់ ពុំអាចដេញរកដើមកំណើតចំផុតចេញពីនរណាមួយជាប្រាកដបានឡើយ ៗ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ យើងនៅតែយល់ថារឿងទាំងនេះ នឹងហុចប្រយោជន៍ឲ្យអ្នកស្រាវជ្រាវជាច្រើនក្នុងការសិក្សាធៀបផ្ទឹមអំពីបញ្ហានិមួយ ៗ ដែលទាក់ទងនឹងរបាំនេះ ៗ

រឿងទី_ ១

សេចក្ដីដំណាលថា មានត្រកូលអ្នកនេសាទម្នាក់ឈ្មោះប៊ុន ប្រពន្ធឈ្មោះនាង ខុមា ភូមិលំនៅ ៗ ជិតស្រុកសាវត្ថី និស្ស័យជាមនុស្សកាចឃើងរឹងរូស ៗ គាត់ជាមនុស្សកំសត់ទាល់ក្រ តែងតែដើរបោចញ៉ាំសត្វស្រមឹគបក្សី នេសាទតាំងផ្លូវទឹកតាំងផ្លូវគោក យកមកចិញ្ចឹមជីវិតរៀងរាល់ថ្ងៃ [illegible] គាត់រៀប

www.budinst.gov.kh www.elibraryofcambodia.org

ប្រដាប់ប្រដាធ្វើ ស្លា ប្រញាប់ចេក កាំបិតស្នៀតនិងគ្រឿងអ្វី ៗ ទៀតតាម ទម្លាប់ព្រាន ៗ នាងភរិយាក៏ចាត់ចែងម្ហូបចំណី បារីស្លាប្រគល់ឲ្យ ប្ដី ៗ ព្រានចេញដំណើរត្រាច់ផ្គាត់ កាត់ព្រៃលើងផងស្ទឹងឆ្ងាយ ទៅ ៗ ពុំមានប្រទះម្រឹគណាមួយសោះនាំឲ្យព្រានទើសចិត្ត ប្រហែល ជាអស់លោកទេវតាគេ លោកបំបិទបំបាំងបង្វែងអាងមិនឲ្យឃើញ ហើយ ៗ បើដូច្នោះព្រានក៏ចាត់ចែងធ្វើជាពានទេវតា ៣ ថ្នាក់ ដំកល់នូវប្រដាប់ប្រដាពលីការ សុំលាភសុំជ័យឲ្យបានជួបម្រឹគ ៗ បន្ទាប់ពីបួងសួងរួចហើយ ព្រានធ្វើដំណើរតទៅមុខទៀត ស្រាប់តែ ប្រទះប្រើសមាសមួយក្លិនឆ្អៅ គឺរោមសុទ្ធតែជាសរសៃមាស ស្នែង ជាកែវភ្លឺព្រាលរន្ទាល ៗ ព្រានត្រេកអរឥតឧបមា ពួនលបបំបាំង កាត្តាបាញ់បានប្រើសនោះហើយ មិច្ឆាយកកាំបិតព្រោះទៅកាត់យក ស្នែងពន្លះស្បែកម្ហូបផងជាមួយផង . អារសាច់ជាតចងប្រមូលវែក ដោយសេចក្ដីត្រេកអរដើរលែត្រឡប់មកផ្ទះវិញ ៗ មកដល់ហើយ ដោយឃើញថា ប្រើសនេះល្អណាស់ក៏នាំយកស្បែកនិងស្នែងទៅ ថ្វាយស្ដេច ៗ ព្រះបាទព្រហ្មទត្តទ្រង់យល់ក៏ទ្រង់សព្វព្រះរាជហឫទ័យ ទើបប្រទានយសដល់នាយព្រានជាចៅហ្វាយខេត្ត ៗ ចាប់ពីថ្ងៃនោះ មកព្រានប៊ុនឡើងយសជាចៅហ្វាយខេត្ត នាងឧមាជាជំទាវ ហើយ

www.budinst.gov.kh www.elibraryofcambodia.org

ក៏បង្កឲ្យមានក្រុមរបាំមួយនិទានពីព្រានដើរបរបាញ់ម្រឹគ ដូចមានការរៀបចំក្នុងវាំងក្រុងសព្វថ្ងៃនេះ ។

( តាមឯកសារសម្ដេចព្រះវន្ន័ត អ៊ុំ-ឡូត )

រឿងទី ២ ៖

មានសេចក្ដីដំណាលមួយទៀតថា របាំត្រុដិនេះ កើតឡើងតាមហេតុគេ ដែលមានឡើងនៅសម័យដែលព្រះសម្មាសម្ពុទ្ធនៅជាពោធិសត្វ មុននឹងត្រាស់ដឹង ព្រះអង្គទ្រង់ចេញសាងបព្វជ្ជា ។ ពេលនោះ មារាធិរាជបានជំណែងក្លែងខ្លួនជាសត្វប្រើស មកករាំងស្កាត់ផ្លូវព្រះអង្គកុំឲ្យព្រះអង្គយាងទៅមុខបាន ។ ព្រះពោធិសត្វទ្រង់តាំងអធិដ្ឋានឡើងក៏ក្ដៅដល់ទេវលោកមួយរំពេច ព្រះព្រហ្ម ព្រះឥន្ទ ទេវតាទាំងឡាយចុះមក ជំណែងគេជាអ្នកលបបាញ់ប្រើសដែលជាមារាធិរាជក្លែងគេនោះស្លាប់បង់ទៅ(១) ។ រួចហើយពពួកទេវតាទាំងអស់នេះ ក៏នាំគ្នាដង្ហែព្រះអង្គឆ្លងស្ទឹងអនោមា ទៅសាងព្រះផ្នួសសំរេចព្រះបំណងទៅ ដោយមានភ្លេងមហោស្រពធំតាមដងផ្លូវផងៗ

ដូច្នេះ បានជាគេយករឿងនោះមកសាងជារបាំត្រុដិឡើង គឺដង

១— រឿងបែបនេះ ពុំឃើញមានក្នុងពុទ្ធប្បវត្តិនេះ ។

www.budinst.gov.kh www.elibraryofcambodia.org

កញ្ចារ ជាឆ័ត្រ ឬ ជាគូសបើកបាំងព្រះពោធិសត្វ , ពួកភូតជាទេវតា , ឯនាគរាជាទេពអប្សរហាម , ប្រើសទន្សោងជាមារ និង ព្រាន-មនុស្សព្រៃ ជាពោះទេពកាកឡា ។

តាមឯកសារលោក ស៊ុ កា មេភូមិគោកប្រសាំង ( សៀមរាប )

## ១– ប្រភពបែបជំនឿអ្នកស្រុក .–

តាមសេចក្តីឲ្យការណ៍ពីលោក ឡុង-សាង នៅបាត់ដំបងថា គេលេងរបាំនេះ ដោយមានជំនឿថា នៅតាមស្រុកជិតឆ្ងាយ យូរៗម្តង រមែងមានសត្វព្រៃចូលមកក្នុងភូមិអ្នកស្រុក ។ បើប្រសិនណាជាមានសត្វព្រៃចូលស្រុកហើយ ទីនឹងកើតឧបទ្រពចង្រៃបែបណាមួយជាមិនខាន ។ ហេតុនេះបានជាមានទម្លាប់ថា បើឃើញសត្វព្រៃចូលស្រុកកាលណា គេនាំគ្នាប្រោះព្រំប្រេងម្សៅឲ្យសត្វនោះ ហើយសុំពរសុំជ័យពីសត្វទាំងនោះវិញ ។ ដើម្បីកេទុកាសបង្អាក់ប្រសិទ្ធចំពោះសត្វព្រៃឲ្យហើយស្រេចក្នុងមួយឆ្នាំៗ យ៉ាងនេះហើយបានជាអ្នកស្រុកដែលមានជំនឿដូច្នេះ ក៏បង្កើតល្បែងត្រុដិនេះឡើង ។ ហេតុនេះវង់ត្រុដិត្រូវមានប្រើស, ទន្សោង, ក្ងោក, សុទ្ធសឹងជាសត្វព្រៃ មកបង្ហាញខ្លួនឲ្យអ្នកស្រុកអកកម្មប្រោះព្រំប្រេងម្សៅចងដៃគាំបោះគម្រង

www.budinst.gov.kh www.elibraryofcambodia.org

ឲ្យបានជាលុយកាក់ទៅធ្វើបុណ្យ រំដោះគ្រោះឲ្យស្រេចហើយតែម្តងទៅ ដោយមានជំនឿថា ប្រសិនជាមានសត្វព្រៃចូលមកក្នុងស្រុកទៅថ្ងៃមុខទៀត ក៏គេបានប្រកបពិធីនេះ រួចស្រេចទៅហើយដែរ; ដូច្នេះ គេជឿថាគ្មានចង្រៃឧបទ្រពអ្វីអាចមានកើតឡើងទៀតទេ ។

តាមមតិអ្នកស្រី ហ្គ-ប៉ូរេ សរសេរចុះក្នុង ទស្សនាវដ្ដីបារាំង·អាស៊ី (France-Asie) លេខពិសេសស្តីពីអារ្យធម៌ខ្មែរ ចេញក្នុង គ.ស. ១៩៤៩ បានហុចហេតុផលមួយទៀតថា ៖ របាំត្រុដិដែលនិយមកន្ទុយក្អែក ដោយហេតុជនជាតិអាស៊ីយើងនិយមទុកសត្វនេះ ជាតំណាងព្រះអាទិត្យ ដែលជំនឿជាន់ដើមទុកជាអាទិទេពមួយដែរ ។ មនុស្សយើងត្រូវការបន់ស្រន់ចំពោះព្រះអាទិត្យ ឲ្យធ្វើអំ·ណោយទឹកភ្លៀងគ្រប់គ្រាន់សំរាប់ធ្វើស្រែចំការ ។ ហេតុនេះ បានជាកាលណាគ្មានភ្លៀងគេលេងត្រុដិសុំភ្លៀង ឯត្រុដិលេងនៅពេលចូលឆ្នាំផង ព្រោះគេលេងថ្វាយព្រះអាទិត្យអង្វរករឲ្យហើយស្រេចតាំងពីដើមឆ្នាំនេះទៅ ដូចគ្នានឹងទំលាប់ជនជាតិចិនហែក្បាលតោហែនាគនៅក្នុងពេលចូលឆ្នាំដូច្នោះដែរ ។

www.elibraryofcambodia.org

## គ- ប្រភពអ្នកស្រាវជ្រាវ .–

ចំពោះមតិដែលផ្អែកទៅលើគំនិតស្រាវជ្រាវនោះ ក្នុងបណ្ដាអត្ថបទជាឯកសារដែលមាននៅក្នុងក្រុមជំនុំទំនៀមទម្លាប់ មានឯកសារលោក មាស-បាំម កាលធ្វើជាចៅហ្វាយស្រុកនៅស្រុកសូទ្រនិគម លោកបានសរសេរឲ្យការណ៍ថា " លោកបានស៊ើបសួររកដើមកំណើតនៃត្រុដិនេះ ពុំមានរឿងរ៉ាវច្បាស់លាស់សោះ មានតែគ្រូត្រុដិម្នាក់បាននិយាយថា ត្រុដិជារបាំរបស់សាសន៍សំរែ ដែលជាជនជាតិដើមមួយរស់នៅលើទឹកដីយើងពីបុរាណមក; ធ្លាប់នាំគ្នាលេងថ្វាយព្រះរាជាខ្មែរយើងកាលគ្រាព្រះអង្គគង់នៅអង្គរវត្ត ។ ហេតុនេះហើយ បានជារបៀបរាំត្រុដិនេះ នៅសល់តែក្នុងខេត្តសៀមរាបដែលនៅជិតកន្លងទីតាំងរបស់យើង ។

ដូចយើងបានដកពោលម្ដងហើយខាងដើមបំផុតថា របាំនេះជាសិល្បៈកេរ្ដិ៍ដំណែលសេសសល់ពីមនុស្សដើមពិតមែន ដូចលោក ហា.ម៉ាកហ្សាល់(១) បានបញ្ជាក់ក្នុងអត្ថបទមួយថា កាលពីរវាង ១០ ឆ្នាំ មុនពេលលោកសរសេរអត្ថបទនោះ គឺរវាងឆ្នាំ ១៩២០ លោកបានឃើញពួកអ្នកលេងត្រុដិមកពីភូមិភាគភ្នំគូលែន សុទ្ធសឹង

១– H. Marchal, Note sur la Danse dite Leng Trot. Bulletin de la Sté des Etudes Ind, No Sp., IX, 3 (1934), pp. 87–90.

ជាជនជាតិសំរែ ។ លោក ម៉ាកា ហ្គ្រាល់ បញ្ជាក់ទៀតថា សព្វថ្ងៃជនជាតិសំរែទាំងនោះ បានរលាយចូលក្នុងជនជាតិខ្មែរ ដែលរស់នៅជិតខាងអង្គរវត្តអស់ទៅហើយ ។

លោក រ.បារាដាត៍(១) ជាតិបារាំងសេសបានធ្វើការសង្កេតល្អិតល្អន់ អំពីជនជាតិសំរែ-ជាតិព័រ ព្រោះលោកបានទៅរស់នៅជាមួយពួកនេះអស់រយៈវេលាយ៉ាងយូរ ត្រាតែចេះពាក្យសំរែយកមកធ្វើជាសព្ទានុក្រមពាក្យសំរែ ប្រែជាបារាំងបាន ។ លោកសរសេរបញ្ជាក់ត្រង់វគ្គនិយាយពីចំរៀងនិងរបាំជនជាតិសំរែថា " មានរបាំមួយ ដែលក្លាយមកជាត្រុដិសព្វថ្ងៃ តែរបាំនេះ ជំនាន់ដើមនោះពុំមានស្ត្រី ៗ ចូលរាំជាមួយផងទេ គឺមានសុទ្ធតែប្រុស ៗ ទាំងអស់ សឹងមានសេសសល់របៀបនេះ នៅនឹងពួកខ្មែរនៅឯស្រុកសុរិន្ទប្រទេសសៀមសព្វថ្ងៃ(២) និយម រហូតមកដល់សព្វថ្ងៃនេះ " ។

ប្រមូលយោបល់ទាំងអស់នេះមក យើងអាចសន្និដ្ឋានបានថា របាំនេះកើតមានឡើងពីជនជាតិសំរែ ដែលជាជាតិដើមមួយផ្នែកនៅ

---

១– R-BARADAT, BEFEO T.XLI, 1941 pp 94—96.

២ ហេតុនេះ បានជាត្រុដិស្រុកសុរិន្ទចាប់ច្រៀងឡើងថា « ត្រុដិនេះមិនមែនស្រុកអាយ ត្រុដិលោកហៅហ្លាយ ឲ្យយើងមកលេង » ។ ច្រៀងជាពាក្យខ្មែរនិងឡេះឡូច ទើបចាប់បន្តពាក្យសៀមតទៅទៀត ។

www.budinst.gov.kh www.elibraryofcambodia.org

លើទឹកដីយើង តាំងពីមុនដែលខ្មែររួបរួមគ្នាបានជាសញ្ជាតិមួយនោះទៅទៀត ។ ចំណេរកាលមក ការប្រធម៌នេះពុំបានលោយអស់ទៅឡើយទេ ក៏ធ្លាក់មកជាមត៌កដល់ជនជាតិយើងរហូតគ្រាសព្វថ្ងៃ ។ ចំណុចនេះ នាំឲ្យអ្នកស្រាវជ្រាវនឹកគិតដល់មនុស្សជំនាន់ដើមដែលមានរបរគេស៊ីតែជាមួយសត្វធាតុមានម្រឹគបក្សីជាដើម ឯសិល្បៈមនុស្សសម័យនោះ ក៏ប្រឌិតយកលំនាំសត្វធាតុជាផលរបរខ្លួនដែរ ដូចជារបាំពំពាក់ស្នែង រាំសៀតកន្ទុយឬរោមសត្វជាដើម ដែលគេឃើញមាននៅគ្រប់ដំបន់ទ្វីបនានា មានអាស៊ី, អាមេរិក, អឺរុប, អាហ្វ្រិក និង អូស្សាលី ។ ក្រោយពីផ្តើមបង្កើតបានជាសិល្បៈតាំងនោះហើយ មនុស្សនៅតាមភូមិភាគនោះ ៗ រមែងតែយកជំនឿ, យកទំនៀមទម្លាប់ខ្លួនទៅភ្ជាប់ ហើយធ្វើរបាំសិល្បៈនោះឯងឲ្យមានបែបផែនជាសណ្ឋានផ្សេង ៗ ឡើង តាមការនិយមចូលចិត្ត តាមការឲ្យតម្លៃរបស់ខ្លួនប្លែក ៗ ពីគ្នា ។

ហេតុនេះហើយ បានជាយើងឃើញមានរឿងនិទានខ្លះនិងជំនឿច្រើនបែបពាក់ទងជាមួយនឹងរបាំតាំងនេះ ហើយជ្រាបចូលជាប់ទៅក្នុងគំនិតអ្នកស្រុកយើងជាយូរអង្វែងមកហើយផង ។

www.budinst.gov.kh www.elibraryofcambodia.org

# ៦- វត្ថុបំណងនៃរបាំត្រុដិ

តាមជំនឿ និងតាមទម្លាប់អ្នកស្រុក ដូចមានអធិប្បាយមក ហើយក្នុងវគ្គមុនៗ យើងឃើញថារបាំត្រុដិមានបំណងតម្រូវតាមការចូលចិត្តរបស់អ្នកស្រុកប៉ុណ្ណោះឯងៗ ប៉ុន្តែបើយើងសង្កេតតាមទម្លាប់បច្ចុប្បន្នវិញ យើងសង្កេតឃើញអ្នកស្រុកអ្នកភូមិយករបាំនេះធ្វើជាមធ្យោបាយជួយសំរាលដល់សេចក្តីត្រូវការជាច្រើនខាងគ្រឿងសម្ភារៈបូជាចំពោះសាសនា និងផលប្រយោជន៍សាធារណៈ ។

អាស្រ័យលើគោលបំណងនេះ បានជាពួកអ្នកលេងត្រុដិគ្រប់គ្នាពុំដែលយកប្រយោជន៍ផ្ទាល់ខ្លួនទេ ។ ប្រសិនជាគេដាក់ទានឲ្យជាម្ហូបអាហារ នោះទើបបានអាស្រ័យខ្លះ; បើគេឲ្យជាលុយកាក់វិញ វង់ត្រុដិត្រូវតែយកទៅដាក់គល់សំរាប់វត្តអារាមណាមួយដែលនៅខាងភូមិខ្លួន សំរាប់ជួយក្នុងការកសាង ឬជួសជុលព្រះវិហារ, កុដិ សាលា ឬកំពែង តាមតែត្រូវការ ។ ប្រសិនជាវេរប្រគេនសង្ឃជាទ្រព្យវត្តរួចហើយ នៅតែសេសសល់ប្រាក់កាសទៀត នោះគេត្រូវតែធ្វើបុណ្យបន្តទៅទៀត ដូចជានិមន្តលោកឆាន់ ឬដារភ្នងជាដើម ។ ក្រៅពីពេលចូលឆ្នាំ ដែលជារដូវលេងត្រុដិ ពួកសមាជិកត្រុដិទាំងអស់ប្រកបរបរធម្មតារៀងៗខ្លួន ពុំបានយកសិល្បៈត្រុដិ

www.elibraryofcambodia.org

ធ្វើជាអាជីវកម្មប្រចាំកាត្តាខេ ។

ហេតុនេះ យើងគេឃើញបានថា បំណងសំខាន់របស់គ្រូជ គឺ ៖

១- គេក្រកើតមតិកសិល្បៈមួយបែបនេះដែលយើងមានពីបុរាណ យូរមកហើយ កុំឲ្យបាត់ងានដំណែលវប្បធម៌ចាស់ ដែលកើតឡើងពិតប្រាកដនៅលើដីស្រុកយើង ។

២ - ដើម្បីជួយជាប្រយោជន៍សាធារណ មានគេសាងទីកន្លែងធ្វើបុណ្យទាន និងទម្លាប់ឲ្យអ្នកស្រុកមានសប្បុរសធម៌ ចេះធ្វើបុណ្យឲ្យទាន ។

www.budinst.gov.kh www.elibraryofcambodia.org

# ២_ របាំស្នែងទន្សោង

នៅតាមស្រុកក្នុងព្រះរាជាណាចក្រជាពិសេសភូមិភាគដែលស្ថិតនៅត្រើយខាងត្បូងទន្លេសាប គេឃើញមានសេសសល់របាំប្រជាប្រិយមួយបែបដែលអ្នកស្រុកសន្មតហៅរត់មាត់ថា "រាំស្នែងទន្សោង" ។ សព្វថ្ងៃឃើញមាននៅតាមខេត្តកំពង់ឆ្នាំង, កំពង់ស្ពឺ និង ពោធិសាត់ ។ បានជាឈ្មោះថា "រាំស្នែងទន្សោង" ព្រោះរបៀបរាំនេះ អាស្រ័យដោយស្នែងទន្សោងនិងមានក្បាច់គ្រប់តាមកាយវិការទន្សោង ។

ដើម្បីនឹងជូនអ្នកអានឲ្យបានយល់ច្បាស់អំពីរបាំប្រជាប្រិយនេះ យើងសូមធ្វើជាសេចក្តីរាប់រៀបលំអិតបន្តិចដូចតទៅ ៖

## ១– អំពីប្រដាប់ប្រដា.

### ក– គ្រឿងភ្លេង .–

ប្រដាប់តន្ត្រីសម្រាប់ប្រគំជាមួយរបាំនេះមានតិចណាស់ គឺមានតែស្គរ ២ ពួយ ១ និង កញ្ចារ ១ ប៉ុណ្ណោះ ។

www.budinst.gov.kh www.elibraryofcambodia.org

ស្គរ.— ស្គរនេះធ្វើពីឈើធ្នង់ គឺលុងឈើនោះឲ្យស្អាតនៅសល់តែ





សាច់ខាងក្រៅស្តើង ល្មមគេពាសស្បែក គោ ដែលហាលស្ងួត ស្ងាប់សាច់ហើយ ។ ឯអន្ទង់សម្រាប់វាយ ស្គរនេះ គេយកគល់ព្រេចស្ងួតមកកាត់ល្មមឲ្យស្រួលកាន់វាយ ។

កញ្ឆារ.— ដូចកញ្ឆារគ្រូដៃដែរ គឺយកដងឫស្សីប្រវែងពីរម៉ែត្រមកធ្វើ ហើយខាងចុងមានពក់បន្ទះឫស្សីបិតស្តើងជាដងផ្ទួនខ្ទងគ្នា· និងព្យួរគ្រាប់អង្កាញ់នៅកណ្តាលសំរាប់បុកឲ្យឮសូរ ។

ពួយ.— ដែលហៅថាពួយនេះ គឺជាប្រដាប់ផ្លុំជាសូរសំនៀងពិរោះដូចខ្លុយដែរ តែពួយធំជាង ។ គេធ្វើពួយពីសំបកឃ្លោកមូលដោយបញ្ចាំភ្ជាប់ចុងឫស្សីពកប្រាំគង់ទីងឃ្លោកនោះ សំរាប់ដាក់អណ្តាតបញ្ចេញខ្យល់ ហើយគេផ្ចុំសំបកឃ្លោកតាមចុងឫស្សីពកមួយទៀតដែលបន្តមកម្ខាង ឲ្យខ្យល់តែចេញតាមរន្ធទាំង ៥ ដោយយកម្រាមដៃ បុចបិទបើករន្ធទាំងនោះ ឲ្យមានសព្ទសូរថ្លែកដាច់ទៅបែបឡើងមានសណ្តានប្រហែលគេផ្លុំនែននៅស្រុកលាវ ។

www.bunhisgov.kh www.libraryofcambodia.org

## ១- គ្រឿងតែង .-

ចំពោះគ្រឿងតែងកាយនៃអ្នករបាំនេះវិញ ពុំមានអ្វីជាពិបាកទេ



ព្រោះពីដើម គេពុំបាច់លំអរសោះ តែឥឡូវគេស្លៀកពាក់តាមទម្លាប់ខ្មែរអ្នកស្រុកសាមញ្ញ នៅតាមជនបទ គឺស្លៀកសំពត់ចងក្បិនពាក់អាវកម្មូលដៃខ្លី មានក្រមាបង់-ក បើជាមនុស្សស្រី និងមានក្រមាក្រវាត់ចង្កេះ បើជាបុរស ៗ ឯប្រដាប់ប្លែក នោះមានតែស្នែងទន្សោងពីរ គឺស្នែងទន្សោងមែនទែនយកមកចងភ្ជាប់នឹងផ្តៅដែលពត់ជាវង់មូលល្មមពាក់ជាប់នឹងក្បាលមនុស្សកើត ៗ ជួនកាលបើគ្មានស្នែងមែនទែនទេ គេយកផ្តៅពត់ឲ្យមានសណ្ឋានជាស្នែងទន្សោងក៏បាន ៗ កន្ទុយក្ងោកវែងៗចងក្រងតម្រៀបគ្នា ហើយមានខ្សែក្រមួនទៅក្រោយចងភ្ជាប់នឹងក្បាលមនុស្ស ៗ អត

www.budinst.gov.kh www.elibraryofcambodia.org

ពាក់ស្នែងមានពីរនាក់ ៗ ក្បាលសេះពីរទៀត គេធ្វើពីក្រដាសខ្មុក សំរាប់ស៊កពីលើក្បាលមនុស្សឲ្យល្មមតែជាប់បាន ៗ

## ២- អំពីរបៀបលេង

អ្នកលេងរបាំនេះមាន ១៦ នាក់(១) មានប្រុសមានស្រី(២) គឺកាន់គ្រឿងភ្លេង ៣ នាក់, ពាក់ស្នែងទន្សោង ៦ នាក់, ពាក់ក្បាលសេះ ២ នាក់, ពាក់គន្ធយក្ស ២ នាក់, អ្នកច្រៀង ២ នាក់ និងអ្នកបុកកញ្ឆាម្នាក់គេហៅ “មេជាគ្រូ” ។ របៀបចេញរាំមានដូចតទៅ ៖

អ្នកវាយស្គរ ចាប់វាយស្គរឡើងមុនគេលេងបីបទសំរាប់ឲ្យអ្នករាំទាំងអស់គ្នា បង្អោនកាយលើកដៃប្រណម្យថ្វាយបង្គំគ្រូ ៗ រួចហើយ ពួកក៏ចាប់ផ្ដុំឡើងស្របជាមួយស្គរ ដែលប្ដូរមកជាចង្វាក់

---

១– ចំនួន១៦តាមឯកសាររបស់លោក វ. ប៉ាកាត់ និងតាមការចងចាំរបស់លោកទេពញ៉ា ភរិយាឧក្ញ៉ាលតាងហ្វាងក្រុមគេដេរនៅព្រះបរមរាជវាំង បើតាមឯកសារទីចាត់ការសិល្បៈថាមានតែ ៦ នាក់ទេ ។

២– ត្រង់ថាមានស្ត្រីកំនេះ តាមឯកសាររបស់ទីចាត់ការសិល្បៈ ដែលបានទៅមើលឃើញនៅភូមិអញ្ចាញរូង ( កំពង់ឆ្នាំង ) តែឯកសារលោក វ. ប៉ាកាត់ក្នុង BEFEO វិញ ថាប្រុសទាំងអស់ សុទ្ធតែជាមនុស្សពេញវ័យហើយមានចំនួនមនុស្សច្រើន ដូចជាមានថែមអ្នកពាក់គន្ធយក្សនិងក្បាលសេះ ។

gov.kh www.elibraryofcambodia.org

រង្វើល ៗ វិញ ។ អ្នកផ្លុំព្រួយនេះ ផ្លុំផង រាំផង គឺរាំជំរុំបួនគ្រាន់តែ
យោលខ្លួនតិច ៗ របៀបនេះជាចង្វាក់គាន់តែញាប់ឡើង ៗ រហូត
បានទៅជាកាយវិការព្រានព្រៃម្នាក់យ៉ាងស្វាហាប់ ដោយមានបំបះ
ចុងព្រួយផ្សៀតផ្លូង ទំនងជាព្រានរករម្រឹគ និងមានទឹកមុខមាំ
ហាក់ដូចកាចសាហាវណាស់ ។

បន្ទាប់មកអ្នកពាក់ស្នែងទន្សោងចាប់ចេញរាំ ធ្វើកាយវិការគ្រប់
ដំណើរសត្វទន្សោង ប្រកបដោយក្បាច់ទន់ភ្លន់ក្រៃក្រាយ ហើយ
ប្រកៀកគ្នា រេចុះរេឡើង ។

ឯអ្នកច្រៀងក៏បើកបទ កាន់ធូបមួយសរសៃ ចាប់ចេញរាំចាក់
ក្បាច់រើតរំពើនតាមចង្វាក់ភ្លេង ហើយច្រៀងឮគ្រេង កប់រៀបពី
ចលនានៃសត្វទន្សោង ម្នាក់ពីមុខ ម្នាក់ទៀតរាំពីក្រោយ ជួយ
ស្រែកបន្ទរតាមបទ ។

អ្នកធ្វើជាក្ងោក ឬ ជាសេះ អ្នកនោះត្រូវចេញមកបន្ទាប់ពី
ទន្សោង ហើយធ្វើកាយវិការប្រហែលទន្សោងដែរ ។ ឯអ្នកច្រៀង
នេះពិតមែនតែមិនដើរចេញ តែក៏ជួយរាំ រេខ្លួនដែរ ។

ដូច្នេះ ឃើញថាអ្នកលេងប៉ុន្មានអស់ សុទ្ធតែនាដការទាំង
... ឯរបៀបធ្វើជាឈុត

www.budinst.gov.kh www.elibraryofcambodia.org

នោះគឺ ៖

ដំបូងខ្សែនចេញព្រានព្រៃ (អ្នកកាន់ធ្នូ) ដើរបែបស្ទាប ៗ ដើរ, តែកក្រឡេបក្រឡាប់ឆ្វេងស្តាំ ដើរវង់ជុំវិញក្នុងវេលាដែលលេង រាំ ៗ បន្ទាប់មក ចេញទន្សោងមួយគូមកដើរបែបផ្អើល ១, អន្ទ្រញ ដើរ កន្ត្រាក់ក្បាលផង ហើយឈានបែបទីនតាំង ១ ៗ ដៃតាំង ពីរ ជួនរុញទៅមុខ ធ្វើបែបជាជើងមុខ, ជួនប្រក់បង្ក្រះតាំងសង ខាង ហើយយូរ ១ម្តង ធ្វើជាជល់ក្បាលគ្នាលេង ៗ ចុងបំផុត មានខ្លា ចេញមកដើរបែបលប ១ ដើរឈប់ ១ នោះគៀនវង់លេង រាំហើយតើកសំឡុកទៅទន្សោងទាំងពីរ រួចដើរក្រវែលពីក្រោយ ព្រានឆនោះទៅទៀត ៗ

## ៣– អំពីចំនុកច្រៀង

ចំនងមើលទៅបទច្រៀងពិតជាមានច្រើនបែបច្រើនយ៉ាងតាម ការតាក់តែងនៃអ្នកស្រុកផ្សេងៗគ្នា ប៉ុន្តែក្នុងទីនេះ យើងលើកយក តែចំនុកណាដែលគេស្គាល់ច្រើន មកធ្វើជាបទពិចារណាប៉ុណ្ណោះ ៖

※ ទន្សោងស្នែងទប់     គេស៊ីតែយប់

ទន្សោងស្នែងខប់     ថ្ងៃខ្សែនពួនព្រៃ ៗ

www.budinst.gov.kh www.elibraryofcambodia.org

ខខ្យោងវែស្នងកែក ស៊ីបែកពីហ្វូង
ខខ្យោងវែស្នងព្រោង វ៉ែហ្វូងបែកខ្ចាយ ។
ជខ្យោងគោធា ស៊ីបន្លាជង្គុំ
ខខ្យោងព្រៃភ្នំ លេបក្រមុំតាំងមូល ។

(តាមឯកសារលោក រ.បារ៉ាដាត់)(១)

※ សូរិយាល្ងាចថ្ងៃ សូរិយាល្ងាចថ្ងៃ
ខខ្យោងគោព្រៃ រកស៊ីដើមភ្នំ ។
តូចស៊ីដោយតូច ធំស៊ីដោយធំ
ស៊ីតាមដើមភ្នំ ល្បះព្រិចខ្ចីល្អ ។
ស៊ីហើយរាំផល់ ផល់គ្នាវីវរ
សុទ្ធតែឡើងក ស្អួតមានកម្លាំង ។

( តាមការចាំរបស់លោក គេង ទ-វៀ ជា គ្រូនៅសាលា
វិចិត្រសិល្បខេមរៈ )

※ បងដើរព្រៃស្ងួត បងរុំតព្រៃស្បាត
ដើរកាត់ព្រៃញាត លោតលេចូលព្រៃ ។

១– R.BARADAT, Les Samrê ou Péar, BEFEO T. XLI, 1941 P. 97

www.budinst.gov.kh

ឡើងភ្នំចុះភ្នំ ថ្មដាត់ក្រៃ

តាំងបន្ទាយឃ្មុំ ល្បាស់ព្រៃលាស់ល្អ ៗ

ទន្សោងគោបា កៀងញីវីវ

ល្បាស់ព្រៃលាស់ល្អ ស្រណោះខែពិសាខ ៗ

កន្ទ្រួតអើយ ទន្សោងគោបា

លើបបន្ទាជើងភ្នំ សុបគ្រមុំតាំងមូល ៗ

ជំនោរខ្យល់បក់ ត្រជាក់ខ្យល់ផ្លូន

កាប់ឫស្សីចងក្បូន ជូនប្អូនទៅស្រុក ៗ

កន្ទ្រើងបងបាត់ បងកាត់មិនស្តាយ

បំណាច់យ៉ាតឆ្ងាយ បងស្តាយតែប្អូនស្រី ៗ

(តាមឯកសារលោក ឌួង-អ៊ុច)

## ៤– អំពីដើមកំណើត

ការផ្សាយដំណើររឿងដើមកំណើត នៃរបាំនេះ មានប្រភពលេចឡើង ច្រើនតាមកន្លែងទាំងរឿងនិទានទៅវិញ ដូចជាភ្នាក់ភូមិអញ្ចាញផ្ទើ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង បានជិតជានិទាន មានរឿងព្រេងមួយដូចតទៅ ៖

www.budinst.gov.kh www.elibraryofcambodia.org

កាលនោះ មានព្រានព្រៃម្នាក់ឈ្មោះព្រាន "ពរ" ទទួលព្រះរាជបញ្ជាពីព្រះរាជា ហើយចេញទៅរកបាញ់ទន្សោង, ព្រានទៅបាត់យូរណាស់ ទើបត្រឡប់ចូលមកគាល់ព្រះរាជាវិញ ដោយដៃទទេ គ្មានបានអ្វីឡើយ ។ ព្រះអង្គក៏ត្រាស់សួរថា ហេតុអ្វីក៏ពុំបានទន្សោងមួយសោះដូច្នេះ ។ ព្រានពរ ក្រាបបង្គំទូលថា ខ្ញុំបានដើរទៅដល់ព្រៃផលសម្បូណ៌ទៅដោយសត្វទន្សោង និងម្រឹគដទៃៗ ។ ប៉ុន្តែដោយទូលព្រះបង្គំរវល់តែមើលទស្សនីយភាពមួយ យ៉ាងចំឡែកអស្ចារ្យណាស់ គឺសត្វទន្សោងមួយគូញីឈ្មោល វាចេះរាំយ៉ាងល្អ នាំឲ្យដក់មិនអាចបាញ់វាកើតឡើយ ។ ទូលព្រះបង្គំផ្គងស្នាលើស្មាលប ៗ ចូលទៅ ប្រុងតែនឹងបាញ់ដែរ តែដោយល្អមើលក្បាច់ចង្វាក់រាំរបស់សត្វនេះពេកក៏ខកខាន រកតែដោះព្រួញឲ្យរត់ទៅមិនកើត ។ មិនតែប៉ុណ្ណោះ មានខ្លាធំមួយដែលលបមកប្រុងនឹងចាប់ទន្សោងដែរនោះ ក៏ចាប់មិនកើត បែរជាជួយគោះជើងជាចង្វាក់ ឲ្យសត្វនេះទៅវិញ ។ ជាមួយក្បាច់រាំរបស់ទន្សោង មានគន្ធូងមួយហ្វូង ហើរស្រែកប្រទក្សិណជុំវិញទន្សោងទាំងពីរ ជួយធ្វើជាសូរសំនៀងពិរោះល្ហឹងល្ហើយ ។

www.budinst.gov.kh www.elibraryofcambodia.org

ព្រះរាជាទ្រង់ព្រះសណ្ដាប់ដូច្នោះហើយ ព្រះអង្គត្រាស់ប្រើឲ្យព្រានពរ ធ្វើត្រាប់តាមទស្សនិយភាពនោះថ្វាយព្រះអង្គ ។ ព្រានពរក៏ខំធ្វើត្រាប់ឲ្យបានគ្រប់កាយវិការ និង សូរសំនៀងសត្វ ថ្វាយព្រះរាជាទ្រង់ទតនិងទ្រង់ព្រះសណ្ដាប់គ្មានសល់ចន្លោះអ្វី ។

ការសម្ដែងកាយវិការ របស់ព្រានពរនេះហើយ ដែលកើតបានទៅជាវង់របាំនេះឡើង គឺ ៖

- អ្នករាំស្លៀកពាក់ជាដំណាងទេវតា-ឈ្មោល ;
- សំឡេងស្គរដំណាងសន្ធឹកខ្លាធំ ;
- សំឡេងព្ធយជាដំណាងសូរសត្វសត្វកន្ទង់ ។

ពុទ្ធសាសនបណ្ឌិត្យ បណ្ណាល័យ LIBRARY BUDDHIST INSTITUTE

វង់របាំនេះ គេហៅឈ្មោះក្នុងគេថា « ក្ដីយហោពរ » គឺគេសំគាល់តាមឈ្មោះព្រានពរ ជាអ្នកបង្កើតវង់នេះ ។

ប៉ុន្តែ បើយើងផញ្ចាលវែរ គិតស្រាវជ្រាវតាមការសិក្សាបែបជាតិពន្ធុសាស្ត្រ (Eiudes ethnographiques) វិញ យើងយល់បានម្យ៉ាងទៀតថា ជនជាតិដើម (Autochtone) នៅក្នុងប្រទេសកម្ពុជាយើង មានជនជាតិមួយហៅថា « ពរ » ដែលរស់នៅតាមជួរភ្នំក្រវាញ ត្រង់ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ; ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ; ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង និង ស្រុក

www.budinst.gov.kh www.elibraryofcambodia.org

កំពង់សោម ខេត្តកោះកុង ៗ របាំនេះសោត ក៏មាននៅតែត្រង់ភូមិភាគតំបន់នេះដែរ នាំឲ្យគេសន្និដ្ឋានបានថា ព្រានពរនេះ គឺព្រានសាសន៍ព័រ ដូច្នេះរបាំប្រជាប្រិយនេះ កកើតឡើងពីជនជាតិព័រ ដែលមានសូរសំនៀងអានពាក្យនេះក្លាយបន្តិចមក ។ ហេតុនេះ យើងសរុបបានថា របាំទន្សោងជាកេរ្តិ៍ដំណាលមកពីពួកព័រ សំរាប់លេងនៅពេលប្រកបពិធីអ្វីមួយ យកលំនាំតាមរបស្គាគេជាអ្នកប្រមាញ់ ៗ

តាមសេចក្ដីអធិប្បាយយ៉ាងវែងរបស់លោក រ. ចាកដាត់ ជាតិបារាំង ដែលបានធ្វើសេចក្ដីសង្កេតអំពីជីវភាពរបស់ជនជាតិសំរែនិងព័រ ហើយសរសេរចុះផ្សាយក្នុងព្រឹត្តិបត្រសាលាបារាំងនៅចុងបូព៌ាប្រទេសថា "របាំកំស្នូលទន្សោងនេះ ប្រាកដជាកើតឡើងពីពួកជាតិព័រខ្មែរ ដោយលោកបានទៅធ្វើសេចក្ដីសង្កេតដល់ទីកន្លែងរស់នៅជាមួយពួកព័រនេះអស់ពេលយ៉ាងយូរ" ៗ លោកបានអះអាងទៀតថា "លោកធ្លាប់ឃើញពួកព័រលេងរបាំនេះផ្ទាល់ភ្នែក" ហើយលោកមានទាំងថតរូប ចុះផ្សាយជាមួយអត្ថបទលោកផង ៗ ដូច្នេះ សរុបសេចក្ដីបានថា បណ្ដាជនដែលរស់នៅលើទឹកដីយើងពីបុរាណ មានសាសន៍ព័រនេះជាអាទិ៍ សុទ្ធតែបានបង្កើតរបាំសំរាប់

www.…gov.kh www.elibraryofcambodia.org

លំហែចិត្ត ដោយប្រឌិតយកតាមលំនាំនៃការប្រកបជីវិត គឺជាកាល នោះ គេរស់នៅដោយព្រៃ មានតែម្រឹគជាញាតិមិត្ត ឬ ជាចំណី អាហារប្រចាំថ្ងៃ, ម្ល៉ោះហើយការប្រឌិតក្បាច់រាំរែក ទិងប្រង់ ប៉ុ គាត់តែងកាយឲ្យដកដួលទៅរករូបភាព ទិងកាយវិការម្រឹគទាំង នោះដែរ ។

តាមឯកសារលោក រ.ធាភដាត៍ បន្ថែមថា របាំលេងនៅ ក្នុងភូមិដែលសំខាន់ៗ ប៉ុន្តែតាមមតិខ្មែរយើងខ្លះ ចាំថា គេលេងនៅ ក្នុងវាំងតែក្នុងព្រះរាជពិធីបុណ្យចូលឆ្នាំ ។

www.budinst.gov.kh www.elibraryofcambodia.org

# ៣ - របាំគោះអង្រែ

របាំគោះអង្រែ តាមពត៌មានពីសមាជិកម្នាក់ក្នុងក្រុមជំនុំទំនៀមទម្លាប់ថា មានលេងនៅសឹងតែគ្រប់ស្រុកក្នុងប្រទេសកម្ពុជាកាលពីសម័យដើម ៗ ប៉ុន្តែមកដល់សព្វថ្ងៃ របាំនេះនៅសេសសល់បន្តិចបន្តួច តែស្រុកណាដែលមានអ្នកថែរក្សា យ៉ាងស្វិតស្វាញខិតខំរក្សាទុកប្រពៃណីនេះ ឲ្យមានគង់នៅក្នុងស្រុកក្នុងភូមិខ្លួន ឬមួយនៅមានតែត្រង់ភូមិភាគណា ដែលនៅឆ្ងាយអំពីទីដែលមានវប្បធម៌នៃប្រទេសដទៃ ចូលមកជ្រៀតជ្រែកលាយឡំបាន ដូចជាភូមិភាគសំពៅធុនកាល់, ជាំក្សាន្ត ជាដើម ៗ ហេតុនេះ បើធៀបផ្ទឹមរបៀបលេងរបាំនេះក៏គង់យើងឃើញជាក់ថា របៀបលេងរបស់អ្នកដែលនៅសំពៅធុនកាល់ នៅជាំក្សាន្ត មានបែបបទបុរាណច្រើនជាជាងរបៀបលេងរបស់អ្នកស្រុករៀងតាយៈយើងនេះ ឆ្ងាយណាស់ ទាំងក្បាច់លោតរាំ ទាំងសំលៀកបំពាក់ ទាំងបទបន្ទរនិងចំនុកច្រៀង ៗ យើងយល់មួយយ៉ាងទៀតថា របាំក្តី ភ្លេងភ្លាត់ក្តី បើកប់ថាជាភ្លេង ឬរបាំតាមប្រពៃណីខ្មែរយើងបុរាណមក

www.budinst.gov.kh www.elibraryofcambodia.org

យើងត្រូវតែរក្សារបៀបរបបបូរាណនោះ ឲ្យគង់នៅទើបល្អ ជាជាង
ការយកមកបំផ្លែងឲ្យបានតែងាយ ៗ បាត់បង់លក្ខណៈចាស់អស់
នោះមិនគាំឲ្យបាត់បង់ទាំងសោភ័ណនៃរបាំនោះទៅផងដែរ ។

អាស្រ័យការយល់យ៉ាងនេះ យើងលើកមកអធិប្បាយក្នុងទីនេះ
គាត់ច្រើនយកតាមតម្រាយបុរាណ ដែលនៅសល់ជាមួយអ្នកស្រុក
គៀនកោះនោះឯង ដោយមានប្រាថ្នាទុកក្បួនច្បាប់របាំនេះ ឲ្យកុល
បុត្រ-កុលធីតាខ្មែរក្រោយ ៗទៅ បើលេងតាមក្តី មិនលេងតាមក្តី
ក៏គ្រាន់តែឃើញនូវសម្រស់លំអនៃរបាំបុរាណ ត្រឹមពិតបុព្វបុរស
យើងថា យ៉ាងនេះ ឬយ៉ាងនោះទៅចុះ ។ម្យ៉ាងទៀតការទុកដាក់ខាង
ផ្នែកសិល្បៈប្រជាប្រិយបែបនេះ ទុកដូចជាទុកដាក់ឲ្យអ្នកក្រោយ ៗ
ងាយស្រួលនឹងស្រាវជ្រាវរកអារ្យធម៌បូរមបូរាណរបស់ខ្មែរយើង
ដែលមានមកហើយជាច្រើនអនេកប្បការ ។

## ១- អំពីប្រដាប់ប្រដា

ប្រដាប់ប្រដាទាំងឡាយសំរាប់លេងមាន ៖

### ក- គ្រឿងភ្លេង .-

គ្រឿងភ្លេងសំរាប់ផ្សំជាមួយរបាំនេះ គ្មានអ្វីច្រើនទេ ព្រោះ

www.bophanst.gov.kh www.elibraryofcambodia.org

ជារបាំងាយស្រួលបំផុត គឺមានតែអង្រែពីរមានប្រវែងប្រមាណជាជាងពីរម៉ែត្រ និងទំហំប្រមាណប៉ុនកំភួនដៃប៉ុណ្ណោះ ។ មានអង្រែ ២ ជាគំណល់សំរាប់គល់ចុងសងខាង ។

## ខ- សំលៀកបំពាក់ .-

តាមនិយមរបស់អ្នកចូលចិត្តរបាំនេះ គេស្លៀកខោទាំងប្រុស ទាំងស្រី ឯអាវគេពាក់អាវធម្មតា ។ ខោនោះជួនពណ៌ ជួនខ្មៅ តាមគេស្ម័គ្រ ហើយក្រវាត់ចង្កេះយ៉ាងតឹងដោយក្រមាពណ៌ ។ មានស្រុកខ្លះទៀតគេស្លៀកខោតែប្រុស ។ ទេ ឯស្រី ។ ស្លៀកសំពត់ចងក្បិនឲ្យរឹតបន្តិច ហើយមានក្រវាត់ចង្កេះដូចគ្នា ។ ហេតុបាននិយមយ៉ាងនេះ ព្រោះការលោតរាំកែងជួនកន្ទួតជើង ជួនលើកជើងខ្ពស់ បោះទៅមុខទៅក្រោយ បើស្លៀកសំឡុយពុំអាចធ្វើបានស្រួលងាយឡើយ ។

## គ- គ្រឿងភ្លេង .-

ដោយរបាំនេះជារបាំសាមញ្ញពេក គ្រឿងភ្លេងមានតិចតួចណាស់ គឺមានតែសាដៀវមួយនិងអង្គួចមួយ សំរាប់លេងកំដររបាំច្រៀងតាមចង្វាក់អង្រែដែលគោះទង្គិចគ្នា ។ តែមានវង់ខ្លះ តាម

ការចូលចិត្ត គេមានបន្ថែមស្គរអារក្សមួយនិងក្រាប់មួយទៀត ព្រមទាំងមានអ្នកទះដៃបន្ទរច្រើននាក់ ។



សាដៀវ



រូបអន្លប (មើលពីលើ)

## ២- អំពីរបៀបលេង

របៀបរាំប៉ាំនេះ ត្រូវមានការហ័សរហួនខ្លាំងណាស់ ព្រោះបើកាន់ជើងតែបន្តិចនឹងមានគ្រោះថ្នាក់ ។ មនុស្សពីរនាក់អង្គុយកាន់ចុងអង្រែម្ខាងម្នាក់ គេកាន់ដៃទាំងសងខាង ម្ខាងមួយ រួចហើយគេទាញអង្រែនេះទង្គិចគ្នាជាចង្វាក់ ព្រមទាំងគោះទង្គិចទៅនឹងកំណាល់ទៀតផង ។ របៀបគោះនិងទង្គិចនេះ តាមចំនួនរបស់គេ គេគាំងគោះនិងទង្គិចទៅតាម „ម៉េ” ដែលគេហៅថា ៖

www.elibraryofcambodia.org

១. រាំអង្រែដមេពីរ.- មេនេះ ត្រូវទង្គិចលើកំណល់ ២ដង គោះចុងអង្រែម្ដង បណ្ដាក់គ្នារហូតឥតឈប់ផ្លាស់របៀបទេ ។ ឯអ្នកលោត ត្រូវប្រយ័ត្នឲ្យត្រូវចង្វាក់នេះ ។

២. រាំអង្រែដមេបី.- មេអង្រែបី ពុំមែនប្រើអង្រែបីទេ គឺអង្រែតែពីរដដែល ប៉ុន្តែគេទង្គិចកំណល់បីដង ទើបគោះអង្រែឲ្យប៉ះគ្នាពីរដងតែ យ៉ាងនេះរៀងរហូតទៅ ។

រីឯអ្នកលោតនិងរាំត្រូវប្រុងប្រយ័ត្នជើងតាមចង្វាក់ដែលគេគោះ គឺគេគោះមេណា ត្រូវលោតឲ្យត្រូវតាមចង្វាក់មេនោះ ។ របៀបលោត គឺដំបូងកន្ទេកជើងទាំងពីរលើសលើអង្រែ ដែលគេកាន់សណ្ដូក ។ កាលគេចាប់គោះភ្លាម ខ្លួនក៏ត្រូវចាប់ចាក់ក្បាច់ភ្លាមដែរ ដោយជើងប្រុងឈានលោតចូលមកក្នុងចន្លោះអង្រែទាំងពីរ ដែលគេទាញឃ្លាតគ្នាឲ្យចំហម្ដង ៗ កាលណាគេគោះជុំគ្នាមកវិញ អ្នករាំត្រូវដកជើងឲ្យផុត តែទំ ៗ មុខជាអង្រែវាយចាក់ស្មងជើងមិនខាន ។ និយាយឲ្យងាយយល់ថា កាលណាគេទង្គិចអង្រែទាំងពីរឲ្យប៉ះគ្នា អ្នករាំត្រូវដកជើងមកដាក់កន្លែងសងខាងអង្រែនោះ ឬមួយជាឈរជើងម្ខាង; ឯម្ខាងទៀត លើកខ្ពស់ឲ្យផុតឡើងលើដោយអង្គុញឡើង ឬមួយជាបោះទៅមុខទៅក្រោយបង្វិលធ្វើជាក្បាច់រាំតម្លន ។

www.budinst.gov.kh www.elibraryofcambodia.org

ឯផងខ្លួន ត្រូវបន្ទន់ខែងអែង ចេះឡៀងទៅឆ្វេងទៅស្ដាំតាម ការសមជាមួយនោះដែរ ។ ចំណែកដៃទាំងពីរ បក់បោយ លោក លេក រាំតាមចង្វាក់ដែលគេគោះ និងចង្វាក់ភ្លេងព្រមទាំង ចម្រៀងបន្ទរ ៗ



អ្នកគោះអង្រែក្ដី អ្នកលោតរាំក្ដីមិនកំណត់ថាប្រុសឬស្ត្រីទេ ស្រេចហើយនឹងការចូលចិត្ត ឬការប៉ុនប្រសប់របស់អ្នកទាំងនោះ ។ ចំណែកអ្នកស្រុកជិតខាងដែលនាំគ្នាមកឈរមើលរបាំនេះ គេតែង យកចិត្តទុកដាក់ជួយទះដៃបន្ទរគ្រប់ ៗ គ្នា ជួនកាលគេជួយច្រៀង ទៀតផង ។

budinst.gov.kh www.elibraryofcambodia.org

## ៣– អំពីចំនុកច្រៀង

ប៉ុះនេះ នៅស្រុកខ្លះដែលកាន់តែឆ្ងាយ យារទៅៗ នោះ ពុំមានចំនុកច្រៀងទេ មានគ្រាន់តែពាក្យបន្ទរមួយម៉ាត់ពីរម៉ាត់ប៉ុណ្ណោះ ដូចជាពាក្យថា "ហេ! ហេ! ហៃណា ហៃណា! ជាដើម ៗ ប៉ុន្តែនៅតំបន់ណាដែលប្រកាន់ខ្ជាប់នូវទំនៀមបូរាណវិញ មានបទបែបក្រាស់ក្រែលណាស់ដែរ សំរាប់ច្រៀងបន្ទរនៃការរាំអង្រែ ៗ

ដើម្បីជាកស្តុតាង យើងសូមស្រង់យកចំនុកខ្លះមកដាក់ក្នុងនេះ តាមការចូលចិត្តរបស់អ្នកស្រុកដែលបានចាំទុកមកផ្សេង ៗ គ្នា៖

១– (១) សារិកាកែវអើយ　　សារិកាកែវកើច
បង់លោមឡើងសើច　　ចង់មើលធ្មេញខ្មៅ ៗ
២– ស្រីស្រសប្រហើរ　　ស្រីស្រស់ប្រហើរ
ប្រយ័ត្នជើងដេរ　　ក្រែងអង្រែដំជើង ៗ
៣– ទន់អើយស្រីទន់　　ទន់អើយស្រីទន់
លើកដៃល្ហាស់ល្ហន់　　ស្រីរាំលោតអង្រែ ៗ
(បន្ទរ) មែនហើយ　　កាដែនមែនហើយ !

ពាក្យបន្ទរនេះ ត្រូវពួកអ្នកឈរមើលដែលទះដៃនោះ

---

១– តាមឯកសាររបស់លោក គុយ ហួត គ្រូបង្រៀននៅសូទ្រនិគម (សៀមរាប) ជា [illegible] និងអ្នកដើរភ្នំគូលែន ។

www.budinst.gov.kh　www.elibraryofcambodia.org

ស្រែកឡើងព្រម ៗ គ្នា ៗ ឯចំនុកច្រៀងខាងលើនេះ ដូចកាលគេបំភ្លៃទៅច្រើនបែបទៀត ប៉ុន្តែទោះជាបែបណាក៏ដោយ ក៏សុទ្ធតែជាបទកំប្លែងផ្តោះផ្តងឲ្យបានសើចទាំងអស់ ៗ

តាមឯកសារមួយដទៃទៀត បានបង្ហាញចំនុកប្លែកពីនេះទៀតគឺ ៖

១–(១) ប៉ោំអើយវង់តូច (បន្ទរ) ហ៊ាំរើយវង់តូច !<br>
មិនដូចវង់ធំ (បន្ទរ) ហ៊ាំរើយវង់ធំ !<br>
ប៉ោំអើយកន្ទុំ ទើបតែរៀនថ្មី !<br>
(បន្ទរ) ទើបតែហ៊ាំរៀនថ្មី !

២– អង្គុបអើយដេញជៀរ (បន្ទរ) ហ៊ាំរើយដេញជៀរ !<br>
សារជៀរដេញដង (បន្ទរ) ហ៊ាំរើយដេញដង !<br>
បើស្រីដោយបង ដឹងដោយស្វាថ្នាក់<br>
(បន្ទរ) ហ៊ាំរើយស្វាថ្នាក់

បញ្ជាក់.– ត្រង់ពាក្យថា " ហ៊ាំរើយ " គេស្រែកទទួលច្រើនគ្នាអ៊ឹងអរ ៗ

ឯសេចក្តីចំនុកផ្សេង ៗ ទៀត ដែលគេនៅចាំបាន់នោះ មានដូចតទៅទៀតនេះ ៖

---

១– តាមឯកសារលោក ចៅឃុំសាឃុំឬស្សីព្រៃ ស្រុកសណ្ដាន់ (កំពង់ធំ) ជាជាប់ទរបស់

សំរាប់ប្រុស .-

– អំពិលអំពែក ទំមែកអំពៅ ល្វាចនេះបង់ទៅ ឲ្យពៅចាប់ក្តៃ ៗ

– បើចាប់អាលុក បញ្ចុកអាភេ គូនត្រូវចាប់ក្តៃ ព្រលចប់ចង់ដុល់(១) ៗ

– ស្រីអើយបងនឹក ស្រីអើយបងនឹក ស៊ីបាយស្រូបទឹក ប្រាំគោមកខ្ទះៗ

– ប្រាំពីរឆ្នាំនដី ប្រាំបីឆ្នាំនខ្ទះ ប្រាំគោមកខ្ទះ ស៊ីសោះញ័រខ្លួន ៗ

– គ្រពើនាំស្រី បងចាំនៅផ្អូក ចាំដល់ទឹកស្រក ស្តាយត្រុកសែសផ្អឹង ៗ

– រូបស្រីជ្រះស ល្អជាងស្រីខ្មៅ ត្រូវប្រេងម្សៅ ស្រីខ្មៅល្អជាង ៗ

– ខ្មៅខ្មៅគ្រះតូច ដូចបាតអម្បែង បេះគុបចេះតែង ចំណីគ្រប់មុខ ៗ

– សក់ស្រីបានបង សក់បងបានកាត់ គេមាយរត់មាត់ ថាស្រីបានបង ៗ

– បងដាំពោធិមួយ ពុំទាន់បានធ្លុង បើស្រីដាំយបង ធ្លុងពោធិពីរនាក់ៗ

សំរាប់ស្ត្រី .–

– ខ្លួនអ្នកនៅថ្លៃ ខ្លួនស្រីនៅក្មេង អ្នកកុំលេង ក្រែងមានអាសន្ន ៗ

– អ្នកបង់ប្រាជ្ញា ត្រូវរិះគិតគន់ កុំអាលអាសន្ន ម៉ែឪប្អូនមាន ៗ

'– ទឹកហូរមិនហាក់ ប្រុសស្បថមិនជឿ ទឹកហូរឡើងលើ ទើបជឿប្រុសបាន

– ធ្វើបុណ្យពោសព្រះ ជម្រះវិហារ ខ្ញុំឧស្សូមរៀរ អ្នកប្រុសចិត្តពីរ ៗ

សេចក្តីសង្កេត.- តាមការសង្កេត យើងឃើញថា ចំនុកច្រៀងទាំង

---

១– ទំនុកនេះដកចំការបស់ភាសខ់ត៏ សុំមើល BEFEO, Tome XLI; 1941 P88

នេះ សុទ្ធតែមានចង្វាក់ញាប់ ៗ រន្ធើន ៗ ដើម្បីឲ្យត្រូវតាមចង្វាក់ លោត ឬ ស្គរអង្រែដែលគេគោះ ។ ឯរបៀបចងជាកាព្យវិញ យើងឃើញមានក្នុងមួយគាថា ១៦ ព្យាង្គ បែកចេញជាបួនឃ្លា ។ ឃ្លានីមួយ ៗ មាន ៤ ព្យាង្គស្មើ ៗ គ្នា មិនគិតពីពាក្យបន្ទរទេ ។ សម្ពស្សពាក្យជួនមានច្រើនដែរ គឺមានមួយម៉ាត់ក្នុងមួយឃ្លា ។ តែគាថាជាបន្ត ៗ ទៅ ដូចជាពុំឃើញមានជួនទាក់មកគាថាមុន ៗ ទេ ។

ឧទាហរណ៍ដូចគំនូសនេះ ៖



## ៤– អំពីដើមកំណើត

ឯកសាររបស់លោកកុយ-ហ្សួត នៅស្រុកសូទ្រនិគម ខេត្តសៀមរាប បានឲ្យការណ៍ថា អ្នកស្រុកនៅត្រង់ស្រុកលោក គេហៅរបាំអង្រែថា "របាំគួយ ឬ រាំគួយ" ។ បើតាមពត៌មាននេះ ឃើញថាជាប់ឈ្មោះកុលសម្ព័ន្ធខ្មែរដើមមួយដែលហៅថាគួយ ។ សាសន៍គួយនេះ រស់នៅលើផែនដីស្រុកខ្មែរយើង តាំងពីមិនទាន់កសាងជាគាណាចក្រឡើងជាច្បាស់ប្រាកដនៅឡើយ ។ ដូច្នេះបើមានស្នាមផាននៅជាប់និងពាក្យអ្នកស្រុកយ៉ាងហ្នឹង នាំឲ្យយើង

www.budinst.gov.kh www.elibraryofcambodia.org

គេឃើញថារបាំនេះ មានដើមកំណើតមកពីសាសន៍ជាតិតូចតាចមួយ ដែលហៅថា "គួយ" អាចចាត់ទុកជាអារ្យធម៌ខ្មែរដើម ដែលពុំទាន់បានទទួលអារ្យធម៌សាសន៍ជាតិនានា មានអារ្យធម៌ឥណ្ឌាជាដើម ។ បើយល់យ៉ាងនេះ ក៏ជាការសមហេតុសមផលដែរហើយ ព្រោះរបាំនេះ មាននៅសេសសល់ដល់សព្វថ្ងៃជាប់លាប់ជាងគេតែនៅតាមភូមិភាគភ្នំដងរែក គឺជាភូមិភាគដែលមានសាសន៍គួយនេះរស់នៅតាំងពីដើមមកដូចជាត្រង់ជាំក្សាន្ដ, សំរោងទុងកាល់, ជើងភ្នំគូលែនសព្វថ្ងៃនេះ ។

មានឯកសារពីសមាជិកាន្ទ័យ ខ្លះនៃក្រុមជំនុំយើងច្រើនទៀតបានឲ្យការណ៍ថា របាំនេះចំឡងមកពីប្រទេសហ្វីលីពីនកាលជំនាន់រជ្ជកាលព្រះបាទសម្ដេចព្រះនរោត្តម (ព្រះសុវណ្ណកោដ្ឋ) ដែលព្រះអង្គទ្រង់យាងទៅក្រុងម៉ានីល ហើយពពួកបរិពារព្រះអង្គបានរៀនរបាំនេះ យកមកលេងនៅប្រទេសយើង ។ ឯកសារលោកជឹម-ឈុំ នៅស្រុកសណ្ដាន់ បានបញ្ជាក់ថា បានជារបាំនេះរលដាលទៅតាមភូមិក្រៅៗ ដោយសារមានទាហានហ្វូងដែលចេញទៅធ្វើសង្គ្រាមតាមទិសជនបទនានាបាននាំយករបាំនេះ ទៅឲ្យអ្នកស្រុករាត់លេងតាមដំណើរដែលគេទៅតើកទៅដល់ ។ លោក

www.budinst.gov.kh www.elibraryofcambodia.org

ដឹម ឈុំ បន្ថែមទៀតថា នៅស្រុកណាក៏មាននៅសល់តាំងគ្រួសាររបស់អ្នកដែលធ្លាប់ធ្វើជាមេទ័ពកាលពីជំនាន់នោះផង ។ អ្នកស្រុកតាំងនោះហើយ ដែលបានបញ្ជាក់ជាខ្លួនដឹងច្បាស់ថា របាំនេះពិតជាផ្សាយទៅតាមពួកកងទ័ពនេះមែន ដោយមានអ្នកខ្លះតាំងទីនៅកំពង់ស្វាយ, សណ្ដាន់ បានដាក់ទ័ពនៅទីនោះព្រោះជាទីសម្បូណ៌ដែកសំរាប់ធ្វើសស្ត្រាវុធ ។ បើយោលតាមគតិមាននេះ ឃើញថារបាំពាក់ស្រែនេះ ទំនងជាមានដើមកំណើតមកពីប្រទេសហ្វិលីពីន ។

ប៉ុន្តែបើពិចារណារកហេតុផលបន្ថែមទៀត យើងអាចសន្និដ្ឋានជាសរុបថា របាំនេះជាសំណល់មកពីសាសន៍ជាតិ ជាវដ្តកសីជាន់ដើម ( les autochtones ) ដែលរស់នៅលើដីគោកគុកគាបផ្នែកអាស៊ីនេះ ហើយដែលទុកសំណល់អារ្យធម៌យ៉ាងច្រើនលើសលុបហូតមកដល់សព្វថ្ងៃមានអក្សរ, ភាសា, ភ្លេង, ចម្រៀង ទំនៀមទម្លាប់ ជាដើម ។ អារ្យធម៌នេះមានឈ្មោះថា “អារ្យធម៌អូស្ត្រូអាស៊ី ( Austro-Asiatiques )” ដែលគេទុកជាមែកធាងយ៉ាងធំរបស់អារ្យធម៌សកលលោកសព្វថ្ងៃ ។ ហេតុដូចម្ដេចទើបយើងពោលដូច្នេះ? ព្រោះថាជនជាតិកួយនៅទឹកដីស្រុកយើងក៏, ជនជាតិដើម

www.budinst.gov.kh www.elibraryofcambodia.org

ផ្សេងៗ ដែលរស់នៅលើកោះជាច្រើននៃប្រទេសហ្វីលីពីនក្តី សុទ្ធតែជាអ្នកមានកំណើតដើម បង្កើតអារ្យធម៌អូស្ត្រូអាស៊ីដូចគ្នា បានសេចក្តីថាមានឫសគល់ដើមជាមួយគ្នា ។

ដូច្នេះ សន្និដ្ឋានបានថា ពោំអាខ្មែរនេះមានកំណើតមកពីមនុស្សជាន់ដើមដែលបង្កើតអារ្យធម៌អូស្ត្រូអាស៊ី មិនប្រាកដជារបស់ជាតិណាតែម្នាក់ ៗ ឡើយ ។

※

※ ※

www.budinst.gov.kh www.elibraryofcambodia.org

# ៤_ របាំបុកអង្រែ

របាំបុកអង្រែ ជារបាំមួយផ្សេងពីរបាំគោះអង្រែ ។ សព្វ-ថ្ងៃរបាំនេះឃើញមាននៅតាមស្រុកភូមិឆ្ងាយពីកជនាទី ព្រោះធ្លាក់ទៅជារបាំប្រជាប្រិយ ដែលអ្នកស្រុកខ្លះនិយមលេងនៅពេលបុណ្យចូលឆ្នាំ ដើម្បីលើកដំកើងពិធីបុណ្យនេះឲ្យរឹតតែឧឡារិកឡើង ៗ អាស្រ័យដោយការខ្សត់ខ្សោយពុំសូវមាននៅសល់ច្រើនគន្លង របាំនេះក៏ស្ទើរតែគេលែងស្គាល់ឈ្មោះទៅហើយ (១) ។ ប្រសិនជានៅចាំឈ្មោះខ្លះ ៗ ក៏គេពុំសូវដែលបានឃើញរូបភាពច្បាស់លាស់នៃរបាំបុកអង្រែនេះដែរ ។

យើងសង្កេតត្រង់ឈ្មោះថា "បុកអង្រែ ៗ" អាចហុចន័យមកក្លាយវិញថា ចង្វាក់រាំនៃរបាំនេះច្បាស់ជាអាស្រ័យជាមួយការបុកអង្រែទៅក្នុងត្បាល់ ឬបុកទៅលើឈើកំណល់ណាមួយដើម្បីបញ្ចេញសូរ ជាមិនខាន ៗ ប៉ុន្តែតាមពិតពុំដូច្នោះទេ ៗ អង្រែនេះជាដងចង្ក្រមចង្ក្រង់ ដែលអ្នករាំកាន់នៅដៃ ដើម្បីបុកទៅនឹងដីបញ្ចេញសូរតាមចង្វាក់ក្បាច់រាំរបស់ខ្លួន ៗ បើយើងពិនិត្យសង្កេតឲ្យច្បាស់លាស់ពីរបាំនេះ ឃើញមានរបៀបដូចតទៅ ៖

---

១– តាមឯកសារនៅក្នុងក្រុមជំនុំ មានតែឯកសាររបស់លោក កៃ កុល នៅភូមិព្រៃរោង ឃុំអង្គតាសោម ខេត្តតាកែវ ជួយប៉ុណ្ណោះ ដែលឲ្យពត៌មានពីរបាំនេះ ។

# ១– អំពីប្រដាប់ប្រដា

## ក– គ្រឿងភ្លេង ៖—

គ្រឿងភ្លេងសម្រាប់ប្រគំបទយ៉ាំនេះ គ្មានអ្វីច្រើនទេ មានតែអង្រែ ៤ គឺអង្រែដែលព្យួរចង្រ្កង់ផងធ្វើពីឫស្សីឬធ្វើពីឈើ ៗ បើធ្វើពីឫស្សី គេយកឫស្សីមានទំហំប៉ុនកំភួនដៃ មានប្រវែងប្រមាណជា ១ ម៉ែត្រកន្លះ ឬ ២ ម៉ែត្រ ហើយពុះខាងចុងចេញជាបន្ទះៗ បិតឲ្យស្តើងស្អាត រួចពត់បន្ទះឫស្សីទាំងនោះឲ្យកចុងកំផាសដូចជាមាត់ជុច ដោយយកបន្ទះឫស្សីផ្សេងទៀត ដែលបិតស្តើងមកត្បាញក្រងជាជន្ទល់ទប់ឲ្យនៅជាប់មានសណ្ឋានដូចជាច្រម ឬមាត់ត្រែ ៗ តាមបណ្តោយបន្ទះឫស្សីដែលត្បាញនោះ មានចងបន្តោងព្យួរកូនចង្រ្កង់ប៉ុនៗ ម្រាមដៃដាក់ផ្គួបគ្នាត្រង់ចម្រៀក ៗ នៅចុងបំផុតនៃចម្រៀកឫស្សីដែលព្យួរចង្រ្កង់ មានចងក្រណាត់ជាតំដែលច្រៀកតូចៗ ធ្វើជាចុងរំយោលៗ ឯខាងគល់ដងឫស្សីនេះ ពុំមានបេនាជាអ្វីទេ ព្រោះសម្រាប់ចុកនៅទីជំទៀញឬស្ទើរតាមបទឬតាមចង្វាក់កំ ៗ ជួនកាលគេធ្វើដងនេះពីឈើមានសណ្ឋានដូចអង្រែ (១) តែបើដងជាឈើ ក៏ត្រូវតែយកបន្ទះឫស្សីមកបន្តខាងចុងធ្វើជារូបកង់សម្រាប់ព្យួរចង្រ្កង់ ដូចពោលមកហើយនេះដែរ ៗ

---

១ ដោយហេតុនេះហើយបានជាអ្នកស្រុកហៅថា (របាំបុកអង្រែ) ។

www.elibraryofcambodia.org

អាស្រ័យដោយសំអាងចុងដោយបង្កោមបន្ទ្រង់យ៉ាងនេះហើយ



បានជាកាលណាគេបុកទៅ អង្រែនោះក៏បញ្ចេញសូរប្រាវ ៗ យ៉ាង គឹកកង ៗ

## ១– ប្រដាប់តុបតែងកាយ .–

អ្នករាំទាំងនេះ មានប្រុសមានស្រី ហើយប្រុសស្រីទាំងនេះ មានសំលៀកបំពាក់ផ្សេងគ្នា ដូចតទៅ ៖

ប្រុស ៗ ពាក់អាវវៀលក ដៃខ្លី មានពណ៌តាមតែចូលចិត្ត, ស្លៀកខោខ្លីពាក់កណ្តាលភ្លៅ ចុងជើងចំក្រណាត់ជាតីក្រហម ហើយក្រប៉ូចតឹងជាប់ទីងសាច់ ៗ កបង់កខ្សែប្រចុច ចំណាក់ចុងសំពត់ទៅក្រោយខ្នង ៗ សក់កាត់ជើងកញ្ចើ ៗ.

ស្រី ៗ ពាក់អាវបំពង់វែង ទើបលើផ្ចិតបន្តិច ពណ៌ត្រយ៉ូបេកឬចុងល័ក្ត ; ដៃអាវស្តួចវៀវតឹងចុងដៃ ៗ សំពត់ចងក្បិនក៏ពណ៌ដែរ តាមការចូលចិត្តពណ៌អ្នកបាន ៗ ដៃពាក់កងប្រាក់ទាំងសងខាង ត្រចៀកពាក់ការ

www.budinst.gov.kh www.elibraryofcambodia.org

ទំពក់ , បង់កកន្សែងស្លូត្រសំយុងចុះមកមុខតាំងសងខាង ៗ សក់កាត់ផ្កាថ្កូវ ៗ

## ២– អំពីរបៀបរាំ

របៀបលេងរបាំនេះ ត្រូវមានមនុស្ស ៤ នាក់ ប្រុស ២ នាក់ ស្រី ២ នាក់ ស្មើគ្នា ៗ ម្នាក់ៗ សុទ្ធតែកាន់ផងអង្រែមួយរៀងៗខ្លួន ។ ដល់ពេលរាំគេឈរសងខាងទល់មុខគ្នា គឺស្រី ១ ពីនាក់ឈរម្ខាង ប្រុសពីរនាក់ឈរម្ខាង ហើយចាប់ផ្តើមច្រៀងម្តងម្នាក់ឆ្លងឆ្លើយគ្នាទំនងដូចច្រៀងប្រកែក តែមានរាំលេងជាមួយផង ។ បើនរណាមួយជាអ្នកច្រៀង អ្នកនោះឈានចេញមកមុខឃ្លាតពីជួរបន្តិច ហើយចាប់ច្រៀងយោលខ្លួនតាមក្បាច់រាំ ជើងគោះចង្វាក់ដៃម្ខាងកាន់អង្រែបុកបញ្ចេញសូរ ដៃម្ខាងរាំយ៉ាងទន់ភ្លន់ ៗ ម្នាក់ទៀតដែលត្រូវច្រៀងតទៅវិញ ក៏ធ្វើដូចគ្នានេះដែរ ៗ រីឯអ្នកដែលមិនច្រៀងទាំងប៉ុន្មាន សុទ្ធតែជួយបុកអង្រែឲ្យចង្វាក់ស្មើ ៗ គ្នា ព្រមទាំងយោលខ្លួនរាំរែកពេងជាមួយផង ៗ

ក្រៅពីអ្នករាំទាំង ៤ នាក់នេះ តែងមានអ្នកឈរមើលហើយជួយទះដៃឲ្យចង្វាក់រាំជាច្រើននាក់ទៀត ។

www.budinst.gov.kh www.elibraryofcambodia.org

ដោយសាររបាំនេះ គេលេងតែនៅពេលចូលឆ្នាំស្របជាមួយរបាំ ឬចម្រៀងច្រើនបែបច្រើនយ៉ាងទៀតនោះ, អ្នកស្រុកខ្លះក៏យករបាំរាំបុកអង្រែទៅបញ្ចូលជាមួយល្បែងបោះឈូង ឬចម្រៀងប្របកែឆ្លើយឆ្លងគ្នារវាងស្រីប្រុសទៅក៏មាន ។ ហេតុនេះ បានជាលោកកែវ គារុល នៅអង្គតាសោមបានឲ្យការណ៍ថា ៖ ពីដើមលោកប្រមខះគេលេងរបាំនេះនៅភូមិទ្រយឹង ឃុំជម្រះពេន ស្រុកសំរោង នៃខេត្តតាកែវ គេច្រៀងបទប្របកែ ឬបទបោះឈូងដោយច្រៀងឆ្លើយឆ្លងគ្នាអស់មួយវគ្គបោះឈូងម្ដង ៗ ហើយអ្នកស្រុកនោះក៏ហៅរបាំនេះថា "រាំបុកអង្រែបោះឈូង" ភ្ជាប់គ្នាដូច្នេះ ។

ឯគោលបំណងនៃការរាំបុកអង្រែនេះ ពុំមានត្រូវការសុំលុយកាក់អ្វីទេ គ្រាន់តែជាការសប្បាយក្នុងពេលបុណ្យទានសំខាន់ៗប៉ុណ្ណោះ ។

## ៣- អំពីទំនុកច្រៀង

ដោយអ្នកស្រុកនិយមយករបាំនេះទៅការឲ្យបញ្ចូលជាមួយល្បែងបោះឈូង ឬចម្រៀងប្របកែសឹងបាត់ដានដើមដូចអធិប្បាយមកខាងលើបានជាបទច្រៀងក្នុងពេលរាំ សុទ្ធសឹងជាបទបោះឈូង ឬប្របកែទាំងអស់ទៅវិញ មានបទ កែវកិតាន, បទកុសវង់ ជាដើម ។

www.budinst.gov.kh www.elibraryofcambodia.org

ដូច្នេះ សេចក្ដីជាចំនុកច្រៀងក៏ប្រែទៅតាមចំនុកដែលមានស្រាប់ក្នុងល្បែងចោលឈូងនិងចំរៀងប្រែបកែនោះដែរ មានតែការផ្ដើមសេចក្ដីខ្លះ ដែលគេព្រាងទុកនូវលក្ខណៈស្របជាមួយរបាំនេះ ដូចឃ្លាដើមមានសេចក្ដីថា ៖

※ ពួកយើងប្រុសៗ (ឬថា ពួកយើងស្រីៗ )
កំពុកអង្រែ
ទាំងអស់គ្រប់គ្នា
មានប្រុសមានស្រី ។
រដូវខែចេត្រ
ខែចូលឆ្នាំថ្មី
លេងទាំងប្រុសស្រី
សប្បាយគ្រប់គ្នា(១) ។

អ្នកច្រៀងទាំងប្រុសទាំងស្រី តែងចាប់ផ្ដើមឡើងសុទ្ធតែយកឃ្លាខាងលើនេះមកធ្វើជាលំនាំដើម រួចបន្តទៅមុខទៀតបំពេញបញ្ចូលថែមថយតាមសំនួនវោហារដែលគេលើកឡើងឲ្យបានសើចសប្បាយក្នុងសិល្បៈនេះឡើង ។

---

១— ចំនុកនេះ យកតាមសេចក្ដីរាយការណ៍របស់លោក កែវ កុល ដែលមានសេចក្ដីខ្លះផែ
ប៉ុណ្ណេះ ឯកសារលេខ ៦៣.០៦០ www.elibraryofcambodia.org

## ៤- អំពីទ្រនឹបគ្រូ

តាមទំនៀមរៀងមក របាំបុកអង្រែមុននឹងលេងសមាជិកនៃរបាំ បាននាំគ្នារៀបទ្រនឹបគ្រូជាមុនសិន ។ ទ្រនឹបនោះមានរណ្ដាប់ដូចតទៅ ៖

- ស្លាធម៌ ១ គូ — អង្ករមួយត្រឡោក
- ទៀន ៥ ធូប ៥ — សំពត់សមួយផ្ទត់
- ស្លាធម ៤ — ប្រាក់មួយរៀល និង កាស ៤

ប្រដាប់ប្រដារៀបចំនៅផ្ទះអ្នកណាជាមេរបាំ គឺជាគ្រូរាំនៃរបាំនេះ ហើយកូនរាំទាំងអស់គ្នាត្រូវទៅជួបជុំអុជធូបថ្វាយបង្គំគ្រប់ៗគ្នា មុននឹងចេញទៅលេង ។

## ៥- អំពីដើមកំណើត

តាមឯកសារដែលយើងមាន ពុំបានបញ្ជាក់ថារបាំបុកអង្រែមានដើមកំណើតមកពីប្រទេសណា ឬកើតមកពីពួកកុលសម្ព័ន្ធណាទេ ។ ប៉ុន្តែបើយើងគេសេចក្ដីសន្និដ្ឋានតាមការសង្កេតចំពោះរបៀបរាំ, ប្រដាប់គ្រឿងបន្ទរ និងសំលៀកបំពាក់ដូចមានរ៉ាយរ៉ាប់មកខាងលើ យើងយល់ថា ជាសិល្បៈរបស់បុរាណឆ្ងាយតាំងពីការព្រេងជាដើមរបស់

ខ្មែរ មុនគ្រិស្តសករាជទៅទៀត គួយ៉ាងដូចមានប្រដាប់បុកឲ្យព្រួស្ងូរ ដូចជាកញ្ចាររបស់ប៉ាំត្រុដីដែរ ប៉ុន្តែប្លែកត្រង់ដែលខ្នបនាជាវង់ មួយបែបនេះឡើង យើងយល់ថាចំនងជាទើបតែតាក់តែងឡើងនៅ សម័យក្រោយអង្គរវាំងសតវត្សទី ១៤ ដល់ ១៨ ប៉ុណ្ណោះ បើវិនិច្ឆ័យ ទៅតាមសំលៀកបំពាក់ ដូចជាប្រុសស្លៀកខោខ្លី ស្រីពាក់អាវបំពង់ វែងជាដើម ។

ប៉ុន្តែ ទោះបីជាវេទនាច្រើនជាន់ថ្នាក់ ច្រើនលើក ច្រើនគ្រា យ៉ាងណាក៏ដោយ លក្ខណៈដើម គឺប្រដាប់បន្ទរនិងក្បាច់រាំ គឺនៅតែកេរ្តិ៍ដំណែលសិល្បៈបុរាណនៃជនជាតិដើមរបស់យើង ដែលជាមូលដ្ឋាននៃអារ្យធម៌ដើមរបស់បណ្ដារដ្ឋកសិ ដែលរស់នៅភូមិភាគអាស៊ីខាងត្បូង ដែលអ្នកប្រាជ្ញសព្វថ្ងៃសន្មតឈ្មោះថា „ អារ្យធម៌អូស្ត្រូ-អាស៊ី ( Austro- Asiatiques ),, មានអារ្យធម៌បុរាណរបស់ខ្មែរយើងជាដើម ។

❋

❋ ❋

www.budinst.gov.kh www.elibraryofcambodia.org

# ៥- របាំក្ងោក

របាំក្ងោកគេប្រទះឃើញ ជាពិសេសនៅតំបន់បៃលិនដែលសុទ្ធតែជាតិកុឡារស់នៅក្នុងស្រុកខ្មែរយូរមកហើយ ហើយដែលបានរួមសញ្ជាតិជាខ្មែរអស់ទៅហើយផង ។ ពលរដ្ឋខ្មែរពួកនេះ នៅមានទំនៀមទំលាប់, សិល្បៈខ្លះៗ ប្លែកពីយើងធម្មតា, ប្រសិនជាយើងទៅពិនិត្យដល់ទីកន្លែងនោះៗ ជាក់ស្តែងដូចជាទំលាប់តុបតែងលំនៅឋាន ការលំអរូបគោម និងការគោរពសាសនាជាដើម ។ នៅបៃលិនសឹងតែទាំងអស់ សុទ្ធសឹងជាខ្មែរកុឡា ហើយគេនិយមដាំផ្កាកុឡាបយ៉ាងច្រើនគុម្ពនៅពីមុខផ្ទះ ។ ឯផ្ទះនោះសង់ដោយគ្រឿងឈើ ច្រើនតែមានកំពស់ពីដីត្រឹម ៨ តឹក ឬ ១ ម៉ែត្រប៉ុណ្ណោះ មានពនហាលពីមុខ, មានទ្វារយ៉ាងធំស្រឡះ ហើយនៅកណ្តាលផ្ទះសុទ្ធតែតុបតែងអាសនៈដំកល់ព្រះពុទ្ធរូបដ៏មានគ្រឿងសក្ការៈបូជាសន្ធឹកសន្ធាប់ជាលំអផង ។ កាលណាមានភ្ញៀវឡើងផ្ទះគេម្តងៗ ម្ចាស់ផ្ទះស្រីក្តីប្រុសក្តី រួសរាន់ចាក់ទឹកតែជូន ហើយអង្គុយទទួលភ្ញៀវនិងការរលាន់ស្រើល ។ គេឃើញទាំងស្រីទាំងប្រុសនិយមជក់បារីដែលយកស្លឹកឈើអន្ទាក់ឈើមានលាយស្លឹកថ្នាំ ហើយយកសន្ទុះ

ស្តើងនៃស្រទបស្វាមកម្ទេចពីក្រៅ មានទំហំប៉ុនៗមេដៃ ឬមេជើង មានប្រវែងប្រមាណជាមួយចំអាមឬមួយតឹក ។ នៅពេលបុណ្យទានម្តងៗ គេនិយមស្លៀកពាក់កោកោរ(១) ហើយជាធម្មតាក៏គេពុំសូវឃើញមានស្លៀកខោដែរ ។ របៀបលេងល្បែងផ្សេង ៗ ក៏ប្លែក ៗ សំរាប់ពួកគេ ដូចជារបាំក្ងោកនេះជាដើម ។ សូមបញ្ជាក់ថា របាំក្ងោកនៅប៉ៃលិននេះមិនដូចរបាំក្ងោកនៅភ្នំក្រវាញទេ(២) ដ្បិតមានលក្ខណៈសំខាន់តែត្រង់ក្ងោកប៉ុណ្ណោះ ឯនៅភ្នំក្រវាញមានយកក្ងោកទៅរួមជាមួយសត្វឯទៀត មានសេះនិងទន្សាយជាអាទិ ។ ដោយសារនៅរក្សាលក្ខណៈ ប្លែកដូច្នេះ ទើបរបាំនេះនៅមានក្បាច់ក្បូរនិងទំនុកច្រៀងជាសភាពដើម (Authentique) ទាំងអស់នៅឡើយ ដល់សព្វថ្ងៃ ។ របាំក្ងោកនៅប៉ៃលិន គេលេងតែក្នុងពេលបុណ្យចូលឆ្នាំ ដើម្បីជួយលើកដំកើងពេលនោះ ឲ្យសប្បាយរីករាយ។ ឥឡូវគេឡើង ឬមួយ លេងនៅពេលពិសេស ៗ ណាមួយ ដែលគេឃើញថាជាការគួរ ។ នៅពេលលេងរបាំនេះម្តង ៗ អ្នកស្រុកអ្នកភូមិទុកដាក់

---

១- ស្លៀកពាក់ពណ៌ស្រស់ៗតាមចំណង់ កាលណាពេញដើរគេមើលទៅឃើញចម្រុះពណ៌ឆើតឆាយ (ពណ៌ឆ្អៀក) ។

២- របាំនៅភ្នំក្រវាញយើងសង្កេតឃើញថា របាំស្លឹងទន្សោង ទៅវិញ ស្នូនអានក្នុង

www.budinst.gov.kh www.elibraryofcambodia.org

ដូចជាបុណ្យទានអ្វីមួយធំកធេងណាស់ សឹងលះបង់ការងារមួយពេល មួយគ្រានោះ មកប្រមូលប្រជុំពោមពេម ជួយលើកទឹកចិត្តផងផ្ទាំនិង សប្បាយរីករាយជាមួយផង ។

ចង្វាក់ភាពនិងរបៀបលេងនៃរបាំនេះ មានដូចតទៅ ៖

## ១- អំពីប្រដាប់ប្រដា

### ក- គ្រឿងភ្លេង .-

ប្រដាប់ភ្លេងសំរាប់ប្រគំរបាំនេះមាន ៖

ស្គរវែង.- ស្គរនេះមានសណ្ឋានដូចស្គរដៃយ៉ាំ គឺមានរាងវែង, លុងអំពីឈើដែលមានសាច់ស្វិត, ពាសស្បែកគោ និងមានបិទបាយ នៅចំផ្ទៃកណ្តាល ហើយពេលភ្លេងឲ្យតឹងស្រួលទើបវាយទៅឮល្អ ។ គេស្ពាយចំហៀងហើយវាយដោយដៃទាំងពីរ ។

ប៉ី.- ប៉ីនេះមានរូបរាងដូចប៉ីចិនបេះបិទ គឺធ្វើពីលោហធាតុមាន រាងស្តួចវែងរីកចុងជាមាត់ត្រែ ខាងគល់ស្តួចមានអណ្តាតសំរាប់ផ្លុំឲ្យឮ សូរ ដ៏មានរន្ធបិទបើកបញ្ចេញបញ្ចូលខ្យល់ជាច្រើនផង គឺអាស្រ័យ ការបិទបើករន្ធទាំងនេះហើយ ទើបមានសូរសៀងប្លែកៗឡើង ។

ស្គរតូច.- ស្គរតូចនេះ មានរាងរៅដូចស្គរផ្ចា គឺធ្វើពីឈើលុង

www.budinst.gov.kh www.elibraryofcambodia.org

កណ្ដាលតាសស្បែករោសងខាងស្រដៀងសំពៅដែរ ។ គេចងស្គរទេះព្យួរទឹងក វាយទះដោយដៃទាំងសងខាង គឺដៃទ្វេងទះខាងទ្វេង ដៃស្ដាំ ទះខាងស្ដាំ សំរាប់ឲ្យសូរជាចង្វាក់មួយ ៗ ស្របនឹងក្បាច់រាំ ។

ឆាប.- ឆាបនេះជាបន្ទះលោហធាតុមួយគូ, មូលប៉ុនហិបស្លា បំប៉ោងកណ្ដាលដូចដោះគង ហើយសិតខ្សែចងបន្ទាយ ពីមួយទៅមួយ ៗ កាលណាលេង គេយកដៃចាប់កាន់ចំត្រង់ដោះនោះម្ខាងមួយ ហើយវាយទង្គិចគ្នា ឬ សង្កៀតគ្នាឲ្យចេញសូរឆាប ៗ តិច ឬខ្លាំងតាមចំណង់ ។

ឈឹង.- ឈឹងធ្វើពីលោហធាតុដែរ មានទំហំតូចប៉ុនផ្លែក្រូចពោធិសាត់ពុះជាពីរ មានរាងក្រឡូមដូចសំបកក្រូចកែមាត់បន្តិច ៗ គេចោះទ្លុះសិតខ្សែភ្ជាប់គ្នាពីម្ខាងទៅម្ខាងដូចឆាប ហើយវាយទង្គិចគ្នាបញ្ចេញសូរដូចឆាបដែរ ដើម្បីឲ្យដាច់ចង្វាក់ ។

គងម៉ង់.- គងម៉ង់គឺគងតូចរាងមូលដូចថាស ប៉ុនមួយចំអាមធ្វើពីលោហធាតុសំប៉ែត មានដោះកណ្ដាលផតពីក្រោម ៗ គេវាយដោយ

www.budinst.gov.kh www.elibraryofcambodia.org

អន្ទង់ឈើតូចមួយធ្វើប្រហែលញញួរ ព្យួររំពេនសំរាប់គោះចង្វាក់ លោតកំ អ្នកស្រុកនោះហៅថា “ជី” ។

## ១– គ្រឿងតែង .–

ប្រដាប់តុបតែងនៃរបាំនេះ ពុំមានច្រើនគ្រឿងទេ ដែលសំខាន់ជាងគេនោះ គឺសំរាប់តែអ្នកធ្វើជាក្ងោកមួយនាក់ប៉ុណ្ណោះ, ក្រៅពីនេះ ស្លៀកពាក់តាមធម្មតាទាំងអស់ ។

អ្នកធ្វើក្ងោក មានអលង្ការសំរាប់តុបតែងខ្លួនឲ្យទៅជារូបរាងក្ងោកមែនទែន គឺមាន ៖

– ក្បាលធ្វើពីក្រដាសស្អាច់(១) ជារូបក្បាលក្ងោកមែនទែនដ៏មានកំប៉ោយនិងរោមលើក្បាលដូចក្ងោក ពណ៌ក៏ឲ្យដូចក្ងោកដែរ គឺមានពណ៌ជាក្ងោកសុទ្ធសាធ ហើយគេពាក់ក្បាលក្ងោកនេះ បន្តពីលើក្បាលមនុស្សទៅទៀត ។

– ពោ-អាវ ក៏មានពណ៌បៃតងចាស់ជាពណ៌ក្ងោកដែរ ដ៏មានសង្វារជាំត្បូងពាក់ខៀនខ្វែងលើខ្លួនទាំងសងខាង ។ អាវដៃវែង

---

១– ក្រដាសស្អាច់ គឺគេធ្វាក់ពុម្ពដីធ្វើជាក្បាលក្ងោកមួយ ហើយយកក្រដាសបកបិទគម្រួតគ្នាពីលើពុម្ពឲ្យចាស់ក្រាស់រងមានសណ្ឋានធំតូចតាមពុម្ពនោះ រួចគេវាយពុម្ពបំបែកទុកតែក្បាលក្ងោកយកមកលាបពណ៌ ។

www.elibraryofcambodia.org

វែតចុងដៃ ជើងក៏វែតចុងជើងដូចគ្នា ឯត្រង់ចង្កេះវែតតឹងមានខ្សែក្រវាត់ ធ្វើពីក្រណាត់ពណ៌ វែតពីក្រៅអាវ ។

—ស្លាប.— ស្លាបនេះជាក្រដាស ឬ កំណាត់ពាសលើឆ្អឹងឫស្សី លាបពណ៌បៃតងចាស់ជាពណ៌ក្ងោកទៀត គេចងពាក់ព្រយុង កណ្ដាលបន្ទោះស្លាបព្យួរនឹងកញ្ចឹងកខាងក្រោយ ហើយចុងស្លាប ទាំងសងខាងចងភ្ជាប់នឹងចុងដៃសងខាងដែរ ម្ល៉ោះហើយនៅពេល ដែលគេរាំលាសដៃទាំងសងខាងទៅ ស្លាបនោះក៏បក់ប៉ោយមាន សណ្ឋានដូចជាក្ងោកទទះស្លាប ។

—កន្ទុយ.— ក្រដាស ឬកំណាត់ពាសឆ្អឹងឫស្សី លាបពណ៌ បៃតងក្រម៉ៅដែរ ហើយដែលចងភ្ជាប់ពីគល់ស្លាប ត្រង់គល់ចង្កេះ មនុស្សខាងក្រោយដោយមានខ្សែចងក្រវាត់ភ្ជាប់ ជុំវិញចង្កេះនោះឯង ។ កាលណាគេរាំទៅកន្ទុយនេះក៏គ្រវាត់ចុះ—ឡើង មានចំនុចជារំ យោលកន្ទុយក្ងោកមែនទែនដែរ ។ ខាងចុងបំផុតមានចងខ្សែភ្ជាប់ មកចុងដៃផង ម្ល៉ោះហើយដល់គេបក់ស្លាប កន្ទុយនោះក៏រីកសាយ ហើយបើក-បិទឡើងតាមនោះដែរ ។

www.budinst.gov.kh www.elibraryofcambodia.org

អាស្រ័យដោយគ្រឿងប្រដាប់ច្រើនយ៉ាងនេះហើយ បានជាអ្នកពាក់ធ្វើក្បាល ច្រើនតែជាបុរស សំរាប់មានកងកាយមាំទាំទ្រនូវប្រដាប់ទាំងនេះ ។

## ២- របៀបរាំ

កាលណាក្រុមរាំជួបជុំគ្នាហើយ អ្នកវាយស្គរចាប់បន្លឺសម្លេងមុនគេ បន្ទាប់មកវង់ភ្លេងទាំងមូលក៏ចាប់ប្រគំឡើងព្រមគ្នា ។ គេឃើញអ្នកធ្វើក្បាលអង្គុយលុតជង្គង់នៅលើតុមួយខ្ពស់ ដៃទាំងពីរប្រណម្យទំនងជាអ្នកការពារធម៌ ។ បន្តិចមកលោតចុះមកដីកាងដៃគ្រវាសស្លាបហើយបក់លោស មានសណ្ឋានជាក្ងោកហើរ ។ ជើងទាំងពីរលោតបន្តើរៗ ជាចង្វាក់តាមភ្លេងជុំវិញទីប្រជុំដែលជាកន្លែងរាំនោះ ។ យូរៗម្តង ធ្វើជាលោតផ្អើលៗ កផ្អៀងផ្អងឆ្វេងស្តាំ, ដៃលោសបក់បោយរេចុះរេឡើងតម្រូវតាមចង្វាក់ភ្លេង ។

បន្តិចមកចេញព្រានព្រៃម្នាក់ដែលមានកាន់ស្នានៅដៃ និងមានបំពង់ព្រួញព្យួរពីក្រោយខ្នង ដើរលោតៗជាចង្វាក់រាំតាមភ្លេង ភ្នែកគន់រំពៃនាយគាយៗ មួយសន្ទុះធ្វើកាយវិការជាភ្ញាក់ ឈប់ងាក់ដោយយល់រូបភាពក្ងោកនៅពីមុខ ។ ព្រានទាញស្នាមកដាក់លើស្មា ផ្អៀងតម្រង់

ហើយហូតយកព្រួញមួយពីបំពង់មកផ្គងសម្រួលលើចង្អូរស្នា, បំបែរ
ចុងតម្រង់ទៅរកក្ងោកនោះ ។ ព្រានធ្វើជាដំណោះតែឲ្យព្រួញ
ធ្លាក់ទៅដីតែមិនត្រូវក្ងោកទេ ។ ព្រានសុះស្មាដោយក្ដៅចិត្តមិនបាន
ត្រូវក្ងោក រួចក៏ធ្វើជាកាយវិការដេញតាមដានក្ងោកនោះម្ដងទៀត
ហើយដែលពេលនោះ ក្ងោកនៅតែរពាំបក់ស្លាបធ្វើព្រងើយ ដួន
លោតឡើងលើគុ ដួនលោតចុះមកពំនៅដី ។ ឃើញថាពេលស្រួល
ហើយនាយព្រានក៏ផ្គងព្រួញលបធ្នូក់យ៉ាងយូរ ហើយដំណោះវែកម្ដង
ទៀតតែជ្រុះធ្លាក់ទៅដីដូចមុនទៀត ។ ព្រានបញ្ចេញកាយវិការ
អស់សង្ឃឹមសាជាថ្មី ។



www.budinst.gov.kh www.elibraryofcambodia.org

ចំណែកឯក្ងោក គេមានផ្លាស់ប្តូរបទតាមឆាករឿងដែរ គឺនៅពេលក្ងោកចេញពន់លើគុ, ដំណាក់ក្ងោកទំលើមែកឈើ, ប្រណាម្យគ្រូសែកមន្តអាគមគាថានោះ ក្ងោកលេងចង្វាក់យឺតបង្អួស ៗ ។ ដល់គ្រន់ព្រានព្រៃចេញ ក្ងោកក៏កាច់យ៉ាងញាប់ គួរឲ្យរន្ធត់ខឹងគ្រោះកាច ។ លុះដល់គ្រន់ព្រានបាញ់ខុសមិនបានការ ក្ងោកក៏ប្រែជាស្វររង្វើលម្តងទៀត តែនៅពេលព្រានបាញ់ម្តងទៀត ក្ងោកត្រឡប់ជាញាប់ឡើងវិញ លុះត្រាដល់ចុងបំផុតទើបក្ងោកលេងជាចង្វាក់ធម្មតា ។

## ៣– ប្រវត្តិរបាំក្ងោក

តាមសេចក្តីបរិយាយរបស់អ្នកស្រុកប៉ៃលិន មានតែជារឿងព្រេងនិទានប៉ុណ្ណោះ ហាក់ដូចជាការជួយផ្តល់ពត៌មានខាងការពន្យល់ពីផ្តុំនរឿងជាឈុតរបាំនេះទៅវិញ ដូចជាសេចក្តីដំណាលថា៖ មានព្រះរាជបុត្រីក្សត្រមួយព្រះអង្គ ទ្រង់ផ្ទុំលង់លក់យល់សុបិនឃើញថាមានក្ងោកឈ្មោលមួយពង់យ៉ាងល្អ ចេះចំរើនមន្តអាគមនិងទេសនាយ៉ាងពិរោះក្បោះក្បាយថ្វាយព្រះនាងទ្រង់ព្រះសណ្តាប់ ។ លុះព្រះនាងតើនឡើង ក៏ទ្រង់រំពឹងគុំព្រះចិត្តថា មិនដឹងធ្វើម្តេចនឹងបាន

www.budinst.gov.kh www.elibraryofcambodia.org

ក្ងោកដ៏ល្អឆើតឆាយនោះមកទេសនាថ្វាយព្រះនាងស្ដាប់ម្ដងទៀត ? ម្ល៉ោះហើយទ្រង់តែងជ្រប់ព្រះភក្ត្រតក្កកល់ថ្ងៃ ទ្រង់សោយទ្រង់ផ្ទំពុំបានស្រួលឡើយ ៗ កាលទ្រង់យល់ព្រះភក្ត្រព្រះរាជបុត្រីសៅហ្មងដូចនេះ ព្រះបិតាទ្រង់ត្រាស់សួរទៅព្រះរាជបុត្រី ៗ ព្រះនាងក៏ក្រាបបង្គំទូលសព្វគ្រប់តាមព្រះសុបិន និងព្រះបំណងរបស់ព្រះនាង ៗ

កាលនោះ ព្រះរាជាទ្រង់ជ្រើសរើសរកព្រានយ៉ាងជំនាញផុតគេឲ្យដើរស្វែងរកសត្វក្ងោក ដែលមានរូបឆោមល្អចេះមន្តគាថា និងទេសនាពិរោះនោះឲ្យបានយកមកថ្វាយ ៗ ព្រានម្នាក់ដែលមានថ្វីដៃលើសគេទទួលព្រះរាជបញ្ជាហើយក៏ខំស្វះស្វែងរកសព្វព្រៃទាំងអស់ ៗ ព្រានចេះតែដើរទៅ ៗ រកកលទីងអស់សង្ឃឹមទៅហើយ ស្រាប់តែព្រឹកមួយ ព្រានប្រទះឃើញក្ងោកឈ្មោលធំមួយកំពុងឈរសញ្ចប់ការនានៅលើមែកឈើ បែរមុខឆ្ពោះទៅកាន់ព្រះអាទិត្យ ៗ បន្តិចមកក្ងោកលោតចុះពីមែកឈើមកលោតរេរាំហាក់ដូចជាសប្បាយរីករាយខ្លាំងណាស់ ៗ ព្រានត្រេកអរពន់ប្រមាណ ក៏ដំឡើងស្នាបាញ់តម្រង់គាត់ដំណើរកុំឲ្យក្ងោករហើររួច ប្រយោជន៍នឹងចាប់យកមកថ្វាយព្រះរាជបុត្រី ប៉ុន្តែព្រានបាញ់ជាច្រើនលើកមិនបានត្រូវសោះ

www.budinst.gov.kh www.elibraryofcambodia.org

នាំឲ្យព្រានលបលួចចាំមើល តើហេតុអ្វីបានជាខ្លួនបាញ់មិនត្រូវ ប្រាកដជាក្អែកនេះ ជាក្អែកចេះមន្តគាថាសក្តិសិទ្ធិ ជាមិនខាន ។ មួយថ្ងៃ ពីរថ្ងៃក្រោយមក ទើបព្រានដឹងច្បាស់ថា ក្អែកនេះតែភ្ញាក់ឡើងពីព្រលឹមក៏តាំងសីលសែកមន្តគាថា ប្រណម្យឆ្ពោះទៅព្រះអាទិត្យខាងកើត លុះដល់ល្ងាចក៏ភាវនាទៀត បែរឆ្ពោះទៅលិច. មុនចូលទ្រនំដេក ។ ព្រានសញ្ជឹងហើយយល់ថា តើគិតធ្វើយ៉ាងណាឲ្យក្អែកភ្លេចចំរើនការនាមន្តគាថាតែមួយថ្ងៃ ខ្លួននឹងលបបាញ់បានជាមិនខាន ។ ថ្ងៃគម៉ក ព្រានទៅចាក់បានក្អែកញីមួយយ៉ាងស្រស់ប្រិមប្រិយពីទីដទៃមក ហើយយកទៅលែងនៅពីមុខទ្រនំលំនៅស្ថាននៃក្អែកឈ្មោលនោះ ។ ព្រលឹមស្វាងឡើង ក្អែកឈ្មោលទទះស្លាបប្រុងនឹងចាប់ផ្តើមការនាមន្តគាថា ស្រាប់តែក្រឡេកទៅប្រទះឃើញក្អែកញីដើរឆាយនៅពីមុខ ក៏កើតក្តីត្រេកមេត្រី ហើយហក់លោតចុះពីមែកឈើទៅកេនាងមយុរីដ៏ស្រស់នោះ ។ ពេលនេះហើយ ដែលក្អែកឈ្មោលចេះមន្តគាថា ត្រូវជាប់អន្ទាក់ព្រានដែលលបលួចដាក់តាំងពីពេលព្រលប់ម្ស៉ិះ ។

ព្រានចូលទៅចាប់ក្អែកបានដោយក្តីត្រេកអរ ទើបក្អែកសាកសួរថា ៖

www.budinst.gov.kh www.elibraryofcambodia.org

— ព្រានអើយ! ព្រានប្រាថ្នារូបខ្ញុំយកទៅធ្វើអ្វី? ខ្ញុំនេះ ទំលះបង់ព្រៃវៀងអស់យកមកនៅព្រៃជ្រៅប្រាថ្នាឲ្យផុតពីការសៅហ្មង និងរបរប្រមាញ់នេសាទគ្រប់យ៉ាង ហេតុអ្វីក៏ព្រានតាមមកធ្វើបាបខ្ញុំទៀត?

ព្រានពុស្សដ៏ក្លោកគ្លួអាណិតណាស់ ក៏ឆ្លើយដោយពាក្យពីរោះពិសារទៅវិញថា ៖

— ក្ងោកអើយ! ខ្ញុំមិនមែនយកអ្នកទៅសម្លាប់ទេ ខ្ញុំឃើញអ្នកជាអ្នកចេះធម៌អាថ៌ តែព្រលឹមឡើងតែងចំរើនធម៌ជានិច្ច ហេតុនេះខ្ញុំចាប់អ្នកនាំទៅថ្វាយព្រះរាជបុត្រីនៃព្រះចៅផែនដី ដ្បិតព្រះនាងយល់សុបិនឃើញក្ងោកចេះទេសនា ហើយព្រះនាងទ្រង់ចង់ទ្រង់ព្រះសណ្តាប់ធម៌ទេសនានេះ ។

ក្ងោកសើចហើយ ឆ្លើយមកវិញថា ៖

— បើដូចនោះទេ សុំអ្នកកុំព្រួយ ខ្ញុំនឹងនាំនាទៅសំដែងធម៌ថ្វាយព្រះនាងស្តាប់រៀងរាល់ថ្ងៃសីល ចាប់តាំងពីសីលនេះតទៅ(១) ។

ចាប់តាំងពីពេលនោះមក ក្ងោកតែងហិចហើរមកថ្វាយធម្មទេសនាដល់ព្រះរាជបុត្រីជានិច្ច ៗ អាស្រ័យរឿងនេះហើយ បានជាពួក

---

១- រឿងនេះ មានលំនាំប្រហែលគ្នានឹងរឿងមួយហៅ មោរជាតក មាននៅក្នុងជាតកដ្ឋកថា ទុកនិបាតវណ្ណនា ដែលជាក្ងោកនេះជាពោធិសត្វ ។

www.budinst.gov.kh www.elibraryofcambodia.org

ខ្មែរកុឡានៅប៉ៃលិន និយមលេងរបាំនេះ នៅពេលថ្ងៃសីលរៀងរហូតមក ៗ

ប៉ុន្តែ បើពោលតាមរបៀបស្រាវជ្រាវពីប្រវត្តិរបាំក្ងោកនេះវិញ ដោយលើកយកក្បាច់រាំ, គ្រឿងភ្លេងនិងសំលៀកបំពាក់មកធ្វើជាការពិចារណា យើងឃើញថារបាំនេះ គឺសេសសល់មកពីអារ្យធម៌អូស្ត្រូអាស៊ី( Austro-Asiatique ) ដូចជារបាំប្រជាប្រិយដទៃទៀតដែរ ប៉ុន្តែចំនួនជាភ្លេងចូលមកពីជនជាតិដើម ( Les Autochlones. ) ដែលនៅក្បែរខាងស្រុកទេសយើង(១) ដូចជាមានព្រៅ, តាបជាដើម ៗ តែដូចជាយើងដឹងហើយថា ជាធម្មតាពួកជនជាតិដើមជាវដ្ឋរាសីតាំងនេះ រមែងមានការទាក់ទងគ្នាយ៉ាងជិតស្និទ្ធណាស់ខាងវប្បធម៌បានជាជួនក្លាយពីយើងទៅគេ ជួនក្លាយពីគេមកយើងវិញ ៗ មួយទៀត នៅសម័យបុរាណមុនគ្រិស្តសករាជនោះ ដែនដីនៃជនជាតិតាំងនេះ ពុំទាន់កំណត់ទៀងទាត់ថាជាស្រុកណា ប្រទេសណាប្រាកដនៅឡើយទេ ដោយហេតុថាអ្នកស្រុកដើមប្រកាន់ទំនៀមទំលាប់ប្រហាក់ប្រហែលគ្នាទាំងអស់ ៗ

---

១— របាំប្រជាប្រិយនៅស្រុកចិនខាងត្បូងបំផុត មានរាំក្ងោកហើយមានសំលៀកបំពាក់ប្រហាក់ប្រហែលគ្នានឹងរបាំក្ងោកនៅស្រុកភូមា ដែលចូលមកយើងនេះដែល ។

www.budinst.gov.kh www.elibraryofcambodia.org

រីឯទំនុកច្រៀងនៃឆ្នាំនេះ ពុំទាន់មានលោយជាពាក្យខ្មែរសុទ្ធនៅឡើយ គេនៅច្រៀងជាពាក្យកុឡា តែមានន័យសុទ្ធតែជាសេចក្ដីបួងសួងប្រសិទ្ធិពរជូនដល់អ្នកស្រុក ដូចជាសុំឲ្យបានសុខចំរើន, មានភ្លៀងគ្រប់គ្រាន់ធ្វើស្រែបានផល, ជីកដីរកត្បូងបានជួបប្រទះផលល្អជាដើម ។ ក្រៅពីនេះមានទំនុកថ្វាយសព្ទសាធុការពរចំពោះព្រះក៏ជាម្ចាស់ផែនដីផង ។

❋

❋ ❋

www.budinst.gov.kh www.elibraryofcambodia.org

# ៦- របាំយីកេ

របាំយីកេមានទៅក្នុងប្រទេសយើងយូរយារមកហើយ ហេតុផល អ្នកស្រុកយើងសន្មតយកជារបាំសំរាប់អ្នកស្រុកស្រែចំការទុកទៅថែមទៀតផង ៗ នៅពេលបុណ្យទានម្តងៗ ឬពេលសំរាកពីការងារ ដូចជាពេលផុតរដូវច្រូតកាត់ជាដើម អ្នកស្រុកអ្នកភូមិតែងប្រមូលប្រជុំគ្នាធ្វើបុណ្យ ដើម្បីបានឱកាសជួបជុំគ្នាបំប៉ននូវកំឡាំងសាមគ្គីរវាងអ្នករួមស្រុករួមភូមិផង និងបានពេលធ្វើទានសាងកុសលរៀងៗខ្លួនផង ៗ បើមានពេលសំរាកផុតពីការនឿយហត់និងបានពេលជួបជុំគ្នា យ៉ាងនេះ រាំរបាំយីកេក៏ត្រូវការជាចាំបាច់សម្រាប់កំដរបរិយាកាសនេះ ម្ល៉ោះហើយអ្នកស្រុកស្រីប្រុសក្មេងចាស់តែងនាំគ្នាលបួនមកពីទីជិតឆ្ងាយ កាត់មកទស្សនារបាំនេះ ហើយប្រកបដោយសេចក្តីរីករាយពន់ប្រមាណ ៗ បណ្តាអ្នកលេងរបាំនេះសោតទៀតក៏សុទ្ធសឹងជាអ្នករួមស្រុក-ភូមិនោះដែរ ដែលជាហេតុនាំឲ្យរបាំនេះរឹងរឹតតែបានទទួលនូវប្រជាប្រិយភាពថែមឡើងទៀត ៗ ចំណេរក្រោយមក នៅស្រុកភូមិខ្លះ ដែលគ្មានរាំយីកេប្រចាំភូមិស្រុក

www.budinst.gov.kh www.elibraryofcambodia.org

ខ្ទង់នោះ គេក៏ត្រូវទៅពឹងអំពីវង់របស់អ្នកស្រុកជិតខាងមក ។ ដូច្នេះ
វង់យីកេនីមួយ ៗ ក៏ត្រូវតែរៀបចំឲ្យបានស្រួលបួលសមរម្យឡើង
ហើយថែមទាំងលេចឮកេរ្តិ៍ឈ្មោះខ្ចរទៅឆ្ងាយ ៗ ទៀតផង ។ អ្នកនាំ
យីកេសុទ្ធតែកំលោះក្រមុំ កាលបើលេចឮកេរ្តិ៍ឈ្មោះ គេឃើញរូប
សម្រស់កូនវង់របាំនេះកាលណា ក៏មានអ្នកទស្សនាចោមរោមតាម
ស្រឡាញ់ចង់បានជាគូស្រករ ហេតុនេះហើយទើបអ្នកលេងយីកេ
កាន់តែមានតម្លៃឡើង ធ្វើឲ្យអ្នកស្ម័គ្រចិត្តលេងនោះខិតខំហាត់រាំ
កាយក្នុងរបាំនេះថែមទៀត ត្រាតែបានទៅជាវង់របាំប្រកបដោយ
សិល្បៈពិតឆាយឡើង ។ ប៉ុន្តែនៅគ្រាដែលប្រទេសយើងមាន
ចលាចលក្នុងស្រុកក្នុងរវាងសតវត្សទី ១៩ ភាគខាងដើមនោះ របាំ
នេះក៏ឡត់ឡោយបន្តិចម្តង ៗ ទៅវិញ រហូតមកដល់សម័យបារាំងធ្វើ
អាណាព្យាបាលលើស្រុកខ្មែរ របាំដ៏វិចិត្រនេះ ស្ទើរតែបាត់រូប
រាងក្រោមឥទ្ធិពលវប្បធម៌នៃបស្ចិមប្រទេសតែម្តងទៅ ។ ដូច្នេះ
ហើយបានជាសព្វថ្ងៃនេះ របាំយីកេនៅសេសសល់តែដោយក្រុម ៗ
ស្ថិតនៅស្រុកឆ្ងាយ ៗ មានគ្នីគ្នាតែបន្តិចបន្តួចប៉ុណ្ណោះ ។ កាល
ពីក្រោយប្រទេសយើងឯករាជ្យក្នុងរវាង គ.ស.១៩៥៤-៥៥ របាំនេះ
ក៏បានផ្ដួចផ្ដើមកើតឡើងជាថ្មី ស្ទើរតែគ្រប់ឃុំស្រុកតាមខេត្តនានា

www.budinst.gov.kh www.elibraryofcambodia.org

ជាពិសេសស្រុកភូមិនៅតាមជនបទខ្លះ ៗ តែរបាំយីកេជំនាន់នេះ ពុំសូវបានហ្មត់ចត់ល្អទេ ព្រោះអ្នកបង្កបង្កើតពុំទាន់មានក្បួនខ្នាតត្រឹមត្រូវ ហើយបេះតែបង្កើតឡើងតាម ៗ តាមចិត្តចង់ ម្ល៉ោះហើយរវែងមានវិបត្តិផ្ទាត្តង់ខ្លះ ៗ ជាមិនខាន ៗ មិនតែប៉ុណ្ណោះនាំឲ្យអ្នកទស្សនានឿយណាយចិត្ត ត្រង់ការសម្តែងពុំបានហ្មត់ចត់នេះថែមទៀត ៗ រាំរបាំយីកេដែលបង្កើតថ្មី ៗ យ៉ាងបន្ទាន់ទាំងនេះ គឺត្រូវរលុបរលាយរូបទៅវិញអស់ទៅ ៗ ឥឡូវនេះ នៅសល់តែរាំណាដែលមានក្បួនខ្នាតគ្រូបង្ហាត់ មានបែបផែនត្រឹមត្រូវប៉ុណ្ណោះ ហើយគ្រូបង្ហាត់ទាំងនេះសុទ្ធសឹងជាអ្នកធ្លាប់រៀនជាមួយគ្រូដើម ដែលបេះទាំសិល្បៈនេះមក តាំងពីមុនសម័យបារាំងមកធ្វើជាអាណាព្យាបាលខ្មែរទៅទៀត ៗ ម្ល៉ោះហើយតម្រាប់តម្រាជាក្បួនខ្នាតរបស់អ្នកទាំងនេះតែងបានប្រាកដប្រជាត្រឹមត្រូវ បើទោះបីជាល្អៀងឃ្លៀងឃ្លាតបន្តិចបន្តួច ក៏មិនរលុបគោលដើមដែរ ៗ

អាស្រ័យហេតុនេះហើយ បានជានៅពេលសព្វថ្ងៃនេះ អ្នកស្រាវជ្រាវនិងអ្នកស្រឡាញ់សិល្បៈជាតិ បានរកឃើញគ្រូដំណាលរបាំយីកេឡើងវិញ ដែលយើងនឹងលើកយកមកធ្វើជាសេចក្តីសង្ខេបបានគ្រាន់ជាគំរូទៅថ្ងៃមុខ ដូចតទៅ ៖

www.budinst.gov.kh www.elibraryofcambodia.org

# ១- អំពីរប្រដាប់ប្រដា

## ក- គ្រឿងភ្លេង .–

តាមធម្មតាចាំយ៉េក គ្មានគ្រឿងភ្លេងច្រើនបែបទេ បើតាមក្បួនបុរាណមក មានតែស្គរមួយមុខប៉ុណ្ណោះ ហើយចំនួនស្គរក៏អាស្រ័យតាមវង់តូចឬវង់ធំ គឺថាវង់ធំបង្អស់មាន ១២ ហើយវង់តូចបំផុតត្រូវមាន ២ ៗ ដូច្នេះហើយបានជាសព្វថ្ងៃនេះ យើងប្រទះឃើញវង់យីកេមានត្រឹមតែស្គរ ២ និងស្គរ ៤ ប៉ុណ្ណោះជាភាគច្រើន ៗ

ស្គរនេះធ្វើពីឈើលុងហើយសិតឲ្យស្តើង ពាសស្បែកគោម្ខាងទេ ៗ តួស្គរមិនដូចស្គរផ្លាឬស្គរការក្បូឡើយ បែរជាមានទំហំធំជាងកម្រាស់ទៅវិញ គឺថាវង់មូលទំហំទទឹងមាត់ ០ម៤០ ទៅ ០ម៦០ ឯកម្រាស់មានត្រឹមតែពី ០ម១៥ ទៅ០ម២០ ប៉ុណ្ណោះ ៗ

## ១- ប្រដាប់តែងខ្លួន .–

ក- មុខ មុខនេះមានបែបគឺ មុខឥសី, មុខយក្ស, មុខស្វា និង មុខក្អែក សុទ្ធតែមានច្រើនសណ្ឋានផ្សេងៗគ្នា តាមលក្ខណៈរូបសម្បត្តិនៃតួតាំងនោះ គឺ :

www.budinst.gov.kh www.elibraryofcambodia.org

- មុខឥសី មុខមនុស្សចាស់ ថ្ពាល់ផត បង្កាវែង ភ្នែកខូន មានកំប៉ោយសក់ហៅថា ជដា ( រាងកន្ទុយត្រី ) ។

- មុខយក្ស មុខកាច ចិញ្ចើមក្រាស់ ភ្នែកឡោត ច្រមុះធំ មាត់ធំសំពេញញញេញចង្កូម ក្បាលមានក្បាំង ហើយរងិបរង្គុបខាងលើ ។

- មុខស្វា ជាមុខ អ្នកក្រមាប់ក្រមើម ក្បាលស្រួចមាត់ស្រួចៗ

- មុខត្លុក អ្នកកំប្លែង មាត់សើចច្រវែប ច្រមុះជ្រួញ ។



មុខទាំងអស់នេះសុទ្ធតែធ្វើពីក្រដាសស្នាប់ គឺដំបូងគេធ្វើជាពុម្ពមួយ ដោយស្មូនដី ហើយឆ្លាក់ឲ្យមានរាងជាមុខនោះ តាមលក្ខណៈគួរអង្គឲ្យស្រេច ហើយយកក្រដាសទៅបិទគម្រូដោយជ័រ ជាន់ត្រួតគ្នាឲ្យទាល់តែក្រាសរឹង រួចលាបពណ៌ទេសាសមតាមលំនាំនៃតួនាទីនោះ ស្រេចហើយទើបគេដោះចេញពីពុម្ព យកតែសំបកមកប្រើការពាក់ស៊កនឹងក្បាលមនុស្សធម្មតាដែលជាអ្នកដើរតួនោះទៅ ។

១ – ម្កុដ – ម្កុដមានក្បាច់ជុំវិញ កំពូលស្រួចសម្រាប់នាយរោង តួឯក ដើរតួស្ដេចនឹងតួទេវតា, តួខាងឯកពាក់ម្កុដដែរតែមានក្បាំងពីមុខផង ឯតួនាងដទៃទៀតមានពាក់ក្បាំងដែរតែឥតម្កុដ ។ ដែលហៅក្បាំងមានរាងខ្ពស់ចំពីមុខទាបទៅក្រោយ ហើយត្រង់ចំហៀងសងខាងភ្ជាប់គល់ត្រចៀក មានក្បាច់ឆ្លាក់សំយុងហើយព័ទ្ធឡើងលើវិញហៅថា "ចន" ចំណែកម្កុដនោះ បើតាមវង់យីកេបុរាណខ្លះ ដូចជានៅខាងខេត្តស្វាយរៀងជាដើមពុំមានពាក់ទេ, បើតួស្ដេចជានាយរោង គេពាក់ក្បាំងដែរ តែខាងមុខមានក្បាច់កញ្ចាំងញឹកជាងក្បាំងសម្រាប់តួនាងពាក់ ។ ក្បាំងទាំងនេះធ្វើពីស្បែក គឺយកស្បែកមកឆ្លាក់ហើយបិទមាសកុំបញ្ចាំង ។ ប៉ុន្តែវង់យីកេសព្វថ្ងៃ ដូចជាវង់យីកេនៅខេត្តតាកែវជាដើម គេមានយកម្កុដកំពូលស្រួចល្ខោនមកប្រើខ្លះដែរ ។

## គ– សំពត់អាវ :–

ចំពោះសំលៀកបំពាក់នៃតួនីមួយ ៗ ក្នុងវង់យីកេ សុទ្ធសឹងតែពាក់តែងប្លែក ៗ គ្នាទៅតាមរូបភាពតួនីមួយៗ គឺ ៖

www.budhist.gov.kh www.elibraryofcambodia.org

– តួស្តេច.– ត្រូវស្លៀកសំពត់ចងក្បិនពណ៌ ពាក់អាវដៃវែងពណ៌ មានសង្វារខ្វែងពីលើអាវ ស្នំ(១)ចង្កេះយ៉ាងតឹងដំ មានបន្តោងប្រឆិប ស្លាបកែ(២) ផង ។ នៅកមានពាក់សរងក ហើយនៅលើអាវត្រង់ កល់ដៃមានពាក់ស្នំដៃតាំងសងខាង ។ លើក្បាលមានពាក់ក្បាំង ប៉ុន្តែយីកេសព្វថ្ងៃមានពាក់មកុដផងចំពោះតួស្តេច ។

– តួទេវតា.– ( តួទេវតាមានសំលៀកបំពាក់នឹងអលង្ការ ដូចតួស្តេចដែរ ) ។

– តួនាង.– តួនាងស្លៀកសំពត់សំឡុយពាក់អាវដៃខ្លីខាង ក្រៅខ្លួនគេនោះបិទបាំង ដោយខាងមុខមានស្បៃ មានសណ្ឋានដូច សំពត់ពានាពាក់ឈៀងកាំម៉ែខ្មៅ ឬពណ៌ប៉ាក់ជិនខ្សែយបុរអង្កាំ ដែលផ្តុកចុងម្ខាងទៅក្រោមក្លៀកឆ្វេង, ហើយវាត់ចុងម្ខាងពាក់មក លើស្មាស្តាំ ទំលាក់ចុងទៅក្រោយ ។ ជុំវិញបំពង់ក មានពាក់សរងក ហើយទឹងធ្លាក់យោលគ្របស្មាតាំងសងខាង ទិងធ្លាក់គ្របលើដើម ទ្រូងផង ។ បន្តពីនេះមានស្បៃដែលធ្វើពីកាំម៉ែប៉ាក់ជាដូចអៀមដែរ

---

១ - ស្នំៈ គ្រឿងអលង្ការសំរាប់ក្រវាត់ ឬពាក់រឹតចង្កេះនៅភ្នំពេញគេហៅថា ចាំងផាប់ ។

២– ប្រឆិបៈ គ្រឿងតែងធ្វើពីសំពត់ពណ៌ស្រែះអង្កាំ ល្បូនិងចង្កេះ ១ សំយុងពីមុខ , ២ ទៀតបែបជាស្លាបកិន្នរនៅផ្នែងស្តាំ ។ ស្លាបកែនេះនៅភ្នំពេញ គេហៅ ផាយក្រែង ។

www.budinst.gov.kh www.elibraryofcambodia.org

លាតគ្របស្មាស្ដាំឆ្វេង ហើយក្វាក់រំកាយទៅខាងក្រោយដល់ត្រឹម គន្ទាក់អាចម៍ ដូចខ្លះស្មាឆ្វេងនៅចំហរចេញសាច់ ។ នៅក្បាលមាន ពាក់ក្បាំងដែមានក្បាច់រលេច ឯនៅលើសាច់គល់ដៃខាងឆ្វេងពាក់ស្នំ ដៃ(១) ប្រកបដោយក្បាច់កញ្ចុំ ។ កជើងមានពាក់កងដែលមានក្បាច់ សុសនិងមានកំពូលធំស្រួចចល់មុខគ្នា ។

- ត្លុយកាវ.— ពាក់មុខ, កាន់ដំបងពេជ្រដែលធ្វើពីឈើដាំខ្សែ ដាំក្បូងសត្វផ្ទុកប្រាលផ្ទៅ, ស្លៀកពាក់ខោ អាវពណ៌ដូចគ្នាច្រើន មានក្រឡាំផង ។ នៅចង្កេះមានចងប្រដាប់ដែរ តែចុងផង ។ សង្វារវែងពាក់លើទ្រូង តែឥតស្បែក ។

- ត្លុកសី - ស្លៀកដណ្ដប់ដោយស្បូវពីពារ, ពាក់មុខ ដៃ កាន់ឈើប្រត់ ស្ពាយយាម ។

- ត្លុព្រានព្រៃ— ស្លៀកខោខ្លី, ពាក់អាវដៃខ្លី ក្រមាក្រវាត់ ចង្កេះ សៀតកាំបិតនៅចង្កេះ ដៃកាន់ស្នា មានឈ្នួតក្បាល ។

- ត្លុកត្លុក.— ស្លៀកខោខ្លី អាវដៃខ្លីក្រឡា ពាក់មុខ(ត្លុកនេះ ជួនជាអាតាំងឥសី ឬជាអមាត្យស្ដេច) ។

---

១— ខ្លះហៅថាកងសាច់ ។

www.budinst.gov.kh www.elibraryofcambodia.org

– ខ្លះហោរា.– ស្លៀកសំពត់ចងក្បិន ពាក់អាវកុកត្រង់ ដៃកាន់ក្តារឈ្នួននិងដីស ។

– ខ្លះយាយម៉ប.– ពាក់អាវដៃវែង ស្លៀកសំពត់ចងក្បិនទៀត ឬសំពត់ពណ៌ស្រគាំ ។

– ខ្លះប្រពន្ធព្រាន.– ស្លៀកសំពត់សំឡុយ ឥតពាក់អាវ មានតែបង់ពុងក្រមាពណ៌ប៉ុណ្ណោះ (ដូចកាលលាបមុខបែបក់ថ្ងៃបន្តិចផង) ។

## ២– របៀបលេង(១)

ចាប់ផ្តើមដំបូងហៅថាហ៊ុមរោង(២)គឺជាគោរពថ្វាយគ្រូជាដំបូង ពុំទាន់ចូលទៅក្នុងការសម្តែងរឿងទេ ។ ការច្រៀងក្នុងពេលនេះពុំទាន់មានសេចក្តីរ៉ាប់រៀបរឿងនៅឡើយ ប៉ុន្តែជាសម្បូរជាច្រើនបទ

---

១– របៀបលេងមានការប្លែកៗគ្នាតាមក្រុម ប៉ុន្តែ យើងយកតាមឯកសារ លោកកេតរស់ នៅឃុំលំចង់ ស្រុកសំរោង (តាកែវ) នៃលសារសោរតាមបែបគ្រូអ៊ុម ធ្វើជាគំរូក្នុងទីនេះ ឃើញថាស្រួលយល់ ។

២– ពាក្យ ហ៊ុម នេះមកពីពាក្យ ហោម មានន័យថា គំនាប់គ្រូ ។

www.budinst.gov.kh www.elibraryofcambodia.org

បែបផែន ឯអ្នករាំទាំងអស់ ជាពិសេសតួនាយរោង, នាងឯក ឬតួរង សំខាន់ៗ ត្រូវនាំគ្នាចេញសម្តែងកាយវិការជាការគោរពប្រតិបត្តិ ដល់គ្រូយីកេមានបែបផែនចិត្តកាត យោលៈទៅតាមចំនុកច្រៀងដែល ហៅថា " ធ្លាំ " ផ្សេងៗគ្នា ។ សូមបញ្ជាក់ថាគ្រូយីកេជាអ្នក វាយស្គរផង ជាអ្នកបើកបទ គឺអ្នកច្រៀងដើមបទផង ៗ ដូច្នេះ បើ ឬគ្រូគេចេញបទអ្វី អ្នករាំនិងអ្នកទទួលក៏ត្រូវតែធ្វើតាមនោះទៅ ។

## គ– ហុមរោង ·–

របៀបលេងជំនួនកូនរាំស្រី-ប្រុស ត្រូវអង្គុយបត់ជើងពីក្នុងវាំងនន ហើយគ្រូជាអ្នកនាំបទនិងជាអ្នកវាយស្គរ ចាប់កោះស្គរឡើងបីបទ ៗ កោះរួច ប្រកាសអញ្ជើញព្រាយយីកេឲ្យមកចូលសណ្ឋិតលើកូនរាំ ទាំងអស់ ៗ ច្រៀងប្រកាសមួយបទ ពួកកូនរាំស្រែកថា! បន្ទរម្តង, លុះគ្រប់បីដង គ្រូក៏តាំងបាចលាជ រួចបានស្គរទាំងអស់ចាប់វាយកោះ ព្រមគ្នាជាបីបទទៀត ៗ បន្ទាប់មកស្គរវាយតាមចង្វាក់ធម្មតាឡើង វិញ កូនរាំទាំងអស់ងើបឡើងដើរចេញមកខាងក្រៅរៀបដំណើរតាម

www.budinst.gov.kh www.elibraryofcambodia.org

ចង្វាក់ស្គរ គឺប្រុសៗចេញម្ខាង ស្រីៗចេញម្ខាង លុះដល់ទៅកណ្ដាល ធាក តួឯកទាំងពីរនាក់ស្រីប្រុសត្រូវនៅចំពីមុខគេ ៗ បន្តិចមកទើប នាំគ្នាលុតជង្គង់ លើកដៃប្រណម្យរៀងខ្លួនហើយច្រៀងព្រមគ្នាថា ៖

« សូមទឹកសូមដី សូមព្រៃព្រឹក្សា សូមព្រាយអ្នកតា ចុះមកជួយ លេង ៗ

« ព្រាយហោះព្រាយហើរ ព្រាយដើរផាយដី សូមព្រាយបារមី ចុះមកជួយលេង ៗ

« ជង្គង់ខ្ញុំលុត ដៃខ្ញុំប្រណម្យ ក្រាបថ្វាយបង្គំ លោកគ្រូជាម្ចាស់ៗ

ក្នុងចន្លោះចប់ឃ្លាទីមួយៗ តែងតែមានចចេបន្ទរថា ៖

« យ៉ាវឡេ ៗ អើយមាសស្ងួនគ្របងរេ ( ថាដូច្នេះស្ទួនពីរដង ) »

បន្ទាប់ពីនេះមក តួតួនាំទាំងអស់នេះ ចូលក្នុងវិញអស់ទៅ ទើប មានសូរស្រែកខ្ទរពីក្នុងមកថា « យក្សអើ ! » ស្គរចាប់ពេចបន្ទរយ៉ាង រន្ទត់គ្រប់ជង ហើយតួយក្សចេញមកដៃកាន់ដំបងគ្រវីចាក់ក្បាច់ ដើរបីជុំ រួចចូលទៅក្នុងវិញ ៗ

តមកតួឯកស្រី-ប្រុសចេញមកម្ដងទៀត រាំចាក់ក្បាច់បង់ជាយតាមបទ

www.budinst.gov.kh www.elibraryofcambodia.org

"ផុន យ៉ាវឡេ" ហើយច្រៀងខ្លួនឯងថា ៖

"សូមលោកតាស់ៗ កុំសើចកុំយំ យីកេរ្តិ៍ខ្ញុំ ទើបនឹងរៀនថ្មី"ៗ អ្នកបន្ទរស្រែកព្រមគ្នាឡើងថា "សៃយោ ទមេពិសម័យ សុរិយោ ល្ងាចថ្ងៃ បន្ទាក់ដីនា" ៗ

- "សូមលោកតាស់ៗ កុំសើចកុំយំ យីកេរ្តិ៍ខ្ញុំ ទើបនឹងរៀនថ្មីៗ (បន្ទរ) សៃយោ ទមេពិសម័យ សុរិយោល្ងាចថ្ងៃ បន្ទាក់ដីនា ៗ

-ដៃហូតព្រះខ័ន ដើរជាន់ថ្នា សូមអស់ទេព្តា រក្សាយើងខ្ញុំៗ"

បន្ទាប់ពីនេះ គេច្រៀងបានពីរបីឃ្លាទៀត តាមពាក្យពេចន៍គេរៀបខ្លួនឯង ៗ រួចហើយ ចេញកូនកំពួនជើងច្រើនធាក់មកទៀត រត់ប្រសាចពេញធាកខ្វែងខ្វាត់គ្នា មួន-ប្រាំត្រឡប់ ទើបចូលទៅក្នុងវិញអស់ទៅ ៗ

## ១- លេងរឿង ៈ—

មុននឹងចាប់ចេញរឿងអ្វីមួយ គេត្រូវប្រកាសប្រាប់ទស្សនិកជនឲ្យដឹងថាលេងរឿងនោះ ៗ ជាមុនសិន ៗ ឯវិធីប្រកាសនេះគេធ្វើ

www.budinst.gov.kh www.elibraryofcambodia.org

ដោយខ្សារិក(១) គឺឲ្យគូឯកគួរនៃចេញមកកាច់បាច់ក្បាច់បីបទ រួចលុតជង្គង់ព្រមគ្នា លើកដៃសំពះឆ្ពោះមកអ្នកមើល ហើយច្រៀងថា ៖

..យើងខ្ញុំផ្ទាប ទៅលោកដើមការ សូមលោកមេត្តា អត់ទោសឲ្យផង យើងខ្ញុំចាត់ចែង ថ្វាថ្វៃផងទំនង ដំណើរដើមទង រឿង(២)..។

ប្រកាសឈ្មោះរឿងរួចស្រាម ក្បួនកាត់ចូលក្នុងអស់ ទើបចាប់ចេញគូឯក(៣)ប្រុសឬស្រីតាមដំណើររឿង ។ ប្រសិនជាគូឯកប្រុសត្រូវកាំដៃចាំងពីក្នុងដំណើរចេញពីក្នុងឆាក តែបើគូឯកស្រីវិញត្រូវកាំតែដៃម្ខាង ហើយដៃឆ្វេងប្រត់ចង្កេះ ដើរដំណើរញឹកញ៉ាក់ៗ ។ កន្ទុយភ្នែកបាញ់ឆ្ពោះទៅអ្នកទស្សនា រួចគមកអ្នកពោលឬគ្រូបើកបទកំចាប់ផ្ដើមរាប់រៀបឡើងពីដំណើររឿង ដូចមានពាក្យថា ៖

---

១— របៀបចេញរឿងនេះក៏មានច្រើនបែបដែរ តែក្នុងនេះយើងយកតាមឯកសាររបស់លោក ម៉ក់-ម៉េង នៅអង្គការសោម ( តាកែវ ) ព្រោះឃើញថាសមរម្យ ។

២— ត្រង់នេះត្រូវបន្ថែមឈ្មោះរឿងដែលគេត្រូវលេង ។

៣— គូឯកទាំងប្រុសទាំងស្រី មានខ្លះគេហៅថា នាយរោង ក៏មាន ។

www.budinst.gov.kh www.elibraryofcambodia.org

កាលហើយកាលនោះ... ជាដើមបទ ។

បន្តពីនេះទៅ ភាគសម្តែងរឿងក៏ចេះតែមានឡើងបន្តបន្ទាប់គ្នា ។ ប៉ុន្តែ ដើម្បីឲ្យបានច្បាស់លាស់បន្តិច យើងលើកយករបៀបសម្តែងក្នុងភាគសំខាន់ៗ មកអធិប្បាយ ដូចជា ភាគព្រួយសៅសោក ភាគសប្បាយរីករាយ ភាគប្រយុទ្ធ និង ភាគថ្លែងមនោសញ្ចេតនា, .. ។ ប៉ុន្តែ ដោយរបៀបសម្តែងអំពីភាគនីមួយៗនេះ ផ្តេកផ្តួលទៅតាមចំនុកច្រៀងនោះ យើងបញ្ចូលសេចក្តីអធិប្បាយនេះ រួមជាមួយចំនុកច្រៀងតែម្តង ។

## ៣– ចំនុកច្រៀង នឹង របាំ

ក្បាច់រាំនិងចំនុកច្រៀងមានច្រើនបែបណាស់ តែយើងលើកយកមកតែខ្លះៗ គឺក្បាច់ណា ចំរៀងណា ដែលសំខាន់ៗ ល្មមយកជាគោលឧទាហរណ៍បានតែប៉ុណ្ណោះ ។ ប៉ុន្តែក្នុងបណ្តាបទច្រៀងរាំនីមួយៗ គេចែកចេញជាពីរផ្នែក គឺ ៖

www.budinst.gov.kh www.elibraryofcambodia.org

បែបផ្តើមបទ ហៅថា "ឆ្សាំ" សម្រាប់ពេលចាប់បទនីមួយៗ ត្រូវតែច្រៀងឡំាជាមុន ឡំានេះមានច្រើនបែប តាមអ្នកបងាំថា. មានដល់ទៅជាង ៤០ ប៉ុន្តែអ្នកលេងយីកេសព្វថ្ងៃ ច្រើនយកតែជាង ២០ ប៉ុណ្ណោះមកច្រៀង ហើយឈ្មោះឡំានេះ គេច្រើនសំគាល់ ហៅតាមពាក្យខាងដើមឃ្លា ។ ឧបមាជាបទផ្តើមឡើងមានពាក្យថា ៖ ណោងកិសរ... ធុងយ៉ាវឡេ... ឬថា ការវេយួនសា... ដូច្នេះ គេក៏សន្មតហៅថាបទ " ណោងកិសរ, ធុងយ៉ាវឡេ ឬការវេយួនសា " ទៅ ។ រីឯចំនុចក្នុងឡំាមានសេចក្តីច្រើន តែពុំសូវជាពាក្យខ្មែរទេ ។ ឧទាហរណ៍ដូចជាបទ « ការវេយួនសា » មានសេចក្តីថា ៖

« (១) ឧការវេយួនសា ស៊ីរិកាសញ្ញាន់ រទត់អស់អត្ថ ការវេ យួនសា សៃយោ ... » ។

២– បែបច្រៀងកាយសេចក្តី ឬកាយចំនុកហៅថា « ក្រើ ឆ » ។ សេចក្តីយ៉ាងណាក្នុងចំនុក(Parole)នេះ ពុំមានកំណត់ទុកស្រាប់ ។ ដូចជាឡំាទេ គឺអាស្រ័យទៅលើអ្នកច្រៀងចេះបញ្ចេញបញ្ចូល

---

១- ចំនុកនេះយកតាមសេចក្តីរាយការណ៍របស់លោក ទេព រស់ សមាជិកធ្វើយធ្លងនៃ ក្រុមជំនុំទំនៀមទម្លាប់ នៅស្រុកសំរោង ខេត្តតាកែវ ។

www.budinst.gov.kh www.elibraryofcambodia.org

យ៉ាងណាស្រេចលើខ្លួនចុះ ឲ្យតែនិយមទៅតាមបទ (Air) ដែលឡាំគេបានតម្រូវទុកមកស្រាប់នោះ ៗ អាស្រ័យហេតុនេះហើយ បានជាអ្នកស្ដាប់ឮគេច្រៀងតែងជាប់ចិត្តខ្លះ មិនជាប់ចិត្តខ្លះ ដោយសារតែអ្នកច្រៀងនោះប្រសប់រៀបសេចក្ដី ឬមិនប្រសប់នោះឯង ៗ

បន្ទាប់ពីច្រៀងបានមួយឃ្លា ៗ ចម្រៀងយីកេច្រើនមានទំនុកបន្ទរផង ឯពាក្យបន្ទរនេះ ក៏មានក្បួនចងទុកស្រាប់ដូច „ឡាំ„ ដែរ គឺថាបើប្រើឡាំណា ត្រូវបន្ទរតាមបែបឡាំនោះជាគូគ្នា ប៉ុន្តែមានឡាំខ្លះក៏គ្មានបន្ទរដែរ ៗ

រីឯក្បាច់រាំ ក៏អាស្រ័យទៅតាមឡាំនេះដែរ បានសេចក្ដីថា បើចេញឡាំបទណា អ្នករាំត្រូវចាក់ក្បាច់តាមនោះ ៗ ទៅពេលសព្វថ្ងៃ គេប្រើច្រើនតែចំនួន ១០ [១] ក្បាច់ប៉ុណ្ណឹង គឺ៖

មាន ៦ ក្បាច់សំរាប់បើកឆាក មានឈ្មោះក្បាច់ផ្សេងៗគ្នា គឺ៖

— ក្បាច់ថ្វាយបង្គំគ្រូ ១ ក្បាច់ ច្រៀងបទ ម៉ានីភេ ;
— ក្បាច់ហ៊ុមរោង ១ — ដ — ណោងអើយម៉ាឌ;
— ក្បាច់រាំហៅគ្រូ ១ — ដ — ធុងយ៉ៅឡេ
— ក្បាច់រាំថ្វាយគ្រូ ៣ — ដ — សៃរយ៉ា, សាធុមិកា, អេរ៉េង ៗ

១— តាមសេចក្ដីរាយការណ៍របស់លោក កែវ គុណ សមាជិកធ្វើបាឡេតនៅក្រុមគិង ៗ

www.budinst.gov.kh www.elibraryofcambodia.org

មាន ៦ ក្បាច់សំរាប់រាំរឿង មានឈ្មោះផ្សេងៗ តាមឈ្មោះបទច្រៀង គឺ ៖

- ណោកពិសាក
- កន្ត្រៃរើយ
- សុរិយ៉ន
- ពិសាំសពេញ
- សុរិយាល្ងាចថ្ងៃ
- បទជើត

ក្នុងបណ្តាបទទាំងនេះ យើងរាប់គ្រាន់តែធ្វើជាគំរូប៉ុណ្ណោះ ឯបទផ្សេងទៀត ដែលនៅតែយើងគេចេះចាំច្រើនជាងនេះ, គេក៏ប្រើបានតាមការប៉ិនប្រសប់របស់គេទៅទៀតដែរ ៗ បានជាមានកំណត់មិនទៀងយ៉ាំងហ្នឹង ដោយហេតុអ្នកចេះចាំជាគ្រូយកគេទាំងអស់ ពុំមានក្បួនតម្រាជាលាយលក្ខណ៍អក្សរទេ មានត្រឹមតែការចាំមាត់ប៉ុណ្ណោះ ម្ល៉ោះហើយរបៀបបែបបទក៏តែងតែឃ្លៀងឃ្លាតទៅជាធម្មតា ។

បន្ទាប់ទៅទៀតនេះ យើងលើកយកឆាកសំខាន់ ១ខ្លះ ក្នុងបណ្តាឆាកសំខាន់ទាំងឡាយ មកអធិប្បាយជាឧទាហរណ៍ មាន ៖

១– ឆាកនិកសព្រាត់ប្រាស ( កំសត់ = Scène de drame )

www.budinst.gov.kh www.elibraryofcambodia

២— ឆាកផ្ដាះផ្ដូន (Scène d'amour)

៣ – ឆាកប្រយុទ្ធ (Scène tragique)

ឆាកទាំងបីនេះ មានការបំពេញកាយវិការ និងទំនុកបទចម្រៀង ប្លែកពីគ្នាដូចតទៅ ៖

១– ឆាកឆក់សព្រាត់ប្រាស .—

ត្រូវប្រើបទវៃងបង្អួស ។ តាមសេចក្ដីឲ្យការណ៍របស់ លោក ទេព-រស់ ថាគេរាំក្បាច់បទទំនួញវៃង មាន " ជ្ងាំ " ថា ៖

" ក្រឡាទី ក្រើនទី ក្រៀងក្រឡាទីអាថា ខរណាក្យក្រា ឆា! ខរណាណាហើយ "

ទិនមានទំនុក " ក្រើង " ថា ៖

" អាសូរអង្គឯង ថ្លៃងខ្ញុំកូនក
ទោរទឹមសុរិយា បន្ទាបសុរិយគ្គ ។
កោតចិត្តស្វាមី ពេកក្រៃកន្លង
ប្អូនគ្មានទុសគ្គង ស្ដេចឲ្យសម្លាប់ ។ល។(១)

តាមឯកសារជាពត៌មានពីលោក កែវ-គុល ជាសមាជិកយើង

---

១— ទំនុកនេះ ទំនងជាលេងរឿងព្រះលក្ខិណវង្ស ត្រង់តាព្រាហ្មណ៍កេសរយំសោក ដោយត្រូវស្វាមីឲ្យពេជ្ឈឃាតនាំទៅសំលាប់ព្រោះជឿពាក្យក្លែងតាមយំស៊ុំ ។

www.budinst.gov.kh www.elibraryofcambodia.org

ជាត្រូវច្រៀងបទ " តិសុាំ ,, ដែលមាន " ឡាំ ,, ថា ៖

— " តិសុាំសពេញ អឺងអើយ! ទុមេត្យគ្រា កាវ៉ាអើយវ៉ាជីង ។

ទិងមាន " ក្រើន " ថា :

" កាត់ព្រៃស្បូវស្បាត   ពុំពង់បាទា

ស្ដេចយាងផ្លូវណា   ឲ្យយាងផ្លូវប្អូន ,, ។ ។

ក្នុងពាក្យទិកាសនេះ អ្នករាំយោលខ្លួនយឺត ៗ ធ្វើមុខស្លូត ដៃទាំងពីរពត់ទន់ភ្លន់ ដើរឈានមួយ ៗ តាមក្បាច់រង្គើលៗដែរ ។

២— ពាក្យផ្ដោះផ្ដង .—

ពាក្យនេះត្រូវប្រើបទយ៉ាងរហ័សរហួន ដែលបង្ហាញអាការៈរួសរាយសប្បាយ ទឹកមុខញញឹមញញែម ៗ តាមសេចក្ដីឲ្យការណ៍របស់លោក ឌេត-ឌស់ ជាសមាជិកយើង ជាត្រូវច្រៀងឡាំ " អាតិវ៉ៃ " ដែលមានសេចក្ដីថា ៖

" អាតិវ៉ៃ យ៉ួនសា ហៃ អាតិវ៉ៃ កាដឹកអាវ៉ង អឺងអឺយការីង ការីង ,,

មានសេចក្ដីថា " ក្រើន " ថា ៖

www.budinst.gov.kh www.elibraryofcambodia.org

ប្រុស

" បងដើរមាត់ព្រែក ឮខ្នុកភាយំ
បងដើរជើងភ្នំ ឮសេកស្រដី ៗ
ឮមួយមាត់សត្វ ឮមួយមាត់ស្រី
ឮសេកស្រដី ដូចស្រីហៅបង ៗ

ស្រី

សេកចូលសំបុក កុកទំដើមត្រើល
លោកអើយជួយមើល ថាឮខ្ញុំហៅ
អ្នកណាខិងអាប គ្រឡាបវាទៅ
បើឮស្រីហៅ ហៅពីកាលណា ៗ "

កាយវិការក្នុងពេលច្រៀងបទនេះ អ្នករាំបញ្ចេញមុខប្រឹមប្រិយ កន្ទៀងផ្អង, ហើយតួប្រុសធ្វើជាដើរគៀងមកខាងតួស្រីឈរ រួចតួស្រីដើរចេញ ធ្វើបែបជា ងរបន្តិច អៀនបន្តិច ៗ

៣ - ឆាកប្រយុទ្ធ .–

ឆាកនេះ កូនរាំត្រូវមានកាយវិការរញ្ជើបរញ្ជាលជាខ្លាំងដូចជា មានកាន់ដំបងនៅដៃរៀងខ្លួន ៗ ក្បាច់ក៏ឲ្យចង្វាក់ យ៉ាងញាប់គ្រឹក

www.budinst.gov.kh www.elibraryofcambodia.org

ស្មៀម ឬមានកន្ទល់ដូចម្ដេច កាលបើឮថ្នាំនេះភ្លាម ចិត្តនោះក៏រីកកាយឡើងមួយរំពេច ។

អាស្រ័យហេតុនេះហើយ បានជាហូតដល់ពេលសព្វថ្ងៃនៅតែមានការនិយមថ្នាំនេះរហូតមក មិនអស់ដម្លៃសោះ តែយើងស្ដាយបន្តិចត្រង់អ្នកលេងថ្នាំនេះសព្វថ្ងៃ ពុំសូវគិតផ្ចិតផ្ចង់ឲ្យត្រឹមត្រូវតាមតម្រាយដើម ដូចជាពុំគិតពីសំលៀកបំពាក់ និងកំពីក្បាច់ក្បូនតាក់តែង ឬប្រើចង្វាក់បទជាដើម ។ កាលណាបើប្រហែសធ្វេសយូរ ៗ ទៅក្បូនខ្នាតក៏កាន់តែបាត់បង់បន្តិចម្ដង ៗ រីឯសម្រស់លំអនៃសិល្បៈក៏នឹងរឹតតែសាបរលាបទៅជាមួយដែរ នាំឲ្យថយទូវតម្លៃជាលំដាប់ ។ ហេតុនេះ ដើម្បីកត់ទុកនូវគោល ១ ខ្លះសំរាប់ជាការបង្ហាញទៅថ្ងៃមុខ យើងសូមលើកយកសេចក្ដីសង្ខេបផ្សេង ១ ស្ដីពីរបាំឆៃយ៉ាំនេះ មកអធិប្បាយទុកក្នុងទីនេះ អាស្រ័យតាមឯកសារទាំងប៉ុន្មានដែលមាននៅក្នុងក្រុមជំនុំយើង(១) ។

ឯសេចក្ដីពណ៌នាការណ៍នេះ មានដូចតទៅ ៖

---

១– ឯកសារលេខ ២២.០០៩, ៦៨.០៥៥, ៣៥.០០៩ និង ៦៨.០៥៦ ដែលដឹកលំនៅក្នុងក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ។

# ១– អំពីប្រដាប់ប្រដា

ប្រដាប់ប្រដាសម្រាប់ប្រកបសិល្បៈនេះ បែកចេញជាពីរផ្នែក គឺ គ្រឿងភ្លេង និង គ្រឿងតែងកាយ ៖

## ១– គ្រឿងភ្លេង .–

គ្រឿងភ្លេងនៃអាយ៉ៃ មិនមានអ្វីច្រើនឡើយ គឺមានតែក្រាប់-ឈើមួយគូ, ឆាបធំមួយ, រគាំង (គងម៉ង់) មួយ និងស្គរបួន[1] ។ ប្រដាប់ទាំងនេះមានទ្រង់ទ្រាយនិងរបៀបធ្វើដូចតទៅ ៖

ក្រាប់.– ធ្វើពីបន្ទះឈើខ្លឹម ២ បន្ទះ មានឈើក្រកោះ, បេង ឬគ្រញូងជាដើម ឬគល់ឬស្សីក៏បាន ។ បន្ទះឈើនេះមានទំហំប្រមាណទទឹង ០ម០៥ បណ្ដោយ ០ម១៧ ឯកម្រាស់ ០ម០២[2] ។ គេកាន់បន្ទះឈើនៅដៃម្ខាងមួយ ហើយវាយតាមចង្វាក់ស្របជាមួយក្បាច់លោតតាក់តូក ។

ឆាប.– ជាបន្ទះលោហធាតុមួយគូ ( ដូចមានអធិប្បាយហើយក្នុងរបាំរាំក្បាក ) ។

---

១ តាមសេចក្ដីរាយការណ៍របស់លោក ខ្លង រ៉ូប សមាជិកឆ្លើយឆ្លងនៅឃុំអង្គាញ់ ( តាកែវ ) តាមការលេងត្រឹមចំនួន ២ ឬ ៣ បានដែរ ។

២ ក្រាប់នេះ មានខ្លះកាលគេយកឈើទូលប៉ុនកៃតិចៗពីរកង់មកវាយក៏បានដែរ ។

www.budinst.gov.kh www.elibraryofcambodia.org

គគាំង ឬ គងម៉ង់,– ធ្វើពីបន្ទះលោហធាតុមានសណ្ឋានមូល ប៉ុនចានទៀប ឬ គ្របថាស ហើយមានដោះប៉ោងកណ្ដាល ផតពីក្រោម និងមានកណ្ដាប់តែមជុំវិញ ៗ គេចងខ្សែកាន់យួរ ហើយវាយដោយអន្លូងឈើ ធ្វើដូចដាញ់ញោរ ៗ

ស្គរ.– ស្គរដៃយ៉ាំមានទ្រង់ទ្រាយប្លែកពីស្គរផងទាំងពួង គឺលុងឈើទ្រវែង មានបណ្ដោយប្រមាណមួយម៉ែត្រ ឬ ជាងមួយម៉ែត្របន្តិច មានរន្ធទម្លុល ពាសស្បែកតែម្ខាង ៗ ត្រង់មុខពាសស្បែក មានទទឹងមាត់០ម ៣០ បន្ទាប់មានកន្លែងជាក្បាលធំកំប៉ោងរួចតទៅទៀត គឺស្ដួចតាមស្រួលរហូតទៅដល់ក ទៅសល់ទំហំស្មើរតែមួយចាប់ តែដល់ចុងបំផុតបែរជារីកឡើងវិញដូចមាត់ត្រែ, ទៅចំហរឥតមានពាសស្បែកទេ ៗ ស្បែកដែលពាសស្គរដៃយ៉ាំ គឺស្បែកគោយកមកសន្ទឹងតែតឹង ហើយបោះកន្ទាស់ឈើភ្ជាប់នឹងស្គរយ៉ាងមាំ ៗ ត្រង់ស្នាមបោះកន្ទាស់នេះ មានចងរំកាយក្រណាត់សំពត់ពណ៌, ច្រើនតែពណ៌ក្រហម, ព័ទ្ធជុំវិញជាលំអផង ៗ ដូច្នេះនៅពេលវាយស្គរបាក់ក្បាច់ទៅ រំកាយនោះក៏បក់បោយគួរឲ្យគយគន់ៗ មានខ្សែត-ចោះក្រងសំប៉ែតចងពីក្បាលទៅចុងស្គរសម្រាប់អ្នកវាយព្យួរនឹងស្មា ៗ

www.budipst.gov.kh www.elibraryofcambodia.org

## ២– គ្រឿងស្លៀកពាក់ ·–

សំលៀកបំពាក់តាមនិយមពីដើមមក អ្នករបាំឆៃយ៉ាំ ត្រូវស្លៀក សំពត់ចងក្បិនពណ៌ ពាក់អាវដៃខ្លី វៀលកធំបន្តិចតាមបែបអាវខ្មែរ-បុរាណមានសន្ទះឡេវបី ហើយស៊កចុងអាវទៅក្នុងចង្កេះសំពត់ ។ សំពត់នោះ ស្លៀកឲ្យមានផ្នត់ធំបន្តិចទំលាក់ទៅមុខ ហើយមាន ក្រវាត់ក្រមាពណ៌នៅចង្កេះទំលាក់ចុងទៅចំហៀងខាងឆ្វេង ។ ឯ ពណ៌សំរាប់សំលៀកបំពាក់នេះ មិនកំណត់ទេ ស្រេចហើយនឹង ការចូលចិត្តរបស់ក្រុមនិមួយៗ ។ ក្រៅពីនេះ មានមុខត្លុក សំរាប់ អ្នកកាន់គងម៉ង់, អ្នកកាន់ក្រាប់ ឬអ្នកវាយស្គរណាម្នាក់ពាក់ចេញមក តាក់ក្បាច់ឡកដាក់គ្នា ។

## ៣– គ្រឿងរណ្តាប់គ្រូ ·–

ប្រដាប់សំរាប់ថ្វាយគ្រូ គ្មានអ្វីជាធំដុំទេ គឺមានតែទៀន ៨ ធូប ៨ ស្លាធម ៤ ទឹកអប់ ២ កែវ តែប៉ុណ្ណោះ ។ មុននឹងចាប់ លេង គ្រូឆៃយ៉ាំតាំងទៅអុជធូប ហើយនិយាយសំបូងសួងគ្រូ អញ្ជើញគ្រូមកសណ្ឋិតនឹងអ្នកលេងទាំងអស់គ្នា ។

www.budinst.gov.kh www.elibraryofcambodia.org



## ២- របៀបលេង

### ១- ការរៀបវង់ .-

ការរៀបចំរាត់វង់ជាកន្លែងលេងរបាំឆៃយ៉ាំមានពីរសណ្ឋាន គឺ ១ សំរាប់ទីវាល ឬកណ្ដាលចំណោមមនុស្សក្នុងទីវាល និង ១ ទៀត សំរាប់កន្លែងមានពេនល្មមចាត់ជាធាតុបាន ។ ចំពោះទីវាល អ្នកលេងឆៃយ៉ាំតាំងពីបុរាណ ឈរជុំគង់ជារង្វង់មូលមួយ ទុកចន្លោះកណ្ដាលឡើងធំបន្តិចសំរាប់លោតតាក់ក្បាច់ហៅថា « ទ្រូកឆៃយ៉ាំ »

www.elibraryofcambodia.org

ឲ្យបានទូលាយ ។ ឯអ្នកមើលតាំងប៉ុន្មាន គេឈរព័ទ្ធជុំវិញពីក្រៅវង់ ។ ចំពោះកន្លែងដែលមានរោងជិតជិតវិញ[១] គេអាចរៀបជាថាកប្រហែលគ្នានឹងថាកល្ខោនដែរ ។ បើមានកន្លែងស្រួលដូច្នេះ ត្រូវអ្នកលេងតាំងប៉ុន្មានឈរជួរតម្រៀបគ្នាជាកង់កោងបន្តិច បែបជាអឌ្ឍមណ្ឌល (Demi- cercle) ឲ្យអ្នកទស្សនាមើលឃើញយ៉ាងស្រួល ។

## ២– ការបាក់ក្បាច់ (ឡក).–

ដូចជាស្គរស័ព្ទដែរ ប៉ុន្តែយ៉ាំមិនសំខាន់ត្រង់ស្គរសំនៀងធំពីរោះមនោរម្យទេ គឺសំខាន់ត្រង់ក្នុងកំប្លែង លោតញាក់តាមភ្លេងយ៉ាងណាឲ្យតែកើតជាបរិយាកាសរីករាយ គឺទុកជាល្អប្រពៃហើយ ។ ដំបូងអ្នកកាន់ដាបដែលជាអ្នកផ្ដើមចេញទៅកណ្ដាលវង់ ហើយបាច់ញាក់មុខ-មាត់ ដែលគូរស-ខ្មៅ ឬ ពាក់មុខ បែបក្រមាប់ក្រមើម ងាកឆាយឆាយ ដើរដេរអង្គុញផ្ដង់ តួចធ្វើជាដើរស្ទឹតហើយលោតជាមួយជំហើរលោតៗ តាមចង្វាក់ស្គរដែលវាយស្មើៗគ្នា ។ ដៃទាំងពីរទោះបីជាកាន់អ្វី ក៏ត្រូវតែកាច់កែតាមភ្លេងជាមួយនឹងបង្កេះដែរ ។

---

១– របៀបលេងក្នុងរោងនេះ ទើបតែលេចឃើញមាននៅគ្រាបច្ចុប្បន្ននេះទេ ឯពីដើមគេលេងតែកណ្ដាលវាលវាលទំនេរ ។

www.elibraryofcambodia.org

បន្តិចទៅមានអ្នកគួរមុខឬពាក់មុខម្នាក់ទៀតចេញមកជាដៃគូ ឡុកជាមួយគ្នា ហើយធ្វើបែបជាចាក់ក្អៀលជន្ទួជទ្រូញពួកអ្នកដទៃទៀត។

## ៣- ទំនុកច្រៀង

ដំបូងបំផុតអ្នកកាន់ឆាបតែស្រែកថា "យក្សហ្អ! អ្នកចាំងអស់ទទួលជាហ្អ!" ឯស្គរ, ក្រាប់, រគាំង ក៏ត្រូវវាយជាមួយទឹងស្គរ បន្ទរថា យក្សហ្អ ចាំងបីដងនេះដែរ ៗ រួចហើយស្គរក៏ចាប់ផ្តើមជាបង្ហាក់ធម្មតា មួយសន្ទុះមកទើបគេចាប់ស្រែកថា ៖

– ហៃយោម៉ាស្កាត់ (បន្ទរ) ហៃយ៉ាត់ម៉ាស្តី ៗ

– មេម៉ាយកូនពីរ (បន្ទរ) ស្អាតហើយសមផង ៗ

ហើយស្រែកព្រមគ្នា "ហ្អេ! ហ្អិ!" បីដង ៗ ឈប់ស្រែកមួយសន្ទុះ ទើបស្រែកតទៅទៀតថា ៖

– ឯណាហើយ? ឯនេះទេ! ឯណាហើយ? ឯនេះទេ! ល្អមើលកូនគេ? គេមានប្តីហើយ! ហ្អេ! ហ្អិ!!!(១)

ក្រៅពីនេះ នៅមានទំនុកដទៃច្រើនទៀត តាមទំនងដែលគេចេះចាំបូកគ្នា ឬមួយគេនឹកឃើញថា ៗ ឡើងដោយខ្លួនឯងទៅក៏បាន ៗ

---

១– ទំនុកមានច្រើនយ៉ាងណាស់ តែសុទ្ធតែគ្មានបទពិរោះពិសារទេ គ្រាន់តែស្រែកៗ ប៉ុណ្ណោះ ។

www.budinst.gov.kh www.elibraryofcambodia.org

## ៤- ប្រវត្តិនៃយ៉ាំ

តាមឯកសារដែលយើងមានក្តី តាមការសាកសួរដល់វង់ភ្លេងនៃយ៉ាំផ្ទាល់ក្តី ពុំសូវបានពតិមានច្បាស់លាស់គួរឲ្យយកជាការបានច្រើនជាក់តែងឡើយ ។ ហេតុនេះ ការស្រាវជ្រាវរកប្រវត្តិនៃយ៉ាំនេះ ពិតជាស្ថិតនៅក្នុងភាពពុំទាន់ច្បាស់មែនទែននៅឡើយទេ ប៉ុន្តែបើនិយាយតាមសេចក្តីពិនិត្យ ហើយធៀបផ្ទឹមជាមួយប្រវត្តិសាស្ត្រវិញ យើងពិតជារកឃើញជាខ្លះ ល្មមលើកយកមកបំភ្លឺបានជាគតិគ្រាន់នឹងជួយអ្នកស្រាវជ្រាវតៗទៅឲ្យរកឃើញការពិត ។

ការដែលសន្និដ្ឋានបានខ្លះនោះគឺ ៖ យ៉ាំនេះ ប្រាកដជាមានសំណល់ សល់មកពីការធ្វើមិតាស់របស់មនុស្សដើម ជាពិសេសពពួកអ្នករស់នៅលើទឹកដីខ្មែរនេះឯង ។ ព្រោះជាធម្មតាតែកាលណាមនុស្សមានកំណើតឡើង មនុស្សក៏ត្រូវការបាំបាច់នឹងសិល្បៈភ្លាមដែរ តែសិល្បៈដើមដំបូងនុ៎ះ មនុស្សយើងពុំទាន់បាននឹកឃើញបង្កើតឲ្យប្លែកៗ ជាក្បាច់ក្បូរបែបបទវិសេសវិសាលដូចសព្វថ្ងៃនេះទេ គឺមនុស្សនៅនិយមតាមលក្ខណៈដើមរបស់ខ្លួនជាដរាប ។ បានសេចក្តីថា បើកាលនោះមនុស្សមានទម្លាប់ធ្វើបុណ្យណា យ៉ាងណា សិល្បៈ

www.budhist.gov.kh www.elibraryofcambodia.org

គឺចេញមកបែបយ៉ាងនោះ ៗ ដូច្នេះហើយ បានជារបាំឆៃយ៉ាំ ប្រកបដោយក្បាច់លោតហក់ កញ្ឆាត់កញ្ឆេងខ្លួនប្រាណ និងស្រែកបែបផ្អើលៗ ឲ្យសមទំនងតាមមនុស្សដែលពុំទាន់មានវប្បធម៌នៅឡើយ ៗ យើងជឿមួយចំណែកទៀតថា កាលបើកើតបានជាក្រុមជាបែបសិល្បៈមួយឡើងហើយ, បែបបទនេះក៏មិនមែននៅនឹងដដែលៗឡើយ គឺថាមុខជាមានវិវត្តន៍ជាដរាប,តាមសម័យកាលនៃមនុស្សជាតិដែលតែងតែប្ដូរឡើងបន្តិចម្ដងៗ ជាលំដាប់ ៗ ដូចជាដំបូង មនុស្សគ្រាន់តែបេះលោតៗ ពុំចាំបាច់គិតពីក្បាច់ឲ្យត្រូវតាមក្បួនខ្នាតអ្វីទេ ឯសម្រែកវិញគ្រាន់តែបន្លឺ អូ-អេ-អា ពុំបាច់ទាមទារឲ្យមានន័យថាអ្វីឡើយ គឺគ្រាន់តែឲ្យផុះសេចក្ដីសប្បាយរីករាយប៉ុណ្ណោះ ៗ ចំណោតមក គ្រាដែលមនុស្សបេះតាក់តែងសិល្បៈឲ្យមានក្បួនខ្នាតឡើង ឆៃយ៉ាំក៏មានជាបន្ទាក់បទសម្រាប់ទៀត មានប្រដាប់ភ្លេងឲ្យសព្ទស្នូរស្របគ្នាជាបែបបទ មានសំលៀកបំពាក់គាត់តែផិតផិតដែរ ៗ លុះមកដល់គ្រាសព្វថ្ងៃ, ប្រហែលជាមួយសតវត្សមកហើយ, របាំនេះក៏ប្ដូរស្នូរស្រែកឲ្យមានន័យខ្លះឡើងទៀតពាក់ឲ្យសមតាមកាលសម័យ ក្បាច់ហក់លោតក៏ពត់ឲ្យមានបែបផែនសមរម្យឡើងផង ៗ

www.elibraryofcambodia.org

សរុបសេចក្ដីទៅឃើញថា របាំឆៃយ៉ាំ កើតមានឡើងតាំងពីសម័យមនុស្សដើមជាពួកដ្ឋក់ស៊ី មុនគ្រឹស្តសករាជ តែតែងមានការកែប្រែជារឿយៗ ស្របនឹងការវិវត្តន៍នៃបណ្ដាជនគ្រប់តែសតវត្សតៗមក រហូតដល់សព្វថ្ងៃ ក៏មានបែបផែនសមរម្យឡើង ប៉ុន្តែមិនលះបង់លក្ខណៈមនុស្សដើមឡើយ ដូចជាក្បាច់ក្រមាច ក្រមើមញាក់ញ័រខ្លួនជាដើម ។

*

* *

# ៨- របាំពាំកន្ដែរ៉ែ

កាលណាឮសូរពាក្យថា "កន្ដែរ៉ែ" យើងក៏នឹកឃើញភ្លាមដល់សភាពវិលខ្លួន គ្រឡប់គ្រឡិនជាមិនខាន ដ្បិតសព្វថ្ងៃយើងនៅមានពាក្យចំនឹមចំនៀមសំរាប់ពោលចំពោះអាការៈវិលវល់ច្របល់ក្នុងចិត្ត ដោយសារការវល់មមាញឹកសឹងតែវិលមុខនោះ គេថា "វិលមើលតែគេកាច់កន្ដែរ៉ែ" ។ មានចំនុកច្រៀងខ្លះទៀត សំរាប់រាំឃើកក្ដី សំរាប់អ្នកចាំមាត់ច្រៀងលេងនៅតាមវាលស្រែ ឬលើចុងត្នោតក្ដី គេចាប់ផ្ដើមបទឡើងថា "កន្ដែរ៉ែអើយ..." យ៉ាងនេះជាញឹកញាប់ណាស់ ។ មិនតែប៉ុណ្ណោះ ក្នុងសាស្ត្ររឿងបុរាណនៃអក្សរសាស្ត្រយើង សឹងតែគ្រប់សាស្ត្រតែងលើករឿងត្រង់ព្រះរាជាទ្រង់តាក់តែងរៀបព្រះរាជពិធីអ្វីមួយ ហើយមានចាត់ឲ្យអ្នកស្រុកលេងល្បែង-របាំកំសាន្តផងនោះ គេតែងប្រទះឃើញមានពាក្យឈ្មោះ "របាំពាំកន្ដែរ៉ែ" នេះជានិច្ច ។ ត្រង់នេះជាហេតុឲ្យគេយល់បានថា ការពាំកន្ដែរ៉ែ ជារបាំមួយជាប់នៅក្នុងព្រះរាជពិធីនៅក្នុងប្រទេសយើងតាំងពីបុរាណកាលមក ។

www.budinst.gov.kh www.elibraryofcambodia.org

បន្ថែមលើនេះទៀត នៅតាមស្រុកស្រែចំការក្នុងពេលបច្ចុប្បន្ន មានអ្នកកំប្លុកកំប្លែងខ្លះ បេះតាក់ក្បាច់បន្លំខ្លួនឲ្យគេងងើសើចគឹកកង ក៏គេហៅថា "កាច់កន្ត្រៃ" ដែរ ។

ឥឡូវយើងងាកបែរមកអធិប្បាយពី របាំកន្ត្រៃ មែនទែន ដែលមានជារបាំក្នុងប្រពៃណីយើងម្តង(១) ។

ដូចជាយើងរាយរាប់មកហើយខាងលើ ពាក្យកន្ត្រៃ ជាពាក្យសាមញ្ញទូទៅ អ្នកស្រុកស្គាល់ពាក្យនេះសព្វទិសទី ទោះបីជាពុំបានឃើញរូបភាពរបាំនេះប្រត្យក្សនៅឡើយក៏ដោយ ។ ដូច្នេះយើងត្រូវដេញដោលរកឲ្យឃើញនូវទិដ្ឋភាពរបាំប្រជាប្រិយនេះ ដើម្បីលើកយកមកអធិប្បាយធ្វើជាបែប បង្ហាញឲ្យអ្នកស្រុកអានគ ។ ទៅបានស្គាល់ផង ។ តែជាការពិបាកដែរ ព្រោះឯកសារនៅក្នុងក្រុមជំនុំយើង ពុំសូវមានស្តីពីរបាំនេះឲ្យពិស្តារសោះ យើងគ្រាន់តែបញ្ជាក់យកបានន័យខ្លះៗមកផ្សងផ្សំគ្នាយ៉ាងលំបាក ។ រីឯហេតុច្បាស់លាស់ល្មមឲ្យគាត់តែងបាននេះ គឺយើងបានសាកសួរផ្ទាល់ពី

---

១– តាមការស៊ើបសួររបស់យើង របាំនេះសព្វថ្ងៃមានលេងនៅភូមិភាគខាងលើ ហើយមានរាំខ្លោងឈាយផង ។

www.budgetst.gov.kh www.elibraryofcambodia.org

លោកឧកញ៉ារាជវរានុកូល គឹម-យិន ពន់ហ្មាន់ផ្នែកព្រះទីនាំង តេជេន្ទ្រនៅព្រះបរមរាជវាំង, ដែលលោកធ្លាប់ទទួលព្រះបរមរាជ-ឱង្ការរៀបចំ ប្រជុំល្បែងនិងរបាំផ្សេង ៗ មានរបាំកន្ទែវ នេះជាដើម ក្នុងព្រះរាជពិធីសំខាន់ៗ, ដូចយ៉ាងព្រះរាជពិធីបុណ្យចូលឆ្នាំជាអាទិ, តាំងពីក្នុងរជ្ជកាលព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម ( ព្រះសុវណ្ណកោដ ) រហូតមកដល់សព្វថ្ងៃ ។ ពត៌មានដែលយើងប្រមូលបានខ្លះនោះ អាចលើកយកមកពយាការណ៍ដើម្បីទុកជាទិដ្ឋានុគតិ ដល់អ្នកចង់ដឹង ចង់ស្គាល់របាំនេះបាន ដូចការរាប់រៀបតទៅនេះ ៖

## ១- ប្រដាប់ប្រដា

### ក- គ្រឿងភ្លេង -

គ្រឿងភ្លេងក្នុងរបាំនេះ គ្មានអ្វីច្រើនទេ មានតែប៉ុពក ១ និង ស្គរ២ប៉ុណ្ណោះ ។

ប៉ុពកធ្វើពីដើមឫស្សីពក ដែលមានប្រវែងមួយសាច់ ទំហំប៉ុនកដៃក្មេង ហើយខាងចុងមានដាក់អណ្តាតស្លាត់សំរាប់បៀមផ្លុំឲ្យឮសូរ

www.budinst.gov.kh www.elibraryofcambodia.org

ខិនមានពោះរន្ធ ៧ សំរាប់យកម្រាមចុចបិទបើកខ្យល់ ឲ្យមានសំនៀងប្លែកៗគ្នា ។ ឯស្គរពោះនោះ គឺជាស្គរអារក្សដែលយើងធ្លាប់ឃើញសព្វថ្ងៃ(១) ។ ប៉ុន្តែនេះ ជួនកាលមានពួកជនជាតិសំរែ ផ្ទុំព្យលាយជាមួយផងក៏បាន ។

## ខ– គ្រឿងតុបតែង .–

ប្រដាប់ប្រដាសំរាប់តុបតែងជាអលង្ការនៃអ្នករាំកន្ត្រៃ គ្មានអ្វីប្លែកធំដុំទេ ។ សំរាប់អ្នកភ្លេង អ្នកច្រៀងបន្ទរ ស្លៀកពាក់ធម្មតាសុទ្ធសាធ មានតែអ្នករាំដែលគេសន្មតឈ្មោះថា "កន្ត្រៃ" មួយប៉ុណ្ណោះ ដែលតុបតែងខ្លួនប្រាណប្លែកពីគេបន្តិច គឺស្លៀកសំពត់សំឡុយពណ៌ក្រហម ពាក់អាវបំពង់វែង ដៃវែង ពណ៌បៃតង ក្បាលពាក់រៃ ដែលធ្វើពីកំណាត់ពណ៌ក្រហម ឥតស្រេះអង្កាំទេ តែមានរំយោលអង្កាំតែផ្កាក់យោងចាំងពីមុខ ។ ដៃសងខាងកាន់ផ្លិតម្នាងមួយ ។

១– នេះយោងតាមអ្នកស្រុកភ្នំស្លែ ប៉ែកខាងលោកញ៉ាកនិវិភនុក្កុលជា គេអាចលេងជាមួយភ្លេង "ប៉ីកែវ" ដែលមាន : ប៉ី ១, រនាត ១, គង ១, ទ្រខ្មែរ ១ និង ឈើប៉ី ១ ។

www.budinst.gov.kh www.elibraryofcambodia.org

## ២- របៀបរាំ

ក្បាច់រាំកន្ទីរ៉ែ យកលំអាននឹងផ្ទិតមួយគូ ដែលអ្នករាំកាន់នៅដៃទាំងសងខាង ។ កាលណាភ្លេងចាប់លេងឡើង អ្នកច្រៀងទាំងពីរនាក់ឈរនៅទល់មុខគ្នា ឃ្លាតពីគ្នាប្រមាណជា ១០ ម៉ែត្រ ហើយទះដៃច្រៀងស្មើ ៗ គ្នាតាមចង្វាក់ភ្លេង ។ ពេលនោះអ្នកធ្វើកន្ទីរ៉ែ ក៏ចាប់រាំចាក់ក្បាច់ភ្លាម ស្ទុះទៅរកអ្នកច្រៀងខាងឆ្វេងមុន ត្រឡប់មករកអ្នកច្រៀងខាងស្តាំម្តង វិលទៅវិលមកតែយ៉ាងនេះរហូតដល់ឈប់ ។

ឯក្បាច់រាំ មានដំណើរលោត ។ បង្វិលខ្លួន ដៃគ្រវីគ្រវាត់បក់ផ្ទិតគ្មានឈប់ (ប្រហែលជាក្បាច់រាំនេះវិលវក់ដូច្នេះហើយ បានជាមានពាក្យនិយាយចំពោះអ្នកណាប្រកាច់ប្រកិនវិលវក់ ថាដូចជាកន្ទីរ៉ែ)។ សូមបញ្ជាក់ថា អ្នកធ្វើកន្ទីរ៉ែនេះ ជាមនុស្សប្រុស ។ គ្រាន់តែស្លៀកពាក់ជាស្ត្រីដូចយើងកប់រៀបពីសំពត់អាវរួចមកហើយ ។

## ៣- បទភ្លេង និង ចំនុកច្រៀង

ចំនុក និង បទភ្លេងសំរាប់ប្រគុំកន្ទីរ៉ែនេះ គេនិយមយកបទ « ខ្នងក្ន » (១) ។ បទនេះមានចង្វាក់យឺត បន្លឺសំឡេងវែង ៗ

១-- តាមសេចក្តីឲ្យការណ៍របស់លោកគ្រូញ៉ាប្រសើរលេខា ហេង.ភឿន ប៉ា គេអាចលេងបទ បំពេ បទអាយ៉ ឬបទព្រោមតាយ ក៏បាន ។

www.budinst.gov.kh www.elibraryofcambodia.org

នាំឲ្យបញ្ចេញសំឡេងប៉ឺអញ្ចប្លាស់ក្រាន់ក្រេវ តោះបើជាមានស្គរសៀន លើកដាក់ជាថ្នាក់ផ្ទើរខ្ទះ គឺគង់ប្រើទូវចង្វាក់យឺតថ្នមសំឡេងណាស់ដែរ ។ ទំនុកនៃបទខ្ទន់ក្ដីមានសេចក្ដីថា ៖

" ... ឡើងភ្នំចុះភ្នំ ថ្មដាធំៗ ថ្មដាធំៗ រណ្ដាំបែកផ្សែង ៗ
បងដើរមាត់ព្រែក ឮខ្វែកវ៉ាយំ បងដើរដើងភ្នំ ឮឃ្មុំយកផ្កា ៗ
បងបីមាន់ធ្លាក់ ទៅទាក់មាន់ព្រៃ រនាវទូរដើ ដាក់ជង់មិនបាន ៗ
បងអុំទូកធ្វើង ត្រយងយំថ្ងូរ កាត់បឹងត្រើយអូរ តាមរកប្អូនស្រី ៗ
ស្រងមាឡាស្ទើរ ទស្រងមាស្ទើរ បងចាំងដៃមើល ស្រងមមានទ្រង់ៗ
កុកហើរលើមេឃ លែងពីជាប់ជង់ ស្រងមមានទ្រង់ លែងពី
ជាប់ជង់បង... ។ល។

យើងយល់ថាទំនុកច្រៀងមានច្រើនតទៅទៀត ប៉ុន្តែយើងស្រង់យកតែអង្គើខ្លះដែលអាចទុកជាគំរូប៉ុណ្ណោះ ។ ឯសេចក្ដីទំនុកដែលនៅគប់តាមការបង់ចាំនៃអ្នកស្រុកស្រែចំការ មានប្លែកៗច្រើនទៀតនោះ យើងពុំបានលើកយកមកកប់រៀបចាំងអស់បានឡើយ ។

## ៤- ដើមកំណើត

ការដាក់ទង់ដោយដើមកំណើតចាំនេះ អាចចាត់ទុកជាពីរប្រភេទ

www.budinst.gov.kh www.elibraryofcambodia.org

គឺ ១.ប្រភពបែបរឿងព្រេង ១.ទៀតប្រភពបែបការស្រាវជ្រាវ ។

តាមរឿងព្រេងថា កាលនោះមានបុត្រីអ្នកស្តុំមួយនាក់ ឈ្មោះ នាងគាក្ដែរ៉ែ កើតកែក្តិសុបសៅ ក៏ទៅលំហែប្រាណអង្គុយ ក្រោមម្លប់ឈើ ។ ពេលនោះ មានសត្វខ្លាធំ ជាពិសៀនបំរើ ផ្ទាល់ សម្រាប់នាំនាងលេងលំហែកាល់ ១ថ្ងៃ ក៏ខ្លះពាក់ជើងញាក់ខ្លួន ជាចង្វាក់ ឲ្យនាងគង្គារ៉ែរាំលេងកែអផ្សុក ។ នាងរាំបែបបោះបោស អន្ទុលខ្លាចាំងពីខាងនេះម្តង ខាងនោះម្តង ។ កាលនោះមានព្រាន ព្រៃម្នាក់ដើរបរបាញ់ក៏ទៅលបមើលឃើញ ទើបនាំពត៌មាននេះទៅ ទូលស្តេច ព្រះអង្គឲ្យលើកសេហពលម នាំយកនាងគង្គារ៉ែទៅពិ ថ្វាយព្រះអង្គទត បានជាគេប្រឌិតកើតជារបាំនេះឡើង ។

ប៉ុន្តែ បើតាមការស្រាវជ្រាវ បែបជាតិពន្ធុសាស្ត្រ ( E'u'es ethnograph ques ) វិញ គេអាចសន្និដ្ឋានបានថា៖ របាំនេះជាកេរ្តិ៍ មត៌កមួយរបស់មនុស្សដើម ដែលរស់នៅលើទឹកដីបុរាណរបស់ខ្មែរ យើង ។ គឺថា កាលណាមនុស្សដើមទាំងនោះ កកើតបានជាសង្គម មួយហើយ ក៏តែងព្យាយាមតុបតែងសាងអារ្យធម៌របស់ខ្លួនឡើង មានការបង្កើតទំនៀមទម្លាប់ ជំនឿផ្សេង ១ និងសិល្បៈជាដើម ។ គ្រាន់តែប្លែកបន្តិច ព្រោះអារ្យធម៌ដើម ដែលមនុស្សរស់នៅក្នុងព្រៃ

www.budinst.gov.kh www.elibraryofcambodia.org

ជាអ្នកបង្កើតឡើងនោះ រមែងមានគំនិតគាត់ស្របទៅតាមជីវភាពព្រៃផ្សៃយ៉ាងនោះទៅដែរ ។ ដូច្នេះក្បាច់ “ រាំកន្ត្រែ ” មានកំណើតមក ក្នុងអារ្យធម៌បុរាណខ្មែរ ជាមួយនិងរបាំផ្សេងៗទៀតជាច្រើន ដូចជារាំស្នែងទន្សោង រាំត្រុដិ រាំអាប្រែ គឺប្រកតកើតមានក្នុងស្រុកយើងផ្ទាល់តែម្តង ឥតមានចំឡងបែបយ៉ាងមកពីស្រុកណា ជនជាតិណាឡើយ ។

ភស្តុតាងមួយទៀត គឺអ្នកស្រុកនៅក្នុងស្រុកថ្ពងដែលជាភូមិភាគមានមនុស្សជាន់ចាស់ស់នៅពីដើម ហើយទុកកេរ្តិ៍អារ្យធម៌ចាស់ច្រើនបែបមកដល់សព្វថ្ងៃ, គេនៅតែនិយមលេងរបាំនេះ ហើយជួនកាល គេយកតាំងរាំស្នែងទន្សោង មកលេងរួមជាមួយផង ។ ដូច្នេះបានជាមានពាក្យហៅថា “ រាំកន្ត្រែ ស្នែងទន្សោង ” ។

* *

*

www.budinst.gov.kh www.elibraryofcambodia.org

# ៩- របាំសួព័ត្រ

« របាំសួព័ត្រ » បានន័យថា « របាំដើរសួរលើព័ត្រ » ដូច្នេះ ឃើញថាក្បាច់របាំនេះ ជាបែបកីឡាមួយបំឡែក ផ្សំជាមួយសិល្បៈៗ សព្វថ្ងៃឈ្មោះរបាំ « សួព័ត្រ » ហាក់ដូចជាគ្រាន់តែជាសភាពស្រមៃ-យល់សប្តមួយប៉ុណ្ណោះទេ ដ្បិតបែបបទប្រាកដប្រជា គេពុំបានឃើញផ្ទាល់ភ្នែកឡើយ ឮសូរតែតាមចាស់ទុំដែលលោកធ្លាប់ឃើញពីសម័យដើម ហើយលោកនាំយកមកនិទានប្រាប់ប៉ុណ្ណោះ ។ មួយទៀត ដោយរបាំនេះ គេនិយមលេងនៅពេលជាមួយនឹងរបាំកន្តែរ ដែលយើងអធិប្បាយក្នុងទំព័រមុននៃសៀវភៅនេះ រួចមកហើយ អ្នកស្រុកខ្លះក៏និយមហៅឈ្មោះភ្ជាប់គ្នាថា « កន្តែរសួព័ត្រ » ដូច្នេះ តែម្តងក៏មាន ។ ប៉ុន្តែតាមពិត ក្បាច់កន្តែរ និងសួព័ត្រ ខុសប្លែកគ្នាស្រឡះជាពីរផ្នែកផ្សេងគ្នា ។

ក្នុងគោលបំណងចង់ណែនាំជនរួមជាតិយើង ឲ្យបានស្គាល់សព្វគ្រប់នូវកេរ្តិ៍មត៌កសិល្បៈ ដ៏ជាមែកធាងសំខាន់ នៃអារ្យធម៌ខ្មែរពី

www.budinst.gov.kh www.elibraryofcambodia.org

បុកណាមក យើងក៏បានស្រាវជ្រាវរកឯកសារនិងសាកសួរអស់លោកអ្នកចាស់ៗ ដែលធ្លាប់បានឃើញបានយល់(១) ប្រមូលយកសេចក្តីរៀបរាប់ឡើងដើម្បីជាគំរូ ដូចមានតទៅនេះ ៖

## ១- គ្រឿងប្រដាប់ - របៀបលេង

គ្រឿងប្រដាប់សម្រាប់ប្រកបបោះនេះ មានឈើបង្គោលបួន ប្រវែងប្រមាណជា ២ ម៉ែត្រ ៗ គេដាំបង្គោលទាំងបួននេះជាបួនមុម យើងគត់ចំណាំជាសញ្ញា ក. ខ គ. ឃ. រៀងគ្នា ហើយយកខ្សែព្រ័ត្រធ្វើពីស្បែកសត្វ ២ សរសៃប៉ុនៗមេដៃ មកចងពុងបង្គោលខ្វែងគ្នាដូចផែនក្អែក គឺចងពីបង្គោល ក ទៅ គ; ពីបង្គោល ខ ទៅ ឃ ។ បង្គោលនេះគេកប់ដីយ៉ាងជ្រៅ ឯខ្សែខ្វែងក៏ត្រូវតែយ៉ាងតឹងសម្រាប់មនុស្សឡើងដើរសន្ធឹតពីលើ កុំឲ្យទន់ជាបម្រុលបានឡើយ ។

មនុស្ស ២ នាក់ ឬ ៤ នាក់ ស្លៀកខោខ្លីពណ៌ ពាក់អាវសដៃខ្លី ឡើងឈរហើយដើរពីលើខ្សែព្រ័ត្រនេះ ៗ ទៅដៃមានកាន់កន្ទុយ-

១ ឯកសារលេខ ៦៧ ០៥៦ របស់លោក ងឹម ឈុំ នៅឃុំឬស្សីជ្រុំ ស្រុកសណ្តាន់ (កំពង់ធំ) និងសួរពីលោក ខេម ញ៉ាំ ជាវាកនុក្ខូល ងឹម- យ៉ង់ នៅព្រះបរមរាជវាំង ។

www.budinst.gov.kh www.elibraryofcambodia.org

ក្បាលមួយសំណុំធ្វាង មានសណ្ឋានដូចជាផ្ចិតធំវែង ៗ

គ្រឿងភ្លេងសម្រាប់ប្រគំការលេងរបាំនេះ មានស្គរពីរ ទិង ប៉ីពកមួយ ដូចជាប្រដាប់ភ្លេងក្នុងរបាំកន្ដ្រែវ ដែរ ៗ កាលណាភ្លេងចាប់លេងឡើង អ្នករាំលោតហក់ឡើងលើខ្សែព្រ័ត្រ រួចចាប់បន្ទន់ខ្លួនរាំដើរលើខ្សែពីបង្គោលមួយទៅបង្គោលមួយ ហើយបែរត្រឡប់មកបង្គោលដើមវិញ ៗ គឺជាបើរាំពីរនាក់ ម្នាក់ដើរលើខ្សែមួយមកជៀសគ្នាត្រង់កណ្ដាលចំខ្សែវែង តែគេបេះធ្វើបែបជារាំបញ្ចិតបញ្ចៀងខ្លួនមិនឲ្យប៉ះគ្នាទេ ៗ ប្រសិនជារាំដល់ទៅបួននាក់ នោះគេឡើងត្រង់បង្គោលមួយម្នាក់គ្រប់បង្គោលទាំង ៤ ហើយចាប់រាំទៅជៀសគ្នាចំកណ្ដាលម្ដងពីរនាក់ឥតឲ្យប៉ះគ្នាដែរ ៗ ដំណើររាំនេះ គេរាសដៃទាំងសងខាង ឲ្យមានលំនាំជាវេរាំ មិនមែនជាក្បាច់ទន់ភ្លន់តែក្រាយផ្ចិតផ្ចង់ឡើយ គ្រាន់តែគ្រវែសគ្រវាសសំណុំគន្ទុយក្បាលហាក់ដូចជាជួយទប់អាត្មា កុំឲ្យដួលធ្លាក់ពីខ្សែតែប៉ុណ្ណោះ ៗ ដូច្នេះ អ្នករាំស្លព្រ័ត្រទាំងប៉ុន្មានសុទ្ធសឹងជាអ្នកប៉ិនប្រសប់ដើរលើខ្សែដោយការទម្លាប់ហាត់ហ្វឹកហ្វឺនអស់ពេលយ៉ាងយូរ ហើយអ្នករាំនេះទប់អាត្មាបានស្រួលក៏ដោយសារតែគន្ទុយក្បាលជួយបក់ខ្យល់ទប់ផង

www.budinst.gov.kh www.elibraryofcambodia.org

ទប់ស្កាំផនដែរ ៗ ឆ្នាំនេះគេលេងតែរបៀបរាំលើខ្សែព្រ័ត្រ ទៅមកៗ យ៉ាងនេះ ហូតឈប់ ឥតមានផ្លាស់ប្តូរអ្វីទៅទៀតឡើយ ។

## ២- បទភ្លេង-ចំនុកច្រៀង

តាមអ្នកឲ្យការណ៍ បញ្ជាក់ច្រើនគ្នាថា បទសម្រាប់យកមកប្រកបជាមួយឆ្នាំនេះ គឺ បទខ្នងភ្នំ បទសារិកាកែវ បទអុំទូក ឬ បទតាលតាប ។

យើងសូមលើកយកចំនុកខ្លះមកបង្ហាញជូនដូចតទៅ ៖

### ក- ចំនុកសារិកាកែវ

"... សារិកាកែវអើយ ទន្ទឹមដូចក្ដុក ទីទៃតែមុខ ដង្ខ្លួនដូចគ្នា ៗ
សារិកាកែវអើយ សារិកាកែវកើច បងល្ងង់ឲ្យសើច បង់មើលជើងឈ្មេញ ៗ
បងគន់ជើងសក់ រត់ផ្លូវរមេញ បងគន់ជើងឈ្មេញ ក្រឹមដូចគេកាត់ ៗ
សារិកាកែវអើយ សារិកាកែវខ្ញង់ ហើរមកតាំងហ្វូង ល្អល្អះតែមួយ ៗ
អាខ្លះទំមែក អាខ្លះទំត្រួយ ល្អល្អះតែមួយ ទំត្រួយបំផុត ៗ
ស្រឡូនឡូនអើយ ពេញចិត្តញាតិសា ម៉ែស៊ុំខណ្ឌស្វា តាមច្បាប់
ព្រហ្មទេព . . . ៗលៗ

www.budinst.gov.kh www.elibraryofcambodia.org

## ១ – ជំនុកអុំទូក

ប្រុស

ទូកបងវាតវែង បងសែងដាក់ទឹក ចែវព្រួតគ្រឹក បេះមៀនត្រើយនាយ ៗ

អ្នកខ្លះបេះវេច អ្នកខ្លះបេះស្វាយ បេះមៀនត្រើយនាយ បឹងកោះផ្កាយព្រឹក ៗ

ស្រី

កុំអួតទូកវែង ចង់សែងដាក់ទឹក ស្ទឹងជ្រៅពន្លឹក ក្រពើចាំស្ទាប់ ៗ

ប្រុស

ក្រពើអត់ធ្មេញ បងហ៊ានចុះចាប់ ទុកជាចាំស្ទាប់ ស៊ូចាប់ឲ្យមើល ៗ

ស្រី

ក្រពើកាចណាស់ អ្នកកុំរវើល កុំចង់លមើល មុខជាវាខាំ ៗ

( តាមឯកសារលោក គង់-ជណ្ណាណ : លេខ ៦៧.០៣០ )

ចំនុកទាំងនេះនិយមតាមការចូលចិត្តរបស់អ្នកអុំ បើគេជ្រើសយក ចំនុកណា បទណាមួយ មកច្រៀងក៏បាន ៗ ដូចជា កាលណាអ្នកអុំមាន សុទ្ធតែប្រុស ។ ពុំចាំបាច់រកបទណាមានពាក្យផ្ដោះផ្ដងទេ តែបើអ្នកអុំមាន លាយស្រីផង គេចូលចិត្តរកពាក្យបញ្ចិតបញ្ចៀងផ្ដោះផ្ដងច្រើនបន្តិច ដើម្បី បានលេងខាយដាក់គ្នា ៗ

www.budhist.gov.kh www.elibraryofcambodia.org

# ៣– ដើមកំណើត

ការស្រាវជ្រាវរកប្រវត្តិដើមនៃរបាំស្នូព្រ័ត្រ អាចហុចមកនូវប្រភពពីរបែបដែរ គឺបែបរឿងព្រេងនិងបែបស្រាវជ្រាវ ។ តាមរឿងព្រេង គេនិទានថា កាលនោះមានបុរសកាប់ៗសម្នាក់ មានវាសនាបានទៅឡើងគ្រងរាជ្យជាក្សត្រ ដោយនិស្ស័យលោកជាអ្នកស្រុកសាមញ្ញ ព្រះអង្គក៏គ្រាស់បញ្ជាឲ្យបង្កើតជាក្បាច់រាំ របៀបជាអ្នកដើរព្រៃឡើងកាប់មែកឈើឬបោចវល្លិ ។ ឯក្បួនប្រភពរបាំនេះជាតំណាងសូរសព្ទសត្វព្រៃដែលយំឆ្លើយឆ្លងគ្នា ។

ប៉ុន្តែ បើពិចារណាតាមអ្នកស្រាវជ្រាវវិញ របាំនេះជាពួកកេរ្តិ៍សំណល់នៃអារ្យធម៌ខ្មែរបុរាណ គឺពួករស់នៅជាន់ដើមដែលហៅថា "វដ្ដកសី" តាំងពីសតវត្សទី ១ នៃគ្រិស្តសករាជ ឬមុនគ្រិស្តសតវត្សទៅទៀត ព្រោះគ្រឿងប្រដាប់សំកប់លេងអាចបង្ហាញឲ្យយើងឃើញ យើងយល់ថា ជាប្រដាប់សំកប់ជីវភាពអ្នកស្រុកព្រៃភ្នំសម័យដើម ដូចជាកន្ទុយក្ងោក, ព្រិត្រៃស្បែក; ផ្ទុំប៉ុពកជាអាទិ ។ ដូច្នេះការសិក្សាពីរបាំបុរាណទាំងនេះ ហាក់ដូចជាការសើរើមើលអារ្យធម៌ដើមរបស់ជាតិយើងដែរ ។

❋

❋ ❋

www.budinst.gov.kh www.elibraryofcambodia.org

# ១០- របាំរាំវង់

កាលណាយើងពោលពី "របាំរាំវង់" យើងទាំងអស់គ្នាសឹងតែយល់មុនអានអត្ថបទនេះទៅទៀត ។ ហេតុម្តេចបានជាហើយយល់ដូចនេះ? យើងឆ្លើយបានភ្លាមថា ដោយហេតុរបាំនេះកំពុងតែមានឥទ្ធិពលផ្សព្វផ្សាយពេញប្រទេសយើងនៅគ្រាសព្វថ្ងៃ ។ ជាធម្មតារឿងរាំឬសិល្បៈអ្វីក៏ដោយ តែកំពុងមានអាយុរស់នៅ ហើយនៅទាំងខ្ទាំងគ្នាដូចយ៉ាងរបាំរាំវង់នេះ ពិតជាមានអ្នកស្រុកដឹងឮច្រើន ព្រោះអ្នកខ្លះធ្លាប់ឃើញ ធ្លាប់ចូលរួមក្នុងរបាំនេះ ដោយផ្ទាល់ខ្លួនទៀតផងៗបើឃើញជាក់ស្តែងយ៉ាងហ្នឹង ហាក់ដូចជាគ្មានប្រយោជន៍អ្វី នឹងលើកយកបែបបទរបាំនេះ មកអធិប្បាយចងក្រងជាគម្រាប់កម្រាអ្វីថែមទៀតទេ ។ ប៉ុន្តែតាមពិតយើងឃើញមែន យើងធ្លាប់រាំក្នុងរបាំនេះមែន តែសារៈសំខាន់នៃរបាំ, ប្រវត្តិនៃរបាំ ឬបច្ចេកទេសនៃរបាំនេះ យើងពុំបានចាប់ភ្លឹកនឹកយកមកប្រមូលក្រងទុកជាកេរ្តិ៍ឲ្យអ្នកក្រោយទៀតទេ ដោយហេតុយើងគិតថា ចាំសរសេរធ្វើអ្វី បើគេឃើញ គេស្គាល់ស្រាប់គ្រប់គ្នារាល់ៗថ្ងៃ ទៅហើយ ។

កុំផ្ទុះច្នាះឡើយ អ្វីៗតែងតែប្រែប្រួល ពេលវេលាចេះតែផ្លាស់ប្តូរទៅគ្រប់ឆ្នាំ គ្រប់សតវត្ស ។ ហេតុនេះបុណ្យដែលជាចំណូលចូលចិត្តអ្នកស្រុក ក៏រមែងផ្លាស់ប្តូរជាមួយពេលវេលាទៅជាលំដាប់ដែរ ។ ថ្ងៃមុនគេចូលចិត្តរាំគោះអង្រែ តែថ្ងៃនេះ គេបោះបង់ចោលស្ទើរតែអស់រកជាន់មិនឃើញ, ថ្ងៃនេះគេចូលចិត្តរាំវង់ តែមើលទៅថ្ងៃមុខវង់ធ្លាយនោះ ច្បាស់ជាគេលែងនិយមច្រើនគ្នាដូចសព្វថ្ងៃហើយ ។ កាលបើគេលែងនិយម ឬក៏និយមដែរតែតិចតួចខ្សត់ខ្សោយពេក ឥទ្ធិពលនៃបុណ្យនេះក៏សោះសូន្យ របៀបរបប,ប្រវត្តិប្រាកដប្រជានៃបុណ្យនេះក៏រលុបម្តងបន្តិច ៗ យូរៗតែងតែសោះសូន្យរលីងទៅដែរ ជាមិនខាន ។

អាស្រ័យការយល់ដូចពោលមកនេះហើយ ទើបយើងខ្ញុំប្រមូលក្រងក្បួនខ្នាតនៃបុណ្យនេះទុកឡើង ទាន់ពេលវេលាកំពុងតែឃើញច្បាស់ កុំដំអក់ឲ្យអស់បាត់ផុតទៅ ហើយទើបស្តាយការគេជាក្រោយនោះមិនបានឡើយ ។

ហេតុមួយទៀតជាចំណុចសំខាន់គួរឲ្យចាប់អារម្មណ៍ណាស់ គឺគ្រឿងបុណ្យនេះសព្វថ្ងៃធ្លាក់ទៅជាបុណ្យប្រជាប្រិយសុទ្ធសាធទៅហើយ ។ នៅគ្រប់ទីក្រុងទាំងអស់នៃព្រះរាជាណាចក្រយើង តែងតែមានល្បែង

«របាំពាំរង់» ជាពិសេស ភ្លេងនៅបុណ្យចូលឆ្នាំ ដើម្បីធ្វើពិធីនេះ ឲ្យឧឡារិក និងភ្លេងនៅពេលចំនេរពីការងារម្តង ៗ ដ្បិតគេរៀប ភ្លេងបានងាយស្រួលបំផុត មិនប្រកាន់ពេល ប្រកាន់កន្លែងសោះ ឡើយ ទោះបីនៅពេលស្ទូងដក, ពេលច្រូតកាត់, ពេលបំពេញការ ហត្ថកម្ម ស្ថាបនាសន្ធរណសំពប់ជាតិក៏ដោយ ៗ ក្រៅពីនេះ មានភ្លេងនៅពេលប្រកបពិធីសំខាន់ ៗ ក្ដីមួយ ដូចជាពេលរៀប អាពាហ៍ពិពាហ៍និងបុណ្យទានក្នុងគ្រួសារជាដើម ៗ ម្យ៉ាងទៀត ពេលប្រកបរបាំនេះ រមែងតែងតែដុះឡើងនូវសាមគ្គីធម៌ រវាងអ្នក ប្រកបការរួមជាមួយគ្នា គឺថាអាចបង្កើនបានជាកម្លាំងបន្ថែមឡើង ទៀតក្នុងកិច្ចការដែលគេកំពុងតែប្រព្រឹត្ត ៗ ដូចនេះ ឃើញថារបាំ នេះ និយមតាំងពីអ្នកទីក្រុងធំ រហូតដល់អ្នកស្រុកស្រែចំការ, តាំងពីអ្នកមានឋានៈខ្ពង់ខ្ពស់រហូតដល់រាស្ត្រប្រជាសាមញ្ញ ៗ

រីឯរបៀបតាក់តែងនិងរបៀបភ្លេង ដែលយើងប្រមូលយកតាម ការស្តាប់ឃើញស្តាប់ចូលរួមផ្ទាល់ក្នុងរបាំនេះ អាចឲ្យកត់ត្រាជា លាយលក្ខណ៍អក្សរបាន ដូចតទៅ ៖

www.budinst.gov.kh www.elibraryofcambodia.org

# ១- អំពីប្រដាប់ប្រដា

## ក- គ្រឿងភ្លេង .-

តាមធម្មតាប្រដាប់ភ្លេងដែលជាចាំបាច់បំផុតនៃរបាំរាំវង់ គឺមានតែស្គរមួយ និងត្រឡោកមួយគូ ប៉ុណ្ណោះ ។

ស្គរនេះបើតាមការនិយមដំបូង គេច្រើនយកស្គរដែលលុងឈើធ្វើឲ្យមានសណ្ឋានប៉ោងកណ្ដាលដូចត្រឡោកដូង តែមានទំហំធំជាង គឺប្រមាណប៉ុនសម្បកឃ្លោកសាជៀរបើគិតជាទំហំទទឹងមាត់មានប្រវែង ០ម ២០ ទៅ ០ម ២៥ ចំពោះខាងរង្វង់ដែលពាសស្បែក, ឯរង្វង់ចុងម្ខាងទៀត ដែលឥតពាសស្បែក មានទំហំតូចជាងបន្តិច ។ ស្គរបែបនេះគេធ្វើក្តោះពីរជាប់គ្នា ដោយមានឈើឃ្នាបក្រាក់ភ្ជាប់គ្នាតែម្ដង ។ ស្គរមួយបែបទៀត គេលុងឈើដែរ ហើយពាសស្បែកដូចគ្នា តែវាមានសណ្ឋានជាស្គរធំរមនាក្នុងប្រដាប់ភ្លេងពិណពាទ្យ. គឺស្គរពាសតែម្ខាង មានទំហំមាត់រង្វង់ប្រមាណជា ០ម២០ទៅ ០ម៣០ ប៉ុណ្ណោះ ។ ស្គរទាំងពីរយ៉ាងនេះ កាលណាគេវាយ គេយកមកកៀបនិងក្បាលជង្គង់ទាំងសងខាង ហើយគេអង្គុយលើកៅអី,វាយដោយដៃទាំងពីរ ។ ចំណែកគេមកកាន់តែក្លាយទៅ

គេនិយមយកស្គរអារក្សមកវាយជំនួសវិញព្រោះងាយស្រួល ។

ឯត្រឡោក គេយកត្រឡោកដូងតក់ គឺដូងតូចៗ មកពោះក្បាល និងពោះគូថហើយឆ្វៀលយកសាច់ចេញឲ្យអស់ ហាលឲ្យស្ងួត រួចសិតឈើធ្វើជាដង ដោយមានដាក់ដុំគ្រួសតូចៗ ឬគ្រាប់ផ្ទឹងៗ ទៅក្នុងនោះ សំរាប់កាលណាក្រឡុកទៅឲ្យឮសូរធ្វើជាចង្វាក់ អ្នកក្រឡុកកាន់ដងត្រឡោកដែលធ្វើពីឈើមូលយ៉ាងរលោង ដ៏មានកំប៉ោយដំរៀតកំណាត់ពណ៌ជាលំអផង,នៅដៃទាំងសងខាង ក្រឡុករលាស់ រលាក់ជាក្បាច់ឲ្យត្រូវតាមចង្វាក់បទនិមួយៗ ។

សព្វថ្ងៃនេះ គេមានយកវង់ភ្លេងទំនើបថ្មីមកលេងអងជាមួយរបាំនេះតែម្តងក៏មាន ព្រោះចង់ឲ្យរបាំនេះអឹកធឹក ប្រហែលគ្នានឹងរាំវង់ដែរ ។

## ១- សំលៀកបំពាក់[១].-

ចំពោះសំលៀកបំពាក់សំរាប់មនុស្សប្រុសពុំឃើញមានប្លែកអ្វីទេ ព្រោះជារបាំទើបនឹងកើតមានឥឡូវនេះ ការស្លៀកពាក់ក៏ជកដួលទៅតាមនិយមសព្វថ្ងៃនេះដែរ ។

១ សំលៀកបំពាក់នេះ យើងសរកតាមឃើញក្នុងពេលសព្វថ្ងៃនេះ ។

www.budinst.gov.kh www.elibraryofcambodia.org

ចំណែកឯសំលៀកបំពាក់ស្ត្រីវិញ បើតាមជំនាន់មុនឃើញគេនិយមស្លៀកសំពត់ពណ៌ជរជើង គឺសំពត់សូត្រពណ៌ មានជាយប្រកបដោយជរខ្សែរស្រយ ៗ ជួនកាលស្លៀកសំពត់ហូល ឬសំពត់ពណ៌ផ្សេង ៗ តែសុទ្ធជាសំពត់ស្រុងលុបបាត់កំភួនជើង ៗ ឯអាវវិញមិនសូវប្រកាន់របៀបទេ ឲ្យតែជាអាវពណ៌ស្រស់ គឺមានពណ៌រលោងសំរាប់ឲ្យចេញពន្លឺភ្លើងក្នុងពេលយប់ ព្រោះគេនិយមរាំរបាំនេះតែនៅពេលយប់ ៗ ប៉ុន្តែសព្វថ្ងៃមានគេនិយមរាំនៅពេលថ្ងៃដែរ ហើយជួនកាលគេស្លៀកពាក់តាមតែបាន ព្រោះស្រេចហើយនឹងពេលវេលា គឺថា បើជាពេលដើរលេងក៏ជាប់តាំងសំលៀកបំពាក់របៀបដើរលេង, បើកំពុងធ្វើការមានការហត្ថកម្មជាដើមក៏ជាប់តាំងសំលៀកបំពាក់សំរាប់ធ្វើការនោះទៅដែរ ៗ តែការដែលគួរសម្គាល់មួយ ត្រង់អ្នករាំស្ត្រី-ប្រុសនៅក្នុងពេលរាត្រី ច្រើននិយមសៀតផ្កា គឺស្ត្រីសៀតនៅសក់ ប្រុសសៀតនៅអាវលើទ្រូងខាងឆ្វេង ៗ

## គ- ការរៀបចំទីកន្លែង·–

ការរៀបចំកន្លែងរាំ ពុំមានអ្វីជាលំបាកទេ របស់ដែលចាំបាច់

www.budinst.gov.kh www.elibraryofcambodia.org

បំផុតនោះ គឺត្រូវមានតុតូចមួយ និងថូផ្កា ឬផើងផ្កាដែលមានស្លឹក និងផ្កានៅស្រស់ ៗ មួយ ប៉ុណ្ណោះ ។ គេយកតុតូចមកតាំងនៅ - កណ្ដាលវាលជាទីលានរាំ ហើយយកថូផ្កា ឬផើងផ្កាទៅដាក់ពីលើតុតូចនោះ សំរាប់ឲ្យអ្នករាំដើរព័ទ្ធជុំវិញ បើមិនទាន់រាំទេ ប្រុស ៗឈរ ឬអង្គុយនៅម្ខាង ស្រីនៅម្ខាង តុផ្កានៅកណ្ដាល។

## ៣– អំពីរបៀបលេង

### ក– របៀបឲ្យចង្វាក់·–

ក្រោយពីតុបតែងទីកន្លែងបន្តិចបន្តួចរួចហើយ អ្នកវាយស្គរចាប់កេទ៍ស្គរបើបទ ជាប្រយោជន៍ប្រជុំគ្នាផង និងជាការបើកពិធីផង ។ អ្នកអង្រួនត្រឡោកក៏ចាប់គ្រវីត្រឡោកតាមចង្វាក់ស្គរដែលវាយជាចង្វាក់បួន ៗ ឬប្រាំ ៗ ស្មើសំឡេងដូចជា ៖

ទីង-គាក់-ទ្រិល-ទ្រិល ! ឬ គាក់-ទីង-គាក់-ទ្រិល-ទ្រិល !

ពុំមានបំពត់ស្គរទៅតាមបទ និងទំនុកអ្វីមួយឡើយ ឯត្រឡោកវិញត្រូវមានចង្វាក់ដេកដួលទៅស្របជាមួយបទដែលមានសម្លេងញាប់ឬរន្ធូល, ទ្វី ឬ យារវែង, កាលណាដល់ត្រង់ចប់កន្ទុយបទមួយឃ្លា ៗ ត្រូវពេទ៍ម្ដង ៗ ឡើង ។

www.budhist.gov.kh www.elibraryofcambodia.org

## ១- របៀបរាំ.-

ដំបូងឡើងត្រូវប្រុសមួយនាក់(១) ចេញរាំជាការបើកឆាក គឺរាំរបៀបក្បាច់ខ្មែរបុរាណដោយបោះដៃទាំងពីរឲ្យស្រឡះៗពីគ្នា ហើយពត់ចុងម្រាមនឹងកដៃឲ្យទន់ភ្លន់ ទំនងសមជាមួយដៃដែលរាសទៅម្ខាងៗ ឯជើងឈានដើរទៅមុខជកាច តែ ៣ ឬ ៤ ជំហានត្រូវទំលាក់យ៉ាងបន្ទើរមកក្រោយម្តង រួចបន្តទៅមុខទៀត, ជង្គង់បន្ទន់តាមបង្វាក់ម្តងៗ, ទ្រគាកទន់គល់បង្អេះត្រូវលាក់បន្តិចៗ ហើយកាច់ពត់តាមបង្វាក់យឺតៗ ។ ស្មាទាំងសងខាងត្រូវបន្ទន់ទៅតាមចុងដៃដែលបក់ទៅឆ្វេង ឬទៅស្តាំ ។ កាលរាំបានមួយជុំហើយ អ្នកបើកឆាកនោះត្រូវងក់ក្បាលហៅប្រុសៗ គ្នាឯងឲ្យបានជាច្រើននាក់ទៀតចេញទៅរាំជាវង្គគ្នា ។ បានមួយជុំទៀត ទើបទៅឈប់នៅចំពោះមុខស្រីៗ ហើយងក់ក្បាលឬសំពះសុំអញ្ជើញរាំជាមួយ; ស្ត្រីត្រូវទទួលសំពះ ឬងក់ក្បាលតបវិញ ហើយចេញមករាំតាមសេចក្តី

---

១- របៀបជាប់ស្តើងនេះ ដូចកាលគេឲ្យស្ត្រីចេញមុខក៏មាន ។ នៅពេលសព្វថ្ងៃគេនិយមយកអ្នកណាជាម្ចាស់កន្លែងត្រូវចេញនាំគេជាកៀវរាំ តែបើគ្មានម្ចាស់កន្លែងទេ គេនិយមតាមឋានៈ គឺអ្នកធ្លាប់ ទៅកញ្ញើញអ្នកធំ ឬអ្នកចាស់ជាងគេក្នុងចំណោមនោះ ។

អញ្ជើញ គឺប្រុសម្នាក់ស្រីម្នាក់ជាមួយគ្នាៗ ដូច្នេះ ។ ស្រីរាំដើរពីមុខ; ប្រុសពីក្រោយ ឬរេទៅចំហៀងដៃរបស់ស្រីខាងឆ្វេង ឬខាងស្តាំទំនងជាដើរកៀងយ៉ាងល្អមើល ។ បើទុកណាគ្នាខថា ស្រីបែរក្រោយទេ ស្រីពុំចាំបាច់បែរមុខមកក្រោយសោះក៏បាន តែបើមានទំនុកថា ស្រីបែរក្រោយ ឬថា ស្រីត្រូវបែរមកតាក់ត្បាច់រលាស់ស្នា ជាមួយបុរសវិញនោះ ស្រីត្រូវងាកមកចំលមុខទីងបុរសហើយឈានជើងរាំថយឲ្យស្របតាមដំណើរដែលគេដើរវិញ ។

លុះបានជាច្រើនជុំហើយ អ្នកឲ្យចង្វាក់កាន់តែញាប់ឡើង ៗ អ្នករាំក៏កាន់តែញាប់តាមចង្វាក់ ។ លុះអ្នកវាយស្គរកេចស្គរឡើង ទើបអ្នករាំឈប់បែរមុខមករកគ្នា ឈរសំរួលដងខ្លួន ហើយសំពះលាគ្នាទៅវិញទៅមក ទើបដើរចេញពីកន្លែងរាំមកអង្គុយនៅកន្លែងធម្មតារបស់ខ្លួនវិញ ។

## គ_ របៀបច្រៀង.—

អ្នករាំទាំងអស់គ្នា ត្រូវច្រៀងព្រមជាមួយនឹងក្បាច់រាំផង ឯអ្នកអង្គុយ ឬឈរនៅសងខាងទាំងប្រុសទាំងស្រី ក៏ត្រូវតែជួយច្រៀងផងដែរ ។ ការបើកបទឲ្យដឹងថាបទណា ៗ មានចង្វាក់ញាប់ ឬរងើល

www.budinst.gov.kh www.elibraryofcambodia.org

នោះ គឺអ្នកវាយស្គរជាអ្នកដើមគាថា ។ កាលណាគាត់ចាប់វាយស្គរឡើង ក៏ចាប់ច្រៀងភ្លាមឡើងដែរ ដូច្នេះអ្នកទាំងអស់គ្នាក៏ចាំស្តាប់ឲ្យដឹងថាគេច្រៀងបទអ្វី ទើបច្រៀងព្រមគ្នាជាបទនោះទៅ ហើយអ្នករាំ ក៏រាំតាមចង្វាក់បទនោះដែរ(១) ។

## ៤– អំពីចំនុកច្រៀង

ចំនុកច្រៀងសម្រាប់របាំនេះ កាលដើមឡើយឃើញច្រៀងសុទ្ធតែជាពាក្យលាវ ឬពាក្យសៀម ប៉ុន្តែចំណេរតមក គ្រាដែលរបាំនេះចូលស៊ប់មកក្នុងស្រុកយើងហើយ ចំនុកទាំងនោះក៏ក្លាយទៅជាខ្មែរភ្លាមៗទៅ សឹងតែពុំសេសសល់ជានបន្តិចបន្តួចផង ។ ការផ្លាស់ប្តូរនេះបានប្រព្រឹត្តទៅក្នុងរយៈវេលា យ៉ាងខ្លីរវាង ២ ឬ ៣ ឆ្នាំប៉ុណ្ណោះ ។ ត្រង់នេះបង្ហាញឲ្យឃើញការប៉ិនប្រសប់របស់ខ្មែរយើងមួយដែរ គឺថាអ្វីៗក៏ដោយ មុននឹងប្រើប្រាស់ឬនាំគ្នានិយម យើងតែងតែយកមកបន្សាំឲ្យពេញលេញជារបស់យើងសិន ។

---

១– សព្វថ្ងៃ គេនិយមយកវង់ភ្លេងមកលេងកំដរផង ដូច្នេះ គេក៏និយមឲ្យអ្នកចម្រៀងច្រៀងម្នាក់ឯងដាក់នឹងភ្លេងសមសព្វតែម្តង ។

www.budinst.gov.kh www.elibraryofcambodia.org

ក- ចំនុកសម្រាប់បើកឆាក

ប្រជុំគ្នា រីករាយ សប្បាយចិត្ត
ចូររាំឲ្យស្អិត ចូលជិត កុំឲ្យហ្មងសៅ
ចូររាំតាមភ្លេង តាមភ្លេង អង្រោគ្រយប៉ាជ្រៅ
ពេលល្ងាចថ្ងៃសៅរ៍ ជាថ្ងៃឈប់ សម្រាករៀន
(បន្ទរ) ហិបពីយ៉ា យ៉ា យ៉ា ហិបពីយ៉ា ។(១)

*

- អ្នកស្រី, អ្នកស្រី អង្គុយធ្វើអី មកលេងរាំវង់
ស្រីស្រស់មានទ្រង់ មានទ្រង់សណ្ឋា
អញ្ជើញជួយច្រៀង អញ្ជើញជួយថា
នៅក្នុងគេហា ជារបាំរបស់ខ្មែរ ជារបាំរបស់ខ្មែរ
- ផ្ទះបងនៅឆ្ងាយ ដោយឆាយការណិតមេត្តា
ចិត្តស្ម័គ្រមូលគ្នា ស្រីកាសួបងផង
(បន្ទរ)- ផ្កាអើយ អើយផ្កា បងស្រឡាញ់តែផ្កាម្លិះ
រូបរាងបែបនេះ គួរឲ្យស្រឡាញ់ (២)

*

---

១- ចំនុកទាំងនេះ មានអ្នកច្រៀងផ្សេងៗ ទៀតក៏មាន ប៉ុន្តែយើងយកមួយឃ្លានេះ មកបង្ហាញគ្រាន់តាលំនាំ ។ ២- ឃ្លាចុងបំផុតនេះ ស្រេចតែអ្នកច្រៀងគេបំភ្លៃតាមតែនឹកឃើញ ។

www.budinst.gov.kh www.elibraryofcambodia.org

១- ចំនុចដែលមានសកម្មភាព .-

- ពេលរាត្រីខែភ្លឺមកលេងរាំវង់

ស្រីស្រស់មានទ្រង់ រូបល្អអស្ចារ្យ

ល្អអើយ ល្អដូចជាទេវតា - ល្អអើយ ល្អដូចជាទេវតា

មានប្រុសសង្ហា មកលេងរាំវង់

អូនអើយចូរនាំមករាំលេង អូនអើយចូរនាំមករាំលេង

ពួកយើងក្មេង ៗ មកលេងទាំងអស់គ្នា

(បន្ទរ) ជយ - ជយ - ជយ បែរមើលក្រោយ

មកលេងរាំវង់ហើយ !

( បទរាំវង់នេះទាន់ខ្លួនឡើងម្តងទៀត ទើប

ចាប់ជាចំនុចរាំវង់សាជាថ្មី )

※

គ- ចំនុចបែបកំប្លែងខ្មែរ.-

- កូមារនាក់ អឹងអើយ ទៅចាក់លលក

ចាក់បានយកមក យកមក ផ្ញើអូនស្រី ៗ

លក់បានថ្លៃណាស់- អឺងអើយ មួយថ្ងៃបានបី

យកមកផ្ញើស្រី- ផ្ញើស្រី គ្រាន់តែកំសាន្ត ។

(ចំនុកច្រៀងបុរាណ)



www.budinst.gov.kh www.elibraryofcambodia.org

# ៥– អំពីដើមកំណើត

ការសង្កេតរកដើមកំណើតនៃរបាំនេះ នៅពេលបច្ចុប្បន្ន ឃើញថាមតិព្រមគ្នាបានច្រើនឡើងថា មានប្រភពដើមមកពីប្រទេសលាវ (ខ្លះគាត់ថាមកពីសៀម) ។ ហេតុបានជាគេរកឃើញថារបាំនេះមកពីលាវ ព្រោះអ្នកស្រុកខ្មែរដែលនៅជិតទល់ដែនលាវបានចេះច្រើន ចេះរាំរបៀបនេះមុនគេ ដោយភ្ជាប់ទាក់ទងចេញចូលទៅមកជាមួយប្រទេសលាវ ឬបានទាក់ទងពូជពង្សគ្រួសារជាមួយគ្នា នាំឲ្យចេះនិយមទំនៀមជាមួយគ្នាឡើង ។ ក្រៅពីនេះ មានរបៀបតែងខ្លួនដូចជាស្ត្រីស្លៀកសំពត់ស៊ីនជាដើម ។ បន្ទាប់ពីហូរតាមខ្មែរដែលនៅទល់ដែនទឹកលាវ នៅមានការហូរតាមខ្មែរនៅទល់ដែនសៀមទៀត ព្រោះសៀមបានយកលំនាំរបាំនេះ មកទុកជាប្រពៃណីគេយូរមកហើយ ព្រមទាំងបានកែច្នៃរបាំបន្ថែមទៀត ។ ការហូរចូលពីតាមរយៈជាយដែនសៀមនេះ ទើបតែមាននៅក្នុងរវាងឆ្នាំ ១៩៦៦-៦៧ ប៉ុណ្ណោះ, ឯការហូរតាមជាយដែនលាវវិញ មានមកជាយូរឆ្នាំណាស់ហើយ គឺតាំងពីមុនសម័យបារាំង មកតាំងអាណាព្យាបាលនៅលើទឹកដីឥណ្ឌូចិននោះទៅទៀត ។

www.budinst.gov.kh www.elibraryofcambodia.org

សរុបទៅ យើងគួរពិចារណា ដោយយកប្រវត្តិសាស្ត្រជាសំអាង, យើងយល់បានថា៖ សិល្បៈរាំរែក, ក្បាច់ក្បូរផ្សេង ១ កើតមាននៅប្រទេសខ្មែរយើងមុនគេបង្អស់ ក្នុងបណ្តាប្រទេសជិតខាងទាំងនេះ ដូចជាក្បាច់របាំគន្ធី (Dause classique ). ដែលសព្វថ្ងៃយើងហៅថា "របាំព្រះរាជទ្រព្យ" នោះ មានមកតាំងពីសតវត្សទី ៣ នៃគ្រិស្តសករាជ ។ ដូច្នេះសិល្បៈរបស់យើងនោះ បានសល់នៅគ្រប់ភូមិភាគទាំងអស់ដែលជាអាណាចក្រហ្វុណនរបស់យើង ប៉ុន្តែប្រែក្លាយបន្តិចបន្តួច ទៅតាមចំណូលចិត្តរបស់អ្នកស្រុកដែលរស់នៅដោយពួកដោយក្រុម ឬ ដោយសញ្ជាតិដែលបែកខ្ញែកគ្នាទៅជាប្រទេសផ្សេងៗ ។ ហេតុនេះហើយបានជាសិល្បៈទាំងនេះវិលត្រឡប់មកកាន់ប្រទេសជាតិយើងវិញ ក្រោយពេលដែលជាតិជិតខាងយកទៅពត់បត់បែនតាមរបៀបគេរួចហើយ តែនៅមានអ្នកស្រុកយើងនិយមស្រឡាញ់រាប់អានគ្រប់ៗគ្នា ដូចជាភ្លេងពិណពាទ្យជាដើម ។ មិនតែប៉ុណ្ណោះ គឺបានជាសេចក្តីសំគាល់មួយទៀតថា ទោះបីជាខ្មែរយើងទទួលយកសិល្បៈការខ្សែពីកាលដើមរបស់យើងនេះមកវិញក៏ដោយ ក៏យើងគ្រាន់តែទុកជាសិល្បៈប្រជាប្រិយប៉ុណ្ណោះ

www.budinst.gov.kh www.elibraryofcambodia.org

បានទុកដាក់ដល់ថ្នាក់ខ្ពស់ ជាសិល្បៈតន្ត្រីប្រចាំជាតិយើងឡើយ ។ ព្រោះជាធម្មតា សិល្បៈប្រជាប្រិយនៃជនជាតិនីមួយៗ រមែងខ្ចីគ្នាទៅវិញទៅមករវាងប្រទេសជិតខាងគ្នាជាដរាប ។

អាស្រ័យហេតុនេះ យើងយល់ថា រាំវង់ពិតជាខ្ចីចូលពីប្រទេសជិតខាងយើងមែន ប៉ុន្តែជាសិល្បៈចាស់បុរាណដែលមានប្រភពដើមនៅប្រទេសយើងនោះឯង ។ អាស្រ័យលើការយល់ដូច្នេះទៀត ដែលជាហេតុនាំឲ្យអ្នកស្រុកយើងត្រូវចំណង់របស់ខ្លួន ព្រោះជាកេរ្តិ៍មតិកចាស់របស់ផងខ្លួនស្រាប់ ទើបនាំគ្នានិយមគុះគរឡើងៗ បើឃើញថាប្លែក គឺប្លែកត្រង់ទម្លាប់លាវគេរាំដន្លែគ្នា ឆ្លាស់ប្រុសមួយស្រីមួយគ្រប់ៗគូ រាំដើរវាតវង់ជុំវិញ ប៉ុន្តែ នេះក៏ជារបៀបរាំខ្មែរយើងដែរ ប្លែកតែត្រង់ចាក់ក្បាច់មិនសូវពិបាក ហើយស្លៀកពាក់ធម្មតាមិនបាច់តែងគ្រឿងច្រើនផង ។ ត្រង់ចំណុចនេះទៀត ដែលអ្នកស្រុកខ្មែរយើងចូលទៅ នាំគ្នានិយមតាមយ៉ាងហ័សណាស់ ព្រោះស្រួលងាយនឹងធ្វើតាមបាន គឺមិនបាច់តែងខ្លួនឲ្យមានអលង្ការប្លែកៗផង មិនបាច់ចាក់ក្បាច់កាច់តែតាមកំណត់លក្ខខណ្ឌពិបាកពេកផង ។

លាវសន្មតរបាំនេះហៅ "ឡាំលាវ ឬ ឡាំកេន" (១) របាំបែបឡាំលាវនេះឯង ដែលចូលមកក្នុងដែនខ្មែរ គ្រប់ភូមិភាគព្រំដែនលាវជាយូរមកហើយ . ឥឡូវក៏ក្លាយចូលក្នុងរាំវង់នេះទៅដែរ ។ លុះនូវទៅសៀម សៀមហៅថា "ឡាំថូន" (២) ប៉ុន្តែខ្មែរយើងដោយឃើញថា ក្បាច់រាំនេះដើរជុំវិញគ្នា ទើបយើងសន្មតថា "រាំវង់" វិញ ។

ចប់

---

១– ឡាំ = លាវ ប្រែថារាំ, កេន គឺគ្រឿងភ្លេងផ្លុំ ដែលខ្មែរហៅ ផែន, បានន័យថា រាំអាស្រ័យនឹងសម្លេងផែន ។

២– ឡាំ = រាំ, ថូន = ឈ្មោះស្គរតូចដែលខ្មែរហៅថាគន គឺបានសេចក្ដីថា រាំអាស្រ័យនឹងស្គរ ។

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org